**សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និង វិទ្យាសាស្ត្រសេដ្ឋកិច្ច**
Université Royale de droit et des sciences Economoiques
Royal University of Law and Economics

# សារណាបញ្ចប់ការសិក្សា

# ការអភិវឌ្ឍរាជធានីភ្នំពេញបច្ចុប្បន្ន

ស្រាវជ្រាវចាប់ពីថ្ងៃទី១៦ ខែមីនា ឆ្នាំ២០២០ ដល់ថ្ងៃទី១៥ ខែឧសភា ឆ្នាំ២០២០

ស្រាវជ្រាវដោយ
និស្សិតឈ្មោះ **ឌុក សុផាន់ម៉ៃ**

សាស្ត្រាចារ្យណែនាំ
លោក **ហៀង សាង**

ថ្នាក់បរិញ្ញាបត្រ **រដ្ឋបាលសាធារណៈ**
ជំនាន់ទី១៣

ឆ្នាំចូលសិក្សា ២០១៦
ឆ្នាំសរសេរសារណា ២០២០

# **សេចក្តីថ្លែងអំណរគុណ**

ខ្ញុំបាទឈ្មោះ **ឌុក សុផាន់ម៉ៃ** ជានិស្សិតថ្នាក់បរិញ្ញាបត្ររដ្ឋបាលសាធារណៈ ឆ្នាំទី៤ ជំនាន់ទី១៣ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច។

**សូមគោរពកិច្ច និងកតញ្ញូតាធម៌ចំពោះ**

លោកឪពុកឈ្មោះ **ឌួន សម្បត្តិ** អ្នកម្តាយ **នន់ ពៅ** ដែលមានគុណយ៉ាងធំធេងមិនអាចកាត់ថ្លៃបានចំពោះរូបកូន ដែលបានផ្តល់កំណើត ចិញ្ចឹមបីបាច់ថែរក្សារូនកូនប្រកដដោយព្រហ្មវិហារធម៌ និងបានបញ្ជូនកូនឱ្យទៅសាលារៀនទទួលការសិក្សារៀនសូត្រក្រេបជញ្ជក់យកនូវចំណេះដឹង ដើម្បីឱ្យកូនរស់នៅក្នុងសង្គមប្រកដដោយកិត្តិយស និងសេចក្តីថ្លៃថ្នូរ ចេះបែងចែកទង្វើល្អ ឬ អាក្រក់ និងចេះតស៊ូជំនះគ្រប់ឧបសគ្គក្នុងជីវិត។

ខ្ញុំបាទសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះ ឯកឧត្តមបណ្ឌិតសាកលវិទ្យាធិការ **លុយ ចណ្ណា** និងសាកលវិទ្យាធិការរង ព្រមទាំងសាស្ត្រាចារ្យ បុគ្គលិក នៅសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ចទាំងអស់ ដែលបានខិតខំបង្ហាត់បង្រៀន ផ្តល់ចំណេះដឹង និងចំណេះធ្វើដើម្បីឱ្យរូបខ្ញុំបាទទទួលយកចំណេះដឹងរហូតអាចបញ្ចប់ការសិក្សាបានដោយជោគជ័យ។

ជាពិសេសខ្ញុំបាទសូមថ្លែងអំណរគុណជូនចំពោះលោកសាស្ត្រាចារ្យ **ហៀង សាង** ដែលជាសាស្ត្រាចារ្យណែនាំ ដោយលោកបានចំណាយពេលវេលាដ៏មានតម្លៃ លះបង់កម្លាំងកាយចិត្ត មិនខ្លាចនឿយហត់ ដើម្បីជួយ ណែនាំ និងជំរុញការសរសេរស្នាដៃនេះ តាំងពីដើមរហូតដល់បញ្ចប់ជាស្ថាពរ។

ខ្ញុំបាទក៏សូមថ្លែងអំណរគុណជាអតិបរិមាដល់ ឯកឧត្តម **ឃួង ស្រេង** អភិបាលនៃគណៈអភិបាលរាជធានីភ្នំពេញ និងមន្ត្រីក្នុងសាលារាជធានីភ្នំពេញទាំងអស់ក្នុងការសហការយ៉ាងកក់ក្តៅ ក្នុងការផ្តល់ឯកសារ ព្រមទាំងផ្តល់ជាមតិយោបល់ចំពោះសារណានេះ។

ជាចុងក្រោយខ្ញុំបាទសូមប្រសិទ្ធពរជ័យ សិរីមង្គល វិបុលសុខគ្រប់ប្រការ ជូនលោកអ្នកមានគុណទាំងឡាយឱ្យជួបប្រទះតែពុទ្ធពរទាំងឡាយបួនប្រការគឺ **អាយុ វណ្ណៈ សុខៈ ពលៈ** កុំបីឃ្លៀងឃ្លាតឡើយ។

# អារម្ភកថា

ក្នុងរយៈពេលសិក្សាបួនឆ្នាំ នៅសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច បានកន្លងផុតទៅយ៉ាងឆាប់រហ័សណាស់។ នៅក្នុងរយៈពេលសិក្សាមួយនេះបានផ្តល់នូវចំណេះដឹងថ្មីៗដល់រូបខ្ញុំបាទក៏ដូចជាមិត្តនិស្សិតគ្រប់រូប ក្រោមការបង្ហាត់បង្រៀន យ៉ាងយកចិត្តទុកដាក់ពីសំណាក់ លោកគ្រូសាស្ត្រាចារ្យ និងអ្នកគ្រូសាស្ត្រាចារ្យ ដែលបានចំណាយពេលដ៏មានតម្លៃរបស់លោក បានជួយបណ្តុះបណ្តាលធនធានមនុស្ស ដើម្បីជំរុញដល់ការអភិវឌ្ឍប្រទេសជាតិ ពីមួយថ្ងៃទៅមួយថ្ងៃ មនុស្សជាតិតែងតែមានការអភិវឌ្ឍផ្នែកគំនិតស្មារតីក្នុងការសិក្សាស្រាវជ្រាវ បង្កើតនូវអ្វីដែលថ្មី អ្វីដែលជាគុណប្រយោជន៍សម្រាប់មនុស្សជាតិនាពេលបច្ចុប្បន្ន និងអនាគត។ ដោយបានយោងតាមតម្រូវការជាក់ស្តែងនៃកម្មវិធីសិក្សារបស់សាកលវិទ្យាល័យ ក្នុងនាមខ្ញុំបាទជានិស្សិតបរិញ្ញាបត្រមានកិត្តិយស និងសេចក្តីសោមនស្សរីករាយយ៉ាងក្រៃលែងក្នុងការបង្កើត និងសរសេរសារណាបញ្ចប់ការសិក្សានេះឡើងមក ក្នុងគោលបំណងចែករំលែកចំណេះដឹងដែលបានសិក្សាកន្លងមកក្នុងថ្នាក់បរិញ្ញាបត្ររដ្ឋបាលសាធារណៈ ហើយជាពិសេសគឺដើម្បីបង្ហាញពីសម្ថតភាព និងលទ្ធភាពនៃការយល់ដឹងទាក់ទងទៅនឹងប្រធានបទ "**ការអភិវឌ្ឍរាជធានី ភ្នំពេញបច្ចុប្បន្ន**" ។

តាមរយៈប្រធានបទនេះ ខ្ញុំបាទសង្ឃឹមថាសារណាបញ្ចប់ការសិក្សាមួយនេះ ពិតជាអាចផ្តល់ចំណេះដឹងមួយផ្នែកដល់បណ្តាលអ្នកសិក្សាស្រាវជ្រាវ សិស្ស និស្សិត ដែលចង់ស្វែងយល់ ឬចង់សិក្សាឱ្យស៊ីជម្រៅអំពី ការអភិវឌ្ឍរាជធានីភ្នំពេញ របស់ប្រទេសកម្ពុជានាពេញបច្ចុប្បន្ន។ ដើម្បីជាចំណេះដឹងមួយសម្រាប់បណ្តាអ្នកសិក្សាស្រាវជ្រាវ និងសិស្ស និស្សិត ជំនាន់ក្រោយបន្តការសិក្សាបន្ថែមទៀត។

ជាទីបញ្ចប់ខ្ញុំបាទ សូមធ្វើការអភ័យទោសទុកជាមុន នូវរាល់កំហុសខុសឆ្គងទាំងឡាយដែលកើតមានឡើង ដោយអចេតនា តាមរយៈ កំហុសអក្ខរាវិរុទ្ធ ការបកស្រាយ និងការប្រើប្រាស់ពាក្យពេចន៍មិនសមស្រប ក៏ដូចជាមានការខ្វះខាតនូវអត្ថន័យក្តី។ ជាពិសេសខ្ញុំបាទសង្ឃឹមថានឹងទទួលបានការយល់ស្របអធ្យាស្រ័យ ហើយក៏រង់ចាំទទួលរាល់ការកែលម្អពីសំណាក់សាស្ត្រាចារ្យ សិស្ស និស្សិត មិត្តអ្នកអានដោយក្តីអនុគ្រោះផង។

# មាតិកា

**ទំព័រ**

**សេចក្តីផ្តើម**........................................................................................................១
ក.លំនាំបញ្ហានៃការស្រាវជ្រាវ........................................................................................................១
ខ.ចំណោទបញ្ហានៃការស្រាវជ្រាវ........................................................................................................១
ឃ. គោលបំណងនៃការស្រាវជ្រាវ........................................................................................................២
ង.វិសាលភាព និងដែនកំណត់........................................................................................................២
ច.វិធីសាស្ត្រស្រាវជ្រាវ........................................................................................................២
ឆ.រចនាសម្ព័ន្ធនៃការបញ្ចប់ការស្រាវជ្រាវ........................................................................................................៣

## ជំពូកទី១

## រំលឹកទ្រឹស្តី

**១.១ និយមន័យអភិបាល**........................................................................................................៤
**១.២ ការអភិបាលតាមបែបប្រជាធិបតេយ្យ**........................................................................................................៤
**១.៣ ប្រវត្តិរាជធានីភ្នំពេញ**........................................................................................................៥
**១.៤ រាជធានីភ្នំពេញ**........................................................................................................៨
**២.៥ ក្រុមប្រឹក្សា**........................................................................................................៩
**២.៦ គណៈអភិបាល**........................................................................................................១០
**១.៧ នាយករដ្ឋបាល**........................................................................................................១១
**១.៨ គណនេយ្យភាព**........................................................................................................១១

## ជំពូកទី២

## ស្ថានភាពទូទៅរបស់រាជធានីភ្នំពេញ

**២.១ ស្ថានភាពសេដ្ឋកិច្ច**........................................................................................................១២
២.១.១ សភាពទីក្រុង និង ស្ថាបត្យកម្ម........................................................................................................១៥
២.១.២ ឧស្សាហកម្ម និងសិប្បកម្ម........................................................................................................១៧
១.១.៣ រ៉ែ និងថាមពល........................................................................................................១៨
១.១.៤ គមនាគមន៍........................................................................................................១៨

១.១.៥ សេវាកម្ម ................................................................................................................១៩
២.១.៦ ទេសចរណ៍...........................................................................................................២១
២.១.៧ វិស័យការងារ ......................................................................................................២២
**២.២ ស្ថានភាពសង្គមកិច្ច**.....................................................................................................២២
២.២.១ ការងារសង្គមកិច្ច ..................................................................................................២២
២.២.២ ស្ថានភាពអប់រំ និងកីឡា..........................................................................................២៣
២.២.៣ ស្ថានភាពសុខាភិបាល.............................................................................................២៦
**២.៣ ស្ថានភាពនៃការប្រើប្រាស់ដីធ្លីការគ្រប់គ្រងធនធានធម្មជាតិបរិស្ថាន** ......................៣៣
២.៣.១ ស្ថានភាពនៃការប្រើប្រាស់ដីធ្លី...................................................................................៣៣
២.៣.២ ស្ថានភាពបរិស្ថាន...................................................................................................៣៥
២.៣.៣ ការងារធនធានទឹក.................................................................................................៣៧
**២.៤ ស្ថានភាពនៃការគ្រប់គ្រងរដ្ឋបាលនិងសន្តិសុខសណ្តាប់ធ្នាប់សាធារណៈ** ................៣៨
២.៤.១ ការងារអភិបាលកិច្ច ..............................................................................................៣៩
២.៤.២ ការអភិវឌ្ឍមណ្ឌលធនធានមនុស្ស..........................................................................៤០
២.៤.៣ វិស័យមុខងារសាធារណៈ ........................................................................................៤០
២.៤.៤ ការគ្រប់គ្រងដែនដីនិងការគ្រប់គ្រងស្ថិតិ......................................................................៤១
២.៤.៥ ការងារសន្តិសុខនិងសណ្តាប់ធ្នាប់សាធារណៈ .............................................................៤២

## ជំពូកទី៣

## របបគំហើញនៃការអភិវឌ្ឍ

**៣.១. ការស្ថាបនាផ្លូវ** ..........................................................................................................៤៧
៣.១.១ គម្រោងរៀបចំបង្កើតផ្លូវថ្មើរជើងថ្មីនៅរាជធានីភ្នំពេញ.........................................................៤៧
៣.១.២ ការស្ថាបនា មហាវិថីថ្មី១ខ្សែ ទទឹង៣០ម៉ែត្រ និងបណ្តោយជាង៥គីឡូម៉ែត្រ..............................៤៨
៣.១.៣ ការសម្រួលប្រព័ន្ធចរាចរស្តុបក្បាន់២ និងការពង្រីកផ្លូវសហព័ន្ធរុស្ស៊ី ....................................៤៩
៣.១.៤ ការបើកគន្លងផ្លូវអាទិភាព រថយន្តក្រុងនៅចំកណ្តាលទ្រូងផ្លូវ...............................................៥០
៣.១.៥ គ្រោងកសាងផ្លូវក្រោមដីពីរខ្សែ.................................................................................៥២
៣.១.៦ ការបង្កើតរង្វង់មូលនៅកន្លែងតំបន់ក្បាន់២ និងការពង្រីកទទឹង .......................................៥៣
៣.១.៧ គម្រោងបើកផ្លូវ២ខ្សែនៅអមសងខាងផ្លូវរថភ្លើងដើម្បីដោះចរាចរណ៍......................................៥៤

**៣.២ ការស្តាបនាប្រពន្ធរំដោះទឹក និងបរិស្ថាន**......................................................៥៥
៣.២.១ ប្រឡាយបង្ហូរទឹកមានសារៈសំខាន់ណាស់សម្រាប់ទីក្រុង ..........................................៥៥
៣.២.២ ការដ្ឋានស្តាបនាប្រព័ន្ធលូ ការដាំដើមឈើ នៅលើមហាវិថីព្រះនរោត្តម ...............................៥៦
៣.២.៣ ការដ្ឋានប្រឡាយស្ទឹងមានជ័យ សម្រេចបានជាង១០០០ម៉ែត្រ ........................................៥៧
៣.២.៤ ការពង្រាយ បង្គន់អនាម័យ នៅតាមទីសាធារណៈនានាចំនួន១២កន្លែង................................៥៨
៣.២.៥ ការសម្អាតមហាវិថីឈ្នះឈ្នះឱ្យបានស្អាតជាប្រចាំ..........................................................៥៩
៣.២.៦ ការដាំដើមឈើជិត ១០០០ដើម អមផ្លូវជាតិលេខ៦A ........................................................៦០
**៣.៣ ការស្តាបនាស្ពានអាកាសថ្មើរជើង**..............................................................................៦១
៣.៣.១ ការស្តាបនាស្ពានអាកាសថ្មើរជើងផ្សារដើមគរ និងសន្ទរម៉ុកជាផ្លូវការ....................................៦១
៣.៣.២ គម្រោងកសាងស្ពានអាកាសថ្មើរជើងប្រមាណជា ២៥ស្ពានទៀត.........................................៦២
**សេចក្តីសន្និដ្ឋាន**..........................................................................................................៦៥
**អនុសាសន៍**...................................................................................................................៦៧
**ឯកសារយោង**
**ឧបសម្ព័ន្ធ**

# សេចក្តីផ្តើម

# សេចក្តីផ្តើម

## ក.លំនាំបញ្ហានៃការស្រាវជ្រាវ

រាជធានីភ្នំពេញ ជាមជ្ឈមណ្ឌលនយោបាយ សេដ្ឋកិច្ច ទេសចរណ៍ វប្បធម៌ និងការទូត ដែលមានការអភិវឌ្ឍន៍ លើគ្រប់វិស័យ ស្ថិតនៅភាគខាងត្បូងនៃប្រទេសកម្ពុជា ត្រង់ចំណុចទន្លេចតុមុខ ដែលជាចំណុចប្រសព្វរវាងទន្លេ មេគង្គលើ មេគង្គក្រោម ទន្លេសាប និងទន្លេបាសាក់។ មានផ្ទៃដីសរុបចំនួន ៦៩២.៤៦គីឡូម៉ែត្រក្រឡាស្មើនឹង ០.៣៨% នៃផ្ទៃដីសរុបទូទាំងប្រទេសដែលចែកចេញជា១៤ខណ្ឌ ១០៥សង្កាត់ និង៩៥៣ភូមិ។[1]

ដោយសង្កេតឃើញថារាជធានីភ្នំពេញពីមួយថ្ងៃទៅមួយថ្ងៃមានការអភិវឌ្ឍន៍ឥតឈប់ឈរ ការអភិវឌ្ឍវិស័យហេដ្ឋារចនាសម្ព័ន្ធរូបវន្ត និងរដ្ឋជាមួយ និងឯកជនជាអាទិ៍ ការស្ថាបនាស្ពានអាកាស ផ្លូវក្រោមដី វត្តមានទីក្រុងរណប អគារពាណិជ្ជកម្ម ផ្សារទំនើប សំណង់បុរី សណ្ឋាគារ ខុនដូប្រណិតៗ និងមជ្ឈមណ្ឌលកំសាន្តគ្រប់ប្រភេទសម្រាប់ បម្រើជូនប្រជាពលរដ្ឋ ធុរៈជន និងអ្នកវិនិយោគិន ភ្ញៀវទេសចរណ៍ជាតិ និងអន្តរជាតិ ដែលនិយមរស់នៅ និងកំសាន្ត តាមបែបទំនើប។

ទីក្រុងភ្នំពេញបានសម្រេចនូវកំណើនគួរឱ្យកត់សម្គាល់ ក្នុងរយៈពេល ១០ឆ្នាំចុងក្រោយនេះហើយបច្ចុប្បន្ននេះ មានប្រជាជនជិត២ លាននាក់ កំពុងរស់នៅក្នុងទីក្រុងដែលបន្តពង្រីកខ្លួនបន្តិចម្តងៗមួយនេះ។ ការទទួលបានសេវា ជាមូលដ្ឋាននៅកម្រិតខុសៗគ្នា ជាមួយនឹងបញ្ហាប្រឈមជាច្រើនពាក់ព័ន្ធនឹងប្រព័ន្ធលូ ការសំអាតទឹកស្អុយ ការដឹក ជញ្ជូនជាសាធារណៈ និងសំណល់រឹង។ ប្លង់គោល ២០៣៥ ប្រកបដោយមហិច្ឆតារបស់របស់ទីក្រុងនេះ បានដាក់ចេញនូវចក្ខុវិស័យជាយុទ្ធសាស្ត្រដើម្បីសម្រេចកំណើនក្នុងពេលជាមួយគ្នាការហូរចូលនូវការវិនិយោគពីបរទេស បានរួមចំណែកធ្វើឱ្យកំណើនក្នុងទីក្រុងកើនឡើង ទីនេះបន្តិចទីនោះបន្តិចដែលរឹតតែដាក់សម្ពាធបន្ថែមទៀតលើហេដ្ឋារចនាសម្ព័ន្ធរបស់ទីក្រុង។

## ខ.ចំណោទបញ្ហានៃការស្រាវជ្រាវ

រាជធានីភ្នំពេញបច្ចុប្បន្ន កំពុងតែមានការអភិវឌ្ឍន៍ពីមួយថ្ងៃទៅមួយថ្ងៃឥតឈប់ឈរលើគ្រប់វិស័យរដ្ឋទាំងវិស័យ ឯកជន និងវិស័យសាធារណៈផងដែរ។ ហើយគេសង្កេតឃើញថាការផ្លាស់ប្តូរជីវភាពរបស់ប្រជាជនក្នុងរាជធានី ហេដ្ឋារចនាសម្ព័ន្ធ សំណង់លំនៅដ្ឋាន កំពុងតែមានសន្ទុះខ្លាំងក្លាមែនទែនក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ។

តើដំណើរការនៃការអភិវឌ្ឍន៍រាជធានីភ្នំពេញ បានបំពេញសេចក្តីត្រូវការដល់ប្រជាពលរដ្ឋយ៉ាងដូចម្តេចខ្លះ? ព្រមទាំងជួបបញ្ហាប្រឈម ការបំពុលផ្សេងៗ និងវិធានការដោះស្រាយនៃការបំពុលទាំងនោះ?

---

[1] ទិន្នន័យសាលារាជធានីភ្នំពេញ

## គ. គោលបំណងនៃការស្រាវជ្រាវ

គោលបំណងក្នុងការកំណត់យកប្រធានបទដែលទាក់ទងទៅនឹង "**ការអភិវឌ្ឍរាជធានីភ្នំពេញបច្ចុប្បន្ន**" យកមកសរសេរសារណាបញ្ចប់ការសិក្សា ថ្នាក់បរិញ្ញាបត្រផ្នែករដ្ឋបាលសាធារណៈ ខ្ញុំបាទមានគោលបំណងដល់សំខានៗដូច ខាងក្រោម៖

១.ស្វែងយល់ពីការអភិវឌ្ឍរាជធានីភ្នំពេញបច្ចុប្បន្ន

២.សារៈសំខាន់នៃការអភិវឌ្ឍទីក្រុង

៣.យុទ្ធសាស្ត្រអភិវឌ្ឍន៍រាជធានីភ្នំពេញតាមគោលនយោបាយរបស់រាជរដ្ឋាភិបាល

៤.ស្វែងយល់ពីចំណុចវិជ្ជមាន និងអវិជ្ជមានរបស់ការអភិវឌ្ឍទីក្រុង

៥.សមិទ្ធផលរាជធានីភ្នំពេញសម្រេសបានក្នុងពេលថ្មីៗនេះ។

## ឃ.វិសាលភាព និងដែនកំណត់

នៅប្រធានបទនីមួយៗតែងតែមានដែនកំណត់របស់ខ្លួន។ ដូច្នេះអ្វីដែលទាក់ទងនឹងប្រធាបបទ "**ការអភិវឌ្ឍរាជធានីភ្នំពេញបច្ចុប្បន្ន**" គឺខ្ញុំបាទមានគោលបំណងចង់បកស្រាយ និងស្រាវជ្រាវទៅលើអ្វីដែលទាក់ទង និងការអភិវឌ្ឍរាជធានីភ្នំពេញ ក៏ដូចជាសមិទ្ធផលរយៈពេលថ្មីៗនេះតែប៉ុណ្ណោះ។

## ច.វិធីសាស្ត្រស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវប្រធានបទនេះគឺ ខ្ញុំបាទបានស្វែងរកឯកសារដែលពាក់ព័ន្ធនានា នៅក្នុងបណ្ណាល័យនីតិសាស្ត្រ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច សាលារាជធានីភ្នំពេញ តាមប្រព័ន្ធអ៊ីនធឺណែត គេហទំព័រផ្សេងៗមួយចំនួន ដោយក្នុងនោះខ្ញុំបានប្រមូលផ្តុំឯកសារទាំងនោះយកមកវិភាគ និងសរសេរជាសារណា បញ្ចប់ការសិក្សានេះឡើង។

## ឆ.រចនាសម្ព័ន្ធនៃការបញ្ចប់ការស្រាវជ្រាវ

សារណាបញ្ចប់ការសិក្សារបស់ខ្ញុំបាទនេះត្រូវបានបែងចែកជា ៣ ជំពូកដែលមានដូចខាងក្រោមនេះ៖

- **ជំពូកទី១ "រំលឹកទ្រឹស្តី"** ៖ នៅក្នុងជំពូកនេះខ្ញុំបាទបានបែងចែកជាប្រាំបី ចំណុចទី១ និយមន័យអភិវឌ្ឍ ចំណុចទី២ ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ ទី៣ ប្រវត្តិរាជធានីភ្នំពេញ ទី៤ រាជធានីភ្នំពេញ ទី៥ ក្រុមប្រឹក្សា ទី៦ គណៈអភិបាល ទី៧ នាយករដ្ឋបាល ទី៨ គណនេយ្យភាព។
- **ជំពូកទី២ "ស្ថានភាពទូទៅរបស់រាជធានីភ្នំពេញបច្ចុប្បន្ន"** ៖ នៅក្នុងចំណុចនេះខ្ញុំបាទបានបែងចែកជាបួនចំណុច ចំណុចទី១ និយាយពីស្ថានភាពសេដ្ឋកិច្ច ទី២ ស្ថានភាពសង្គមកិច្ច ទី៣ ស្ថានភាពបរិស្ថាន ទី៤ ស្ថានភាពនៃការគ្រប់គ្រងរដ្ឋបាល និងសន្តិសុខសណ្តាប់ធ្នាប់សាធារណៈ។

❖ **ជំពូកទី៣ "របបគំហើញនៃការអភិវឌ្ឍ"** ៖ ជំពូកបញ្ចប់នេះខ្ញុំបានលើកយកចំនួនបីចំណុចមកនិយាយរួមមាន ចំណុចទី១ ការស្តាបនាផ្លូវ ទី២ ការស្ថាបនាប្រព័ន្ធរំដោះទឹក និងបរិស្ថាន ទី៣ការស្ថាបនាស្ពានអាកាសថ្មើរជើង។ ចំណុចបញ្ចប់មាន សេចក្តីសន្និដ្ឋាន អនុសាសន៍ និងឧបសម្ព័ន្ធ។

# ជំពូកទី១

# រំលឹកត្រីស្ដី

# ជំពូកទី១
# រំលឹកទ្រឹស្តី

## ១.១ និយមន័យអភិវឌ្ឍ

អភិវឌ្ឍ មានន័យថាសេចក្តីចម្រើន[2] ដំណើរការនៃការផ្លាស់ប្តូរ ឬ ការប្រែប្រួលទៅរកសភាពមួយដែលធំជាងមុន ខ្លាំងជាងមុន ប្រសើរជាងមុន ចាប់អារម្មណ៍ជាងមុន ជោគជ័យជាងមុន ឬ ជឿនលឿនជាងមុន ។ ម្យ៉ាងវិញទៀត ការអភិវឌ្ឍនៅត្រង់នេះគឺសំដៅដល់ការអភិវឌ្ឍប្រកបដោយចីរភាព

## ១.២ ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ

ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ (Democratic Development) សំដៅទៅលើការអភិវឌ្ឍដែលដំណើរការដោយមានលក្ខណៈ (១) ភាពជាតំណាងសាធារណៈ (២) ស្វ័យភាពរបស់មូលដ្ឋាន (៣) ការពិគ្រោះយោបល់ និងការចូលរួម (៤) ការឆ្លើយតប និងគណនេយ្យភាព (៥) ការលើកកម្ពស់គុណភាពជីវិតរបស់ប្រជាពលរដ្ឋក្នុងមូលដ្ឋាន (៦) ការលើកស្ទួយសមធម៌ (៧) តម្លាភាព និងសុចរិតភាព និង (៨) វិធានការប្រឆាំងអំពើពុករលួយ និងរំលោភអំណាច។

ប្រជាធិបតេយ្យ វាគឺជាប្រព័ន្ធដែលពាក់ព័ន្ធនឹងការពង្រាយអំណាចនយោបាយទៅក្នុងដៃមហាជនដែលបង្កើតជារដ្ឋាភិបាលអ្នកម្ចាស់ឆ្នោត រឺ រដ្ឋាភិបាលតំណាងរាស្ត្រ និង សេរីភាពក្នុងការនិយាយស្តី ប្រជាធិបតសេរី ការប្រើប្រាស់ផ្សេងទៀត ប្រជាធិតេយ្យ គឺជាទម្រង់នៃការគ្រប់គ្រងរដ្ឋដែលសិទ្ធ និងអំណាចក្នុងការចាត់ចែងកិច្ចការប្រទេសជាតិស្ថិតនៅក្នុងដៃរបស់ប្រជាពលរដ្ឋ ហើយដាច់ខាតត្រូវមានប្រព័ន្ធធានាដល់ការប្រើសិទ្ធ និង អំណាចជាម្ចាស់របស់ប្រជាពលរដ្ឋជាអចិន្ត្រៃយ៍។

រដ្ឋាភិបាលប្រជាធិបតេយ្យ គឺជារដ្ឋាភិបាលមួយដែលបង្កើតឡើងដោយប្រជាពលរដ្ឋ របស់ប្រជាពលរដ្ឋដើម្បីប្រជាពលរដ្ឋ។

- ដោយប្រជាពលរដ្ឋ មានន័យថា ប្រជាពលរដ្ឋជាអ្នកជ្រើសរើសតំណាងរបស់ខ្លួនដោយចំមុខនិងមាន តម្លាភាព។
- របស់ប្រជាពលរដ្ឋ មានន័យថា ប្រជាពលរដ្ឋជាអ្នកបោះនិងទម្លាក់តំណាងនោះពីតំណែងវិញនៅពេលណាតំណាងនោះមិនធ្វើកាឆ្លើយតបទៅនឹងផលប្រយោជន៍របស់ប្រជាពលរដ្ឋនៅពេលណាក៏បាន លើកលែងតែតំណាងណាដែលត្រូវទម្លាក់ នៅពេលដាច់អាណាត្តិដែលកំណត់ដោយច្បាប់។

[2] វចនានុក្រមខ្មែរ សម្តេចសង្ឃរាជ ជួន ណាត

- ដើម្បីប្រជាពលរដ្ឋ មានន័យថា តំណាងត្រូវបំពេញការងារដើម្បីផលប្រយោជន៍ប្រជាពលរដ្ឋ ដែលតម្រូវដោយ ប្រព័ន្ធនៃការគ្រប់គ្រងរដ្ឋ ដែលមានតុល្យភាពអំណាចរវាងរដ្ឋាភិបាលនិងប្រជាពលរដ្ឋ។

## ១.៣ ប្រវត្តិរាជធានីភ្នំពេញ

ដំបូងឡើយភ្នំពេញមានឈ្មោះថាខេត្រកោះឫស្សីកែវ ដែលមន្ត្រីត្រួតខេត្តនេះមានងារថា ចៅពញារាជាមេត្រី។ ក្នុងរាជពង្សាវតារខ្លះបាននិទាន ពីប្រវត្តិសាស្ត្រនៃក្រុងភ្នំពេញ ដោយមានសេចក្តីសម្រួលដូចតទៅ៖ ដើមឡើយមានការកត់ត្រា មួយសតវត្សក្រោយមកនិយាយរៀបរាប់រឿងនិទាននៃការកកើតភ្នំពេញដែលនិទានអំពីស្ត្រីអ្នកស្រុកម្នាក់ជាអ្នកមានទ្រព្យស្តុកស្តម្ភ ឈ្មោះដូនពេញដែលផ្ទះគាត់តាំងនៅលើត្រើយខាងលិចនៃទន្លេប្រាបឈាម ទន្លេចតុមុខសព្វថ្ងៃគឺទីក្រុងភ្នំពេញ (កាលណោះគេហៅថា ខេត្តកោះឫស្សីកែវ)។[3] នៅចុងសតវត្សទី១៤ កាលណោះរាជធានីខ្មែរគឺស្ថិតនៅសៀមរាបនៅឡើយដែលមានចំងាយ ៣៥០ km ទៅភាគខាងលិច។

នាសម័យថ្ងៃមួយ ក្នុងរដូវវស្សាមានទឹកជំនន់នៅប្រទេសលាវយ៉ាងធំបណ្តាលអោយបាក់ច្រាំងរលំដើមគគីរជាច្រើនហើយអណ្តែតបណ្តោយទឹកតាមទន្លេមេគង្គរហូតមកដល់ទន្លេប្រាបឈាម។ ក្នុងចំណោមនោះមានដើមគគីរធំមួយបានអណ្តែតមកទើនៅត្រង់មាត់កំពង់របស់ដូនពេញ។ គាត់ក៏បានបបួលញាតិមិត្តជិតខាងជិះទូកទៅចងដើមគគីរនោះ ហើយនាំយកមកលើគោក។ កាលបើអ្នកទាំងនោះរើសំរាមនៅគល់គគីរ ស្រាប់តែឃើញព្រះពុទ្ធរូបបួនព្រះអង្គ និងរូបបដិមាថ្ម មានលក្ខណៈជាព្រាហ្មណ៍ នៅក្នុងប្រហោងឈើនោះ។ ពួកអ្នកស្រុកបានដង្ហែរូបបដិមាទាំងនោះ យកទៅតំកល់ទុកនៅផ្ទះដូនពេញ ហើយគាត់បានអោយគេជញ្ជូនដីពូនដំបូកភ្នំភាគឦសានផ្ទះ និងអោយគេយកឈើគគីរនោះសង់ព្រះវិហារតូច មួយនៅលើកំពូលភ្នំនោះ ហើយបានយកព្រះពុទ្ធរូបនោះទៅតំកល់ទុកព្រះវិហារនោះនៅឆ្នាំ ជូត ឆស័ក ព.ស. ១៩១៦ គ.ស ១៣៧២។ តមកទៀតដូនពេញបានអោយគេសង់ខ្ទមមួយខាងឦសានព្រះវិហារ រួចគេយកបដិមាថ្ម ទៅតំកល់ទុកទីនោះ ហើយបានសន្មតថា អ្នកតា ព្រះចៅ ។[4]

ពិធីបុណ្យសម្ពោធក៏ត្រូវបានប្រារព្ធឡើង ដើម្បីសម្ពោធពុទ្ធសេនាសនៈ យ៉ាងអធិកអធម។ ដោយអាស្រ័យហេតុនេះ ភ្នំនេះក៏មានឈ្មោះហៅថា ភ្នំដូនពេញ ហើយដែលយូរៗទៅក្លាយនៅត្រឹមតែភ្នំពេញ ដូចយើងហៅសព្វថ្ងៃនេះ។ គួរគប្បីបញ្ជាក់ថា ចំពោះរូបបដិមាដែលដូនពេញបានរកឃើញក្នុងរន្ធដើមគគីរនោះរាជពង្សាវតារ និង

---

[3] ឯកសារប្រវត្តិរាជធានីភ្នំពេញ

[4] ឯកសារ https://l.facebook.com/l.php?u=http%3A%2F%2Fwww.phnompenh.gov.kh%2F%3Ffbclid%3DIwAR1QWs14Z90o81NPXvULoOQfQrQ399qM1qKt1W47nbl-ns-1zCw1LgC6Zvc&h=AT0ZsovlVI4ugyh8W_seBX6W_Mo7fDLktICmn3ZOUh4nr3VHcNqkTzXQkVJpElfipa5U_k-N8AhxpBUYJi5SYj8RCaYcb-GIRbQTzoMjuttaVQMwOa50CRUMcXDHFCbasUuIbA

អត្ថបទចំលងតៗមកទៀតនិយាយមិនស្របគ្នាសោះ ខ្លះថាមានពុទ្ធបដិមាបួនអង្គធ្វើពីលង្ហិន និងបដិមាថ្មកាន់ស័ង្ខ និងគទា (ព្រះនារាយណ៍?) ខ្លះថាមាន ព្រះពុទ្ធរូប ពីរអង្គមានព្រះភ័ក្ត្រឈរ ជាបួនទិស ខ្លះទៀតថាមានព្រះពុទ្ធរូបសំរិទ្ធមួយព្រះអង្គ មានព្រះភ័ក្ត្រ តាំងសមាធិ និងរូបបដិមា ១ ដៃកាន់ស័ង្ខមានផ្នួងសក់ដូចជាពួកព្រាហ្មណ៍។ តែបើតាមរូបតំណាងដែលមានតំកល់នៅក្នុងព្រះវិហារវត្តភ្នំ (ភ្នំដូនពេញ) សព្វថ្ងៃគឺជាព្រះពុទ្ធរូបប្រក់នាគ ៤ អង្គគង់លើបុស្បុកទល់ព្រះប្រឹស្ន (ខ្នង) នឹងគ្នាទៅវិញ។ ការរកឃើញនេះត្រូវបានចាត់ទុកថាជាការប្រសិទ្ធិពររបស់ទេព្តា និងអ្នកខ្លះយល់ថាជាសញ្ញាដែលរាជធានីខ្មែរនឹងត្រូវមកតាំងនៅភ្នំពេញនេះ។ ដើម្បីតំកល់វត្ថុសក្តិសិទ្ធិដែលបានរកឃើញ ដូនពេញបានលើកកូនភ្នំតូចមួយនៅលើច្រាំងទន្លេខាងលិចនៃទន្លេសាប និង បានអភិសេកជាមួយទីសក្ការៈបូជា បច្ចុប្បន្នត្រូវបានគេស្គាល់ថាវត្តភ្នំនៅចុងខាងជើងភាគកណ្តាលនៃភ្នំពេញ។ ភ្នំដូនពេញបានយកឈ្មោះតាមអ្នកកសាងវាឡើង និងបរិវេណជុំវិញនោះត្រូវបានគេស្គាល់ ក្រោយមកនៅត្រឹមតែ ភ្នំពេញ។ ក្រោយមកក៏មានឈ្មោះថា រាជធានីចតុមុខ មានន័យថា ទីក្រុងដែលមានមុខបួន។ ឈ្មោះនេះដែរយកតាមការរត់ប្រសព្វគ្នានៃទន្លេ ៤ គឺមាន ទន្លេមេគង្គលើ ទន្លេមេគង្គក្រោម ទន្លេបាសាក់ និង ទន្លេសាប។ ទន្លេទាំង ៤ បានរត់ប្រសព្វគ្នាត្រង់កន្លែងដែលក្រុងចតុមុខបានតាំងនៅដូច្នេះក៏តាំងឈ្មោះដូច្នេះទៅ ក្រុងចតុមុខ។

ភ្នំពេញបានក្លាយទៅជារាជធានី នៃប្រទេសកម្ពុជាជាលើកដំបូងក្នុងរជ្ជកាលស្តេចពញាយ៉ាតដែលជាស្តេចនៃអាណាចក្រខ្មែរនាសម័យនោះ។ ស្តេចពញាយ៉ាតបានផ្ទេររាជធានីពីរាជធានីអង្គរធំ មកភ្នំពេញ បន្ទាប់ពីរាជធានីត្រូវបានក្តោបក្រសោបយកដោយប្រទេសសៀមប៉ុន្មានឆ្នាំមុននោះបន្តិច។ ក្នុងរជ្ជកាលព្រះបាទនរោត្តម ព្រះមហាក្សត្រនៃ ព្រះរាជាណាចក្រកម្ពុជា ក្រុងភ្នំពេញបានក្លាយជាកន្លែងឈរជើងរបស់រាជរដ្ឋាភិបាលកម្ពុជាហើយនិងព្រះបរមរាជវាំង។[5]

រាជធានីភ្នំពេញចាប់ផ្តើមស្ថាបនាលើកដំបូងបង្អស់នៅពុទ្ធសតវត្សទី២១ គ្រិស្តសតវត្សទី១៥ ក្នុងរជ្ជកាលព្រះបរមរាជា (ពញាយ៉ាត) គឺព្រះស្រីសុរិយោពណ៌ នៅពេលដែលទ្រង់បោះបង់ចោលព្រះរាជវាំងអង្គរមកកសាងព្រះរាជវាំងថ្មីនៅទួលបាសាន្តក្នុងខែត្រស្រីសឈរ ដែលសព្វថ្ងៃហៅថា ស្រុកស្រីសន្ធរ ក្នុងខេត្តកំពង់ចាម។ ប៉ុន្តែដោយទីទួលបាសាន្តនោះ ក្នុងរដូវភ្លៀងមានទឹកលិចរាល់ឆ្នាំ ទ្រង់បានសាងប្រាសាទព្រះរាជវាំងហើយគង់នៅបានតែមួយឆ្នាំ ក៏ទ្រង់ស្តេចយាងមកកសាងទីក្រុងថ្មី នៅឆ្នេរទន្លេបួនមុខ គឺក្រុងភ្នំពេញសព្វថ្ងៃនេះ នៅ គ.ស. ១៤៣៤។ មានចេតិយមួយនៅពីក្រោយវត្តភ្នំ ដែលតំកល់ព្រះអដ្ឋិធាតុ ព្រះពញាយ៉ាត និង ព្រះញាតិវង្ស ដូចគ្នាដែរ ក៏មានរូបចំលាក់ខាងពុទ្ធសាសនា ដែលសេសសល់ពីសម័យអង្គរផងដែរ។

[5] ប្រវត្តិសាស្ត្រប្រទេសកម្ពុជា

ភ្នំពេញនៅតែជារាជធានីអស់រយៈពេល ៧៣ ឆ្នាំចាប់ពីឆ្នាំ ១៤៣២ ដល់ ១៥០៥។ វាត្រូវបានគេបោះបង់ចោលអស់រយៈពេល ៣៦០ ឆ្នាំចាប់ពីឆ្នាំ១៥០៥ ដល់ ១៨៦៥ដោយសារតែស្តេចបន្តបន្ទាប់ ព្រោះតែជំលោះផ្ទៃក្នុងរវាងពួកស្តេចដណ្តើមរាជ្យគ្នាទៅវិញទៅមក។ ព្រះមហាក្សត្រក្រោយៗមកទៀតបានផ្លាស់រាជធានីជាច្រើនលើក និង បានបង្កើតរាជធានីនៅទីតាំងផ្សេងៗ នៅទូលបាសាន្ត ស្រីសន្ធរ ពោធិ៍សាត់ លង្វែក ល្វាឯម និង ឧដុង្គ។

នៅសតវត្សទី១៧ ពួកអន្តោប្រវេសន៍ជប៉ុនក៏បានមកតាំងលំនៅនៅជាយក្រុងនៃភ្នំពេញសម័យបច្ចុប្បន្ននេះ។ សហគមន៍ព័រទុយហ្គាល់តូចមួយបាននៅសេសសល់នៅភ្នំពេញរហូតមកដល់សតវត្សទី១៧ ដែលកំពុងធ្វើសកម្មភាពពាណិជ្ជកម្មនិងសាសនានៅក្នុងប្រទេសនេះ។ វាមិននៅរហូតដល់ឆ្នាំ ១៨៦៦ ទេ ក្រោមរជ្ជកាលនៃព្រះបាទនរោត្តម (១៨៦០-១៩០៤) ព្រះបុត្រាច្បងនៃព្រះបាទអង្គដួង ដែលទ្រង់បានដឹកនាំប្រទេសក្នុងនាមជួសសៀម ដែលភ្នំពេញបានក្លាយជាទីតាំងអចិន្ត្រៃយ៍នៃរដ្ឋាភិបាលនិងរាជធានីនៃប្រទេសកម្ពុជា ហើយក៏ជាកន្លែងដែល ព្រះរាជវាំងថ្មីត្រូវបានសាងសង់ឡើងផងដែរ។ នៅពេលផ្តើមឆ្នាំ ១៨៧០ ពួកអាណានិគមនិយមបារាំងបានកែប្រែពីភូមិតាមមាត់ទន្លេមួយទៅជាទីក្រុងមួយ ដោយពួកគេបានសាងសង់ សណ្ឋាគារ សាលារៀន គុក បន្ទាយទាហាន ធនាគារ ការិយាល័យការងារសាធារណៈ ការិយាល័យទូរលេខន៍ សាលាកាត់ក្តី និង អគារបំរើសេវាសុខភាព។ នៅឆ្នាំ ១៨៧២ មួយប៉ព្រិចភ្នែកដំបូង ទីក្រុងសម័យថ្មីមួយក៏បានប្រែរូបរាង នៅពេលនោះ ពួករដ្ឋការអាណានិគមបានប្រើសេវានៃសហគ្រិនម៉ៅការបារាំង លើ-ផ្វូសគា ដើម្បីសាងសង់ផ្ទះបេតុង ៣០០ ខ្នងដំបូងសម្រាប់លក់ និង ជួលទៅអោយពួកពាណិជ្ជករចិន។ កាលជំនាន់អាណានិគមបារាំង ភ្នំពេញស្ថិតក្នុងរដ្ឋបាលដែនដីជាស្រុកមួយនៅក្នុងខេត្តកណ្តាល ដែលសព្វថ្ងៃត្រូវនឹងស្រុកអង្គស្នួលសព្វថ្ងៃនេះនិងបរិវេណភ្នំពេញសព្វថ្ងៃដែរវាលែងតែខណ្ឌព្រែកព្នៅ ជ្រោយចង្វារ ច្បារអំពៅ មានជ័យ ដង្កោ ឬស្សីកែវ និងសែនសុខចេញ នេះបើផ្អែកលើប្រវត្តិលោកតាង៉ុយដែលលោកកើតនៅក្នុងស្រុកភ្នំពេញនាសម័យនោះ។

នៅទសវត្សឆ្នាំ១៩២០ ភ្នំពេញត្រូវបានគេស្គាល់ថាជា គុជអាស៊ី និង ជាងបួនទសវត្សបន្ទាប់ ភ្នំពេញបានបន្តឆ្លងកាត់ការអភិវឌ្ឍយ៉ាងរហ័សជាមួយការសាងសង់ផ្លូវដែកទៅព្រះសីហនុ និង ព្រលានយន្តហោះអន្តរជាតិពោធិ៍ចិនតុង (ឥឡូវ អាកាសយានដ្ឋានអន្តរជាតិភ្នំពេញ)។ កាលណោះ ក្នុងរជ្ជកាលព្រះបាទស៊ីសុវត្ថិ-មុន្នីវង្ស (១៩២៧-១៩៤១) ភ្នំពេញស្ថិតនៅជាស្រុកចំណុះខេត្តកណ្តាល (១៩២៧-១៩៤១) ហើយចៅហ្វាយស្រុកភ្នំពេញមានងារជា បំរុងរាជា និង បាឡាត់ស្រុកភ្នំពេញមានងារជាពិភ័ក្តារាជាសង្គ្រាម។[6]

ភ្នំពេញយកតាមឈ្មោះវត្តភ្នំ ជាទីទួលតូចល្មមមួយដែលលម្អពីលើដោយវត្តអារាមមួយដែលបានកសាងឡើងនៅឆ្នាំ១៣៧៣ ហើយវាក៏ជាទីកន្លែងសំគាល់ចាប់បដិសន្ធិតាមព្រេងនិទានរបស់ទីក្រុង ដែលសព្វថ្ងៃវត្តភ្នំ

[6] ប្រវត្តិរាជធានី

មានទីតាំងស្ថិតនៅ សង្កាត់ វត្តភ្នំ ខណ្ឌដូនពេញ។ នៅទីបរិវេណវត្តភ្នំគេសង្កេតឃើញថា ប្រជាជន និង ភ្ញៀវទេសចរជាតិ ជាច្រើនបានទៅលេងកំសាន្តនៅទីនោះ ជាពិសេសថ្ងៃបុណ្យជាតិ ឬ ថ្ងៃបុណ្យប្រពៃណីជាតិធំៗ បង្កើតបានជាភាពសប្បាយរីករាយ និងកន្លែងទីសក្ការៈបូជាសម្រាប់ព្រះពុទ្ធសាសានា និង ពុទ្ធសាសនិក គ្រប់មជ្ឈដ្ឋានផងដែរ។

ក្នុងរាជ្យព្រះបាទ ពញាយ៉ាត រាជធានីនេះត្រូវបានប្រទាននាមថា ក្រុងចតុមុខ ឬ ក្រុងចតុមុខមង្គលសកលកម្ពុជាធិបតី សិរីធរបវរ ឥន្ទបត្តបុរី រដ្ឋរាជសីមាមហានគរ។[7]

## ១.៤ រាជធានីភ្នំពេញ

ក្នុងចំណោមបណ្ដាជនជាតិអាស៊ីទាំងក្នុង និងក្រៅប្រទេស រាជធានីភ្នំពេញ គឺជារាជធានី ដែលមានកេរ្តិ៍ឈ្មោះល្បីក្នុងការទទួលស្វាគមន៍ភ្ញៀវទេសចរណ៍ច្រើនជាងគេនៅក្នុងព្រះរាជាណាចក្រកម្ពុជា។ រាជធានីភ្នំពេញ មានទីតាំង ស្ថិតនៅប្រសព្វនៅទន្លេធំ ៣ ជាប់ដៃទន្លេ ៤ នៃទន្លេមេគង្គ ទន្លេសាប និងទន្លេបាសាក់ នៅផ្នែកខាងស្តាំមុខ ព្រះបរមរាជវាំង។ រាជធានីភ្នំពេញ គឺជាមជ្ឈមណ្ឌលពាណិជ្ជកម្ម នយោបាយ និង វប្បធម៌ ដែលជាលំនៅដ្ឋានរបស់ ប្រជាពលរដ្ឋ ចំនួន ១.៤៧០.៣០៣នាក់ (ស្ថិតិ ឆ្នាំ២០១៨) ជាមួយនឹងបរិមាណប្រជាជនសរុបទូទាំងប្រទេស ចំនួន ១១.៤ លាននាក់។[8] រាជធានីភ្នំពេញមានខណ្ឌចំនួន១៤ ក្នុងនោះរួមមានមានៈ

- ❖ខណ្ឌចំការមន ដែលមាន ៥សង្កាត់ ៤០ភូមិ
- ❖ខណ្ឌដូនពេញ ដែលមាន ១១សង្កាត់ ១៣៤ភូមិ
- ❖ខណ្ឌ៧មករា ដែលមាន ៨សង្កាត់ ៦៦ភូមិ
- ❖ខណ្ឌទួលគោក ដែលមាន ១០សង្កាត់ ១៤៣ភូមិ
- ❖ខណ្ឌដង្កោ ដែលមាន ១២សង្កាត់ ៩១ភូមិ
- ❖ខណ្ឌមានជ័យ ដែលមាន ៧សង្កាត់ ៥៩ភូមិ
- ❖ខណ្ឌឫស្សីកែវ ដែលមាន ៧សង្កាត់ ៣០ភូមិ
- ❖ខណ្ឌសែនសុខ ដែលមាន ៦សង្កាត់ ៤៧ភូមិ
- ❖ពោធិ៍សែនជ័យដែលមាន ៧សង្កាត់ ៥៥ភូមិ
- ❖ខណ្ឌជ្រោយចង្វារ ដែលមាន ៥សង្កាត់ ២២ភូមិ
- ❖ខណ្ឌព្រែកព្នៅ ដែលមាន ៥សង្កាត់ ៥៩ភូមិ

[7] ប្រវត្តិសាស្ត្រកម្ពុជា

[8] ជំរឿនឆ្នាំ២០១៨

❖ខណ្ឌច្បារអំពៅ ដែលមាន ៨សង្កាត់ ៤៩ភូមិ

❖ខណ្ឌបឹងកេងកង ដែលមាន ៧សង្កាត់ ៥៥ភូមិ(ថ្មី)[9]

❖ខណ្ឌកំបូល ដែលមាន ៧សង្កាត់ ៥៣ភូមិ(ថ្មី)[10]

រាជធានីភ្នំពេញ ក៏ជាច្រកចូលមួយដ៏សំខាន់នៃបណ្តាប្រទេសផ្សេងៗនៅលើពិភពលោកជាតំបន់បេតិកភណ្ឌ មានសាសនាចំរុះជាងគេនៅលើពិភពលោក និងមានអំណោយផលពីធម្មជាតិ ដោយមានប្រាសាទអង្គរវត្ត នៅភាគ ខាងលិច ឆ្នេរសមុទ្រដ៏ស្រស់ស្អាតនៅភាគខាងត្បូង និងមានដើមកំណើតជនជាតិភាគតិចនៅបណ្តាខេត្តជាច្រើននៃ ភាគឥសានប្រទេស។

រាជធានី ភ្នំពេញបានបង្ហាញនូវវប្បធម៌មួយចំនួន និងភាពទាក់ទាញបែបប្រវត្តិសាស្រ្តរួមមាន ព្រះបរមរាជវាំង វិហារព្រះកែវមរកត និងសារមន្ទីរជាតិ។ មិនត្រឹមប៉ុណ្ណោះ មានសណ្ឋាគារថ្នាក់ផ្កាយប្រាំ ផ្ទះសំណាក់ភោជនីយដ្ឋាន អន្តរជាតិ ហាងគុយទាវតាមដងផ្លូវ ក្លិបកំសាន្តថ្នាក់ក្នុងស្រុក និងក្លឹបឪស្កូថ្នាក់អន្តរជាតិ ។ល។

រាជធានី ភ្នំពេញ ជារាជធានីដែលមានកំណើនប្រជាជនផ្លាស់ប្តូរ ដូចបណ្តា ទីក្រុងទេសចរណ៍អាស៊ានដទៃទៀតដែរ។ បរិមាណភោជនីយដ្ឋាន និងសណ្ឋាគារ បានរីករាលដាលគួរឱ្យកត់សំគាល់ នៅប៉ុន្មានឆ្នាំកន្លងទៅនេះ មិនត្រឹមតែប៉ុណ្ណោះកំណើនភ្ញៀវទេសចរណ៍បានកើនឡើងយ៉ាងគំហុក ពីមួយឆ្នាំទៅមួយឆ្នាំ។ ច្រកទ្វារចេញចូល អន្តរជាតិផ្លូវគោកចំនួន ៣ ត្រូវបានចាប់ដំណើរការនៅឆ្នាំ ២០០៨ ហើយសព្វថ្ងៃ យើងអាចធ្វើដំណើរតាមផ្លូវ អាកាសដោយផ្ទាល់ពីរាជធានីភ្នំពេញទៅទីក្រុងអាស៊ានមួយចំនួនផងដែរ ។ ប្រព័ន្ធផ្លូវគោកត្រូវបានជួសជុលនិងធ្វើ អោយប្រសើរឡើងបន្តិចម្តងៗ ធ្វើឱ្យការធ្វើដំណើរមានភាពងាយស្រួលរួមទាំងការដឹកជញ្ជូនតាមជើងយន្តហោះក្នុង ស្រុក និងការបំពីសេវាទៀងទាត់តាមរថយន្តក្រុង ពីរាជធានីទៅទីក្រុងធំៗដូចជាក្រុងព្រះសីហនុ និងកំពង់ចាមជា ដើម។ ព្រះរាជាណាចក្រកម្ពុជាកំពុងក្លាយជាកន្លែងមានភាពទាក់ទាញ និងងាយស្រួលសម្រាប់ភ្ញៀវទេសចរណ៍មក ទស្សនាជារៀងរាល់ថ្ងៃ ។

## ២.៥ ក្រុមប្រឹក្សា

រដ្ឋបាលរាជធានីមានក្រុមប្រឹក្សារាជធានីចំនួន ២៧រូប (ស្ត្រី ០៦រូប) មានគណៈអភិបាលរាជធានីចំនួន ០៧រូប (ស្ត្រី០១រូប) មាននាយករដ្ឋបាល ០១រូប នាយករងរដ្ឋបាល ០៧រូប (ស្ត្រី០២រូប) និងមានទីចាត់ការចំនួន ០៩ការិយាល័យចំនួន២៤[11] អង្គភាពច្រកចេញ-ចូលតែមួយអង្គភាពលទ្ធកម្មនិងការិយាល័យប្រជាពលរដ្ឋដែល

[9] អនុក្រឹត្យលេខ ០៣ អនក្រ.បក ស្តីពី ការបង្កើតខណ្ឌបឹងកេងកង នៃរាជធានីភ្នំពេញ ចុះថ្ងៃទី ៨ ខែមករា ឆ្នាំ២០១៩

[10] អនុក្រឹត្យលេខ ០៤ អនក្រ បក ស្តីពី.ការបង្កើតខណ្ឌកំបូល នៃរាជធានីភ្នំពេញ ចុះថ្ងៃទី ៨ ខែមករា ឆ្នាំ២០១៩

[11] របនាសម្ព័ន្ធក្រុមប្រឹក្សារាជធានីភ្នំពេញ

បានធ្វើសមាហរណកម្មរចនាសម្ព័ន្ធ និងមន្ត្រីរាជការបច្ចុប្បន្នចូលទៅក្នុងរចនាសម្ព័ន្ធថ្មីតាមច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ។ ធ្វើឱ្យមានប្រសិទ្ធភាពការងារនិងការផ្តល់សេវាសាធារណៈរបស់រដ្ឋបាលរាជធានីភ្នំពេញកាន់តែប្រសើរឡើង។

ក្រុមប្រឹក្សារាជធានីភ្នំពេញត្រូវមានដែនសមត្ថកិច្ចនៅក្នុងតំបន់ របស់ខ្លួន សម្រាប់បង្កើត ជំរុញ និងធ្វើឱ្យមានចីរភាពដល់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ។[12] ក្រុមប្រឹក្សារាជធានីភ្នំពេញត្រូវធ្វើប្រតិភូកម្មមុខងារ និងភារកិច្ចទៅឱ្យក្រុមប្រឹក្សាខណ្ឌ ក្រុមប្រឹក្សាសង្កាត់ ដើម្បីបង្កើត ជំរុញ និងធ្វើឱ្យមានចីរភាពដល់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ។[13]

## ២.៦ គណៈអភិបាល

គណៈអភិបាល គឺជាក្រុមអភិបាលដែលគ្រប់គ្រងដែនដីសមត្ថកិច្ចរបស់ខ្លួនដែលត្រូវបានតែងតាំងឡើងស្របតាមល័ក្ខខ័ណ្ឌនៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ។ យ៉ាងណាមិញរាជធានីភ្នំពេញមានមានគណៈអភិបាលមួយគឺ **ឯកឧត្តម ឃួង ស្រេង** ជាអភិបាលនៃគណៈអភិបាលរាជធានីភ្នំពេញ និងអភិបាលរងមួយចំនួន ដែលត្រូវបានតែងតាំងឡើង ស្របតាមល័ក្ខខ័ណ្ឌនៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ។

គណៈអភិបាល ត្រូវជ្រើសរើសពីក្នុងចំណោមមន្ត្រីទាំងពីរភេទដែលស្ថិតក្នុង ក្របខ័ណ្ឌមន្ត្រីរដ្ឋបាលជាន់ខ្ពស់ក្រសួងមហាផ្ទៃ ដែលមានលក្ខណសម្បត្តិដូចខាងក្រោម៖

- មានឋានន្តរសក្តិឧត្តមមន្ត្រី
- មានអាយុចាប់ពីសាមសិបប្រាំ តដល់ថ្ងៃតែងតាំង ិឆ្នាំឡើង គ(៣៥)
- មានបទពិសោធន៍ការងារផ្នែករដ្ឋបាលសាធារណៈយ៉ាងតិចចំនួនប្រាំពីរ )០៧និងមានសញ្ញាបត្រ/ឆ្នាំ ឬ( បរិញ្ញាបត្រដែលទទួលស្គាល់ដោយក្រសួងអប់រំ យុវជន និងកីឡា
- មានឈ្មោះក្នុងបញ្ជីឈ្មោះបោះឆ្នោតផ្លូវការក្នុងរយៈពេលនៃការតែងតាំង
- មិនធ្លាប់មានទោសឧក្រិដ្ឋ ឬ មជ្ឈិមណាមួយ។[14]

[12] ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលធានី ខេត្ត ក្រុង ស្រុក ខណ្ឌ មាត្រា១០៦

[13] ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលធានី ខេត្ត ក្រុង ស្រុក ខណ្ឌ មាត្រា ១០៨

[14] ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលធានី ខេត្ត ក្រុង ស្រុក ខណ្ឌ មាត្រា១៤០

## ១.៧ នាយករដ្ឋបាល

នាយករដ្ឋបាល មានតួនាទីជាជំនួយការក្នុងការចាត់ចែងកិច្ចការរដ្ឋបាល និងធានានិរន្តរភាពកិច្ចការរដ្ឋបាលប្រចាំថ្ងៃរបស់ក្រុមប្រឹក្សា និងគណៈអភិបាលរបស់ខ្លួន។ ក្នុងតួនាទីខាងលើនេះ នាយករដ្ឋបាលត្រូវធ្វើសេចក្ដីរាយការណ៍ និងមានគណនេយ្យភាព ចំពោះក្រុមប្រឹក្សា និងគណៈអភិបាលរបស់ខ្លួន។[15]

នាយករដ្ឋបាល មានតួនាទី ភារកិច្ចដូចខាងក្រោម :

- អនុវត្តកិច្ចការប្រចាំថ្ងៃរបស់ក្រុមប្រឹក្សា និងគណៈអភិបាល
- ធានាឱ្យអង្គភាព បុគ្គលិករបស់ក្រុមប្រឹក្សា អនុវត្តសេចក្ដីសម្រេចរបស់ក្រុមប្រឹក្សា និងគណៈអភិបាលរបស់ខ្លួន
- អនុវត្តដីការបស់ក្រុមប្រឹក្សា
- ចូលរួម និងមានយោបល់រាល់កិច្ចប្រជុំរបស់ក្រុមប្រឹក្សា គណៈកម្មាធិការរបស់ក្រុមប្រឹក្សា និងគណៈអភិបាល ប៉ុន្តែពុំមានសិទ្ធិបោះឆ្នោតបានឡើយ
- ផ្ដល់យោបល់ដល់ក្រុមប្រឹក្សា ដល់គណៈកម្មាធិការនានារបស់ក្រុមប្រឹក្សា ដើម្បីក្រុមប្រឹក្សាសម្រេចបាននូវគោលបំណងក្នុងការបង្កើត ការជំរុញ និងការធ្វើឱ្យមានចីរភាពដល់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ
- ផ្ដល់យោបល់ដល់គណៈអភិបាល ដើម្បីគណៈអភិបាលអនុវត្តមុខងារ និងភារកិច្ចរបស់ខ្លួនឱ្យមានប្រសិទ្ធភាព។[16]

## ១.៨ គណនេយ្យភាព

គណនេយ្យភាព មានន័យថាភាពទទួលខុសត្រូវ ភាពអាចគណនាបាន, ភាពអាចពន្យល់បាន។ នៅក្នុងន័យទូលាយ គណនេយ្យភាព គឺជាទស្សនៈមួយនៃក្រមសិលធម៌ និងអភិបាលកិច្ចដែលមានន័យទូលំទូលាយ និងអាចត្រូវ បានគេប្រើទាំងនៅក្នុងវិស័យសាធារណៈវិស័យឯកជន និងស៊ីវិល។

ក្នុងន័យគណនេយ្យភាពនេះគឺសំដៅទៅលើការទទួលស្គាល់ និងការទទួលខុសត្រូវចំពោះសកម្មភាពការសម្រេចចិត្ត និងគោលនយោបាយ ដែលបានអនុវត្តន៍ក្នុងតួនាទី ភារៈកិច្ច និងដែលសមត្ថកិច្ចរបស់ខ្លួន។

[15] ច្បាប់ស្ដីពីការគ្រប់គ្រងរដ្ឋបាលធានី ខេត្ត ក្រុង ស្រុក ខណ្ឌ មាត្រា ១៨៤

[16] ច្បាប់ស្ដីពីការគ្រប់គ្រងរដ្ឋបាលធានី ខេត្ត ក្រុង ស្រុក ខណ្ឌ មាត្រា ១៨៥

# ជំពូកទី២

# ស្ថានភាពទូទៅរបស់រាជធានីភ្នំពេញ

# ជំពូកទី២
# ស្ថានភាពទូទៅរបស់រាជធានីភ្នំពេញ

## ២.១ ស្ថានភាពសេដ្ឋកិច្ច

### ក.សេដ្ឋកិច្ច

រាជធានីភ្នំពេញ ស្ថិតនៅចំណុចប្រសព្វគ្នានៃ ទន្លេមេគង្គ ទន្លេបាសាក់ និង ទន្លេសាប។ ភ្នំពេញគឺជាទីក្រុងធំនៃប្រទេសកម្ពុជាហើយមានប្រជាជនជាងពីរលាននាក់កំពុងរស់នៅ។ សព្វថ្ងៃនេះប្រទេសកម្ពុជា មានការអភិវឌ្ឍសេដ្ឋកិច្ច មានល្បឿនយឺត ក្នុងការប្រកួតប្រជែងទីផ្សារក្នុងស្រុក និងប្រទេសនៅលើសកលលោកដែលមានសេដ្ឋកិច្ចខ្ពស់ គឺអាស្រ័យទៅលើរដ្ឋាភិបាលការបើកទ្វារអោយប្រទេសផ្សេងៗ មកធ្វើវិនិយោគទុនពង្រឹងនិងពង្រីកផលិតផលក្នុងស្រុក កាត់បន្ថយការនាំចូល និង បង្កើនការនាំចេញច្រើន។ ដើម្បីអភិវឌ្ឍន៍សេដ្ឋកិច្ច ក៏ដូចជារកការងារអោយប្រជាពលរដ្ឋរដ្ឋាភិបាលបានកែច្នៃកន្លែងផ្សេងៗអោយក្លាយទៅជាតំបន់ទេសចរណ៍ និងរកចំណូលបានតាមរយៈភ្ញៀវបរទេសដែលចូលមកទស្សនាប្រទេសកម្ពុជា។

ភ្នំពេញគឺជាមជ្ឈមណ្ឌលសេដ្ឋកិច្ចរបស់ប្រទេសកម្ពុជាដូចគ្នាដែរ វាក៏ត្រូវបានចាត់ទុកថាជាផ្នែកដ៏ធំនៃសេដ្ឋកិច្ចរបស់កម្ពុជា។ អត្រាកំណើនសេដ្ឋកិច្ច តួលេខបាន កើនឡើងទ្វេដងក្នុងប៉ុន្មានឆ្នាំថ្មីៗកន្លងផុតមកនេះដែលធ្វើឱ្យមានសន្ទុះឡើងនូវការលូតលាស់សេដ្ឋកិច្ចយ៉ាងឆាប់រហ័សនៅភ្នំពេញ ជាមួយនិង សណ្ឋាគារ ភោជនីយដ្ឋាន រង្គសាលថ្មីៗ ការផុសផុល និងការសាងសង់លំនៅឯកជនមានការរីកដុះដាលជាច្រើនឡើងជុំវិញទីក្រុង។

សេដ្ឋកិច្ចចំបងពឹងផ្អែកលើវិស័យពាណិជ្ជកម្មដូចជា កាត់ដេរ ពាណិជ្ជកម្ម និងបណ្តាសហគ្រាសធុនតូច និង មធ្យម។ ក្នុងរយៈពេលពីរបីឆ្នាំមុននេះ ធុរកិច្ចខាងអចលនទ្រព្យកំពុងបានរីកលូតលាស់យ៉ាងរហ័ស រួមនិងការកើនឡើងយ៉ាងរហ័សនូវតំលៃអចលនទ្រព្យ។ ទេសចរណ៍ ក៏ជាវិស័យរួមចំណែកមួយសំខាន់ក្នុងរាជធានីក៏ដូចជាការបើកមជ្ឈមណ្ឌលទិញឥវ៉ាន់ និង ពាណិជ្ជកម្មកាន់តែច្រើន ដែលធ្វើឱ្យភ្នំពេញ ក្លាយជាកន្លែងមួយក្នុងចំណោមគោលដៅទេសចរណ៍ដ៏សំខាន់ក្នុងប្រទេសនេះរួមជាមួយ សៀមរាប និង ព្រះសីហនុ។ តាមរយៈក្រុមប្រឹក្សាគមនាគារ និងទេសចរណ៍ពិភពលោក ទេសចរណ៍បានកើនឡើង ១៧,៥ភាគរយ (២ ០៥៣លានដុល្លារ) នៃផ.ផ.ស.របស់កម្ពុជានៅឆ្នាំ២០០៩ ឆ្លើយតបនឹង ១៣,៧ ភាគរយនៃការងារសរុប។ មួយក្នុងចំណោមនៃតំបន់ដែលមានប្រជាប្រិយបំផុតនៅភ្នំពេញសម្រាប់អ្នកទេសចរណ៍នៅតិរណៈវិថីស៊ីសុវត្ថិ តាមបណ្តោយទន្លេសាប។ មហាវិថីស៊ីសុវត្ថិជាផ្លូវមួយខ្សែដែលមានប្រវែងជិត ៥ គម សំបូរទៅដោយភោជនីយដ្ឋាន រង្គសាល និង សណ្ឋា-គារ។ ការអភិវឌ្ឍក្រុងថ្មី កាំកូស៊ីធី ក្នុងរង្វង់ទឹកប្រាក់ ២.៦ រយកោដិដុល្លារ បំណងគឺលើកកំពស់ទស្សនីយភាពទីក្រុង។ ការិយាល័យកិច្ចការក្រុងនៃរាជធានីភ្នំពេញមានផែនការច្រើនពង្រីក និងកសាងហេដ្ឋារចនាសម្ព័ន្ធថ្មី

ដើម្បីជួយសម្រួលទៅនឹងប្រជាជន និង សេដ្ឋកិច្ចកំពុងកើនឡើង។ អគារដើបឡើងខ្ពស់ៗនឹងត្រូវកសាងនៅចំណុចច្រកចូលនៃទីក្រុង និងក្បែរបឹងបួរនិងច្រាំងទន្លេ។ បន្ថែមទៀតនោះ ផ្លូវថ្មីៗ ប្រឡាយ និង ប្រព័ន្ធផ្លូវដែកនឹងត្រូវបានប្រើដើម្បីភ្ជាប់កាំកូស៊ីធីទៅនឹងរាជធានីភ្នំពេញ។ គម្រោងដទៃទៀតរួមមាន៖

- ហ្រ្វេនដ៍ភ្នំពេញអន្តរជាតិ
- សហបាលាគារដឺខាសសលរ៉ូយ៉ាល់
- សំណង់អគារហិរញ្ញវត្ថុអន្តរជាតិ
- ហ្គោលដ៍ថោវ៉រ ៤២ (ឈប់ត្រឹម៣២ជាន់)
- ថោវ៉រអូស៊ីអាយស៊ី (OCIC) (៣២ ជាន់)
- វីុជាឡេស
- វឌ្ឍនៈកាប់ពីថលថោវ៉រ (៣៨ ជាន់)
- ទីក្រុង អូឡាំព្យា
- មជ្ឈមណ្ឌលពាណិជ្ជកម្មភ្លោះ ថៃ ប៊ុនរ៉ុង

ជាមួយកំណើនសេដ្ឋកិច្ចផ្ទុះឡើងបានឃើញថាចាប់ផ្ដើមតាំងពីទសវត្សឆ្នាំ១៩៩០ ហាងថ្មីបានបើកសម្ពោធដូចគ្នានឹងម៉លបែបលោកខាងលិច ដូចជា ផ្សារទំនើបសូរិយា មជ្ឈមណ្ឌលសុវណ្ណា អ៊ីអនម៉ល ធីខេម៉ល ផាសិន ជាដើម។ សិទ្ធិប្រើយីហោអន្តរជាតិពីរក៏បានសម្ពោធឡើងនៅភ្នំពេញដែរ។ ដាយអារីឃ្វិន ក៏បានសម្ពោធឡើងរួចហើយនៅខាងក្នុងអាកាសយានដ្ឋានអន្តរជាតិភ្នំពេញ និង មាន់បំពងកេនទុកគី (KFC) បានសម្ពោធឡើងភោជនីដ្ឋានមួយលើដងមហាវិថីមុនីវង្ស និងមានផែនការបើកសម្ពោធបន្ថែមទៀតឆាប់ៗនេះ។ ក្រុមហ៊ុន QSR ដែលបានបើក KFC នៅកម្ពុជាដែលឥឡូវទទួលបានសិទ្ធិប្រើយីហោដើម្បីនាំភីហ្សាហាត់ មកប្រទេសនេះដែរ។ ក្រៅពីនោះ អាហារដ្ឋានការ៉េមស្វិនសឹន បានបើកសម្ពោធនៅមជ្ឈមណ្ឌលទិញឥវ៉ាន់សូរិយា។ ហាងកាហ្វេស្តារបាក់ បានបើកដំបូងនៅព្រលានអាកាសយានដ្ឋាននៅឆ្នាំ ២០១៥ ហើយឥលូវនេះមានចំនួន ៦ កន្លែងហើយ។

អគារកប់មេឃខ្ពស់បំផុតនៅភ្នំពេញគឺ ប៉មវឌ្ឍនៈកាប់ពីថល នៅកម្ពស់ ២០០ម៉ែត្រ ដែលលេចត្រដែតតាមជើងមេឃរបស់ភ្នំពេញជាមួយនឹងអគារកប់មេឃក្បែរខាង ប៉មកាណាឌីយ៉ា (ប៉មOCIC)។ ប៉មនេះត្រូវបានសាងសង់ឡើងនៅ ខែឧសភា ២០១២ និងបញ្ចប់បង្ហើយនៅចុងឆ្នាំ២០១៤។ ការដើបឡើងខ្ពស់ៗទំនើបៗត្រូវបានកសាងឡើងជុំវិញទីក្រុងនេះទាំងអស់ មិនមែនផ្តុំនៅតំបន់ពិសេសណាមួយឡើយ។

ផ្សារធំថ្មី គឺជាចំណុចក្ដៅរបស់ទេសចរណ៍ភាគច្រើន។ ស្លាបទាំងបួននៃផ្សារលាបពណ៌លឿងទុំ ពោរពេញទៅដោយរានជាច្រើនដែលលក់គ្រឿងអលង្ការមាស និង ប្រាក់ កាក់វត្ថុបុរាណ សម្លៀកបំពាក់ នាឡិកា ផ្កា ចំណី

អាហារ គ្រឿណាត់សំពត់ និង ស្បែកជើង។ ផ្សារថ្មីទទួលការកែប្រែសាជាថ្មីភាគច្រើន រួមជាមួយការបង្កើតរានលក់ដូរថ្មីៗ ក្រោមការយកចិត្តទុកដាក់ពី សាធារណរដ្ឋបារាំង។

**ខ.ទីផ្សារ**

សព្វថ្ងៃនេះទីផ្សារគឺមានការពេញនិយមយ៉ាងខ្លាំងចំពោះភ្ញៀវទេសចរណ៍កម្ពុជា ស្ទើរតែគ្រប់ភ្ញៀវទេសចរណ៍ទាំងអស់ដែលបានចូលមកទស្សនាទីក្រុងភ្នំពេញគឺពួកគេទាំងនោះចូលចិត្ត ទៅផ្សារ មើលភាពខុសប្លែកគ្នានៃផលិតផលដែលមានលក់នៅក្នុងផ្សារ។ ផ្សារធំថ្មីមានលក់ដូចជា មាស ប្រាក់ គ្រឿងអលង្ការ គ្រឿងចំលាក់ សម្លៀកបំពាក់ នាឡិកា ផ្កា អាហារ ស្បែកជើង។ល។ ដែលអាចទាក់ទាញភ្ញៀវគ្រប់ទិសទីទាំងជាតិ និងអន្តរជាតិ។

ផ្សារបច្ចុប្បន្ន៖ ផ្សារកណ្តាល|កណ្តាល ផ្សារកសិផលជ្រោយចង្វា ផ្សារកាណាឌីយ៉ា ផ្សារកាណាស៊ីធី ផ្សារកាប់គោ ផ្សារកំបូល ផ្សារកំពង់កន្ទួត ផ្សារកោះដាច់ ផ្សារដើមថ្កូវ ផ្សារក្រាំងពង្រ ផ្សារគីឡូម៉ែត្រលេខ៦ថ្មី ផ្សារគីឡូម៉ែត្រលេខ៧ ផ្សារគីឡូលេខ៤ ផ្សារឃ្លាំងរំសេវ ផ្សារចាក់អង្រែ ផ្សារចាស់ ផ្សារចុងព្រែក ផ្សារចោមចៅ ផ្សារចំការដូង ផ្សារច្បារអំពៅ ផ្សារច្រាំងចំរេះ ផ្សារឆេកូ ផ្សារជម្ពូវ័ន្ត ផ្សារជ័យជំនះ ផ្សារញ៉ែ ផ្សារដីហុយ ផ្សារដេប៉ូ ផ្សារដំបូលខៀវ ផ្សារដើមគ ផ្សារដើមអម្ពិល ផ្សារឌុយម៉ិច ផ្សារតាប៉ាង ផ្សារតូច ផ្សារតូចថ្មី ផ្សារតាង៉ូវថ្មី ផ្សារតាំងកសាងថ្មី ផ្សារត្រពាំងឈូក ផ្សារត្រពាំងថ្លឹង ផ្សារត្រពាំងពោធិ៍ ផ្សារត្រពាំងអញ្ចាញ ផ្សារទំនើបថៃហួត ផ្សារថ្នល់បត់បត ផ្សារទឹកថ្លា ផ្សារទួលកី ផ្សារទួលគោក ផ្សារទួលទំពូង ផ្សារទួលពង្រ ផ្សារទួលសង្កែថ្មី ផ្សារទួលសំបូរ ផ្សារទំនប់ ផ្សារទំនប់ថ្មី ផ្សារទ្រា ផ្សារធំថ្មី ផ្សារនាគមាស ផ្សារទំនើបបាយ័ន ផ្សារទំនើបប៉ារ៉ាហ្គន ផ្សារបឹងឈូក ផ្សារឈូកមាស ផ្សារបឹងកេងកង ផ្សារបឹងត្របែក ផ្សារទំនើបបឹងត្របែកផ្លាហ្សា ផ្សារបឹងប៉ាយ៉ាប ផ្សារបឹងទំពុន ផ្សារបឹងព្រលិត ផ្សារបឹងសាឡាងថ្មី ផ្សារប៊ុណ្ណាផ្លាហ្សា ផ្សារបុរីចោមចៅ ផ្សារបុរីតាំងកសាង ផ្សារបុរីពិភពថ្មី ផ្សារប៉េសេ ផ្សារទំនើបផាករ៉េ ផ្សារទំនើបផេនសល (ចតុមុខ) ផ្សារទំនើបផេនសល(បឹងកក) ផ្សារទំនើបផេនសល(មាត់ទន្លេ) ផ្សារពោធិ៍ចិនតុង ផ្សារព្រែកព្នៅ ផ្សារព្រែកព្នៅផ្លាហ្សា ផ្សារព្រែកលៀប ផ្សារព្រែកលៀបថ្មី ផ្សារព្រែកឯង ផ្សារព្រែទា ផ្សារភូមិអណ្តូង ផ្សារមាន់អាំង ផ្សាររតនាផ្លាហ្សា ផ្សាររន្ទះបាញ់ ផ្សាររាត្រី ផ្សារលឹមឈាងហាក់ ផ្សារលូប្រាំ ផ្សារទំនើបវៀតណាម ផ្សារសឡា ផ្សាររីករាយ ផ្សារសហគមន៍បុរីកីឡា ផ្សារសាមគ្គី ផ្សារសាមគ្គីថ្មី ផ្សារសារឿន-យ៉ាន្នី ផ្សារសិនជូផ្លាហ្សា ផ្សារស៊ីធីម៉ល ផ្សារស៊ីឡឹប ផ្សារកុងទីន័រ ផ្សារទំនើបសុវណ្ណា ផ្សារទំនើបសូរិយា អ៊ីអនម៉ល១ អ៊ីអនម៉ល២ ផ្សារសែនមនោរម្យ ផ្សារសែនសុខ ផ្សារសំណង់១២ ផ្សារសំពៅមាស ស្តង់បុរីកីឡា ផ្សារទំនើបស្ទឹងមានជ័យថ្មី ផ្សារស្វាយប៉ាក ផ្សារហេងប៉េងជ្រី ផ្សារហេងលី ផ្សារហេងលីថ្មី ហ្គោលឌិនសូរិយាម៉ល ផ្សារទំនើប

ឡាក់គីផ្សារឡាក់ស៊ីធី ផ្សារអូរបែកក្អម ផ្សារអូរឫស្សី ផ្សារអូឡាំពិក ផ្សារឯករាជ្យ១ ផ្សារឯករាជ្យ២ ផ្សារឯករាជ្យ៣ ផ្សារ៧មករា...។[17]

**តារាង៖ ផ្សារក្នុងរាជធានីភ្នំពេញ**

| ល.រ | បរិយាកាស | ចំនួន |
|---|---|---|
| ១ | ផ្សាររដ្ឋ | ២៣ ផ្សារ |
| ២ | ផ្សារឯកជន | ៨១ ផ្សារ |
| ៣ | ផ្សារមីនីម៉ាត | ២៣៥ ផ្សារ |
| ៤ | ផ្សារក្រៅការចាត់តាំង ( ផ្សារមិនរៀបរយ ) | ២២ ផ្សារ |
| ៥ | ផ្សារទំនើប | ៣៥ ផ្សារ |
| **សរុប** | | ៣៩៦ ផ្សារ |

## ២.១.១ សភាពទីក្រុង និង ស្ថាបត្យកម្ម

កន្លែងដែលទាក់ទាញភ្ញៀវទេសចរណ៍នៅទីក្រុងភ្នំពេញរួមមាន ព្រះបរមរាជវាំង ផ្សារធំថ្មី ព្រះវិហារព្រះកែវមរកត សារមន្ទីរជាតិ វិមានឯករាជ្យ វិមានមិត្តភាពកម្ពុជា-វៀតណាម សារមន្ទីរទួលស្លែង វត្តភ្នំ និង វាលពិឃាតជើងឯកនៅជាយក្រុងភ្នំពេញ។

ព្រះបរមរាជវាំងគឺជាអគារមួយក្នុងចំណោមអគារជាច្រើនដែលស្ថិតនៅក្នុងព្រះរាជាណាចក្រកម្ពុជា។ ព្រះបរមរាជវាំងចតុមុខ ត្រូវបានសាងសង់ឡើងដោយ ព្រះចៅក្រុងកម្ពុជា នៅក្នុងឆ្នាំ ១៨៦៦។ ព្រះបរមរាជវាំងត្រូវបានរុះរើសាងសង់សាជាថ្មីដោយព្រះបាទនរោត្តម។

វត្តភ្នំគឺជាវត្តប្រវត្តិសាស្ត្រមួយដ៏មានសារៈសំខាន់ដែលមានទីតាំងនៅក្នុងរាជធានីភ្នំពេញ។ កសាងនៅក្នុងឆ្នាំ១៣៧៣ មានកំពស់២៧ម៉ែត្រ ជាវត្តខ្ពស់ជាងគេក្នុងចំណោមវត្តទាំងប៉ុន្មាននៅក្នុងទីក្រុងភ្នំពេញ។ វាបានសាងសង់ឡើងដោយកម្លាំងសាមគ្គីដែលដឹកនាំដោយស្ត្រីមេម៉ាយដែលមានទ្រព្យស្តុកស្តម្ភម្នាក់ គឺ ដូនជីពេញ ដើម្បីតម្កល់ព្រះពុទ្ធរូប៥អង្គ ដែលត្រូវបានទឹកជំនន់ហូរនាំមកតាមដើមគគីរធំមួយ មកទើរនៅត្រង់តំបន់ចតុមុខនេះឯង។

[17] របាយការណ៍ https://km.wikipedia.org/wiki/%E1%9E%97%E1%9F%92%E1%9E%93%E1%9F%86%E1%9E%96%E1%9F%81%E1%9E%89

សំណង់ចាស់បំផុតគឺវត្តភ្នំចាប់ពីថ្ងៃស្ថាបនាក្រុងនេះ ដែលបានសាងសង់នៅឆ្នាំ ១៣៧៣។ ការទាក់ទាញទេសចរណ៍សំខាន់បំផុតគឺព្រះបរមរាជវាំងដែលមានព្រះវិហារព្រះកែវ និងសារមន្ទីរជាតិបានសាងសង់នៅកំឡុងសម័យអាណានិគមបារាំងនៅចុងសតវត្សទី១៩ក្នុងរចនាបថខ្មែរបុរាណ ហើយទទួលនូវការប្រមូលផ្តុំវត្ថុបុរាណខ្មែរជាច្រើន។ វិមានឯករាជ្យ ទោះបីចាប់ពីទសវត្សឆ្នាំ១៩៥០ក៏ដោយ ក៏វាត្រូវបានសាងសង់ឡើងក្នុងរចនាបថខ្មែរបុរាណដដែល។

ពួកបារាំង ដែលជាម្ចាស់អាណានិគមចាប់ពីសតវត្សទី ១៩ ដល់ ទសវត្សឆ្នាំ ១៩៤០ ក៏បានបន្សល់ទុកទីសំគាល់ខ្លួនរបស់ពួកគេ ជាមួយភូមិគ្រឹះអាណានិគមផ្សេងៗ ព្រះវិហារបារាំង មហាវិថី និង ផ្សារសិល្បៈតែង ផ្សារធំថ្មី។ ទីសំគាល់ដែននៃសម័យអាណានិគមគឺសណ្ឋាគារឡឺរ៉ូយ៉ាល់។

ចាប់ផ្តើមជាមួយឯករាជ្យពីពួកបារាំងនៅទសវត្សឆ្នាំ ១៩៥០ និង បន្តរហូតដល់សម័យខ្មែរក្រហមនៅទសវត្សឆ្នាំ ១៩៧០ ភ្នំពេញបានរងនូវការលូតលាស់យ៉ាងសម្បើមជាទីក្រុងធានីនៃប្រទេសឯករាជ្យថ្មីមួយ។ ព្រះបាទសីហនុបានយកចិត្តទុកដាក់ដើម្បីបង្ហាញរចនាបថថ្មីនៃស្ថាបត្យកម្ម និងដោយហេតុធ្វើឱ្យរឹងមាំនូវដំណើរការកសាងជាតិ។ យុគសម័យនៃស្ថាបត្យកម្មថ្មីបានបញ្ចប់ រួមជាមួយនិងគម្រោងផ្សេងៗនិង ស្ថាបត្យករខ្មែរវ័យក្មេង ជារឿយៗបានរៀនសូត្រនៅបារាំង ដែលមានឱកាសដើម្បីរចនានិងសាងសង់។

ចលនាថ្មីនេះត្រូវបានគេហៅថា ស្ថាបត្យកម្មខ្មែរថ្មី និង ជារឿយៗត្រូវបានធ្វើឱ្យមានចរិកលក្ខណៈដោយសារការរំលាយចូលគ្នានៃប៉ោហូស ស្ថាបត្យកម្មក្រោយសម័យទំនើបអឺរ៉ុប និង ធាតុបុរាណពីសម័យអង្គរ។ ស្ថាបត្យករដែលលេចធ្លោបំផុតគឺលោកវណ្ណ-ម៉ូលីវណ្ណ ដែលត្រូវបានតែងតាំងជាប្រធាស្ថាបត្យករជាតិដោយព្រះមហាក្សត្រផ្ទាល់នៅឆ្នាំ១៩៥៦។

លោកម៉ូលីវណ្ណបានបង្កើតអគារទីសំគាល់ដែនដូចជារោងមហោស្រពជាតិព្រះសុរាម្រិត និង អគារគណៈរដ្ឋមន្ត្រី។ ស្ថាបត្យករដទៃៗទៀតបានជួយសាងសង់សាកលវិទ្យាល័យភូមិន្ទដែលស្ថាបនាថ្មី វិទ្យាស្ថានភាសាបរទេស និង មជ្ឈមណ្ឌលកីឡាជាតិ។ រួមជាមួយកំណើននៃថ្នាក់លើនិងកណ្តាលរបស់សហគ្រិន ជាយក្រុងថ្មីៗត្រូវបានសាងសង់នៅទសវត្សឆ្នាំ ១៩៥០ និង ៦០។

ទោះបីជាសំណង់អគារទាំងនោះបាននៅសេសសល់នៅសម័យខ្មែរក្រហម និងសម័យសង្គ្រាមរដ្ឋប្បវេណីក៏ដោយ ក៏បច្ចុប្បន្ននេះ អគារទាំងនោះស្ថិតនៅក្រោមការគំរាមកំហែង ដោយសារតែការអភិវឌ្ឍខាងសេដ្ឋកិច្ចនិងបរិកប្បហិរញ្ញវត្ថុដដែល។ ភូមិគ្រឹះ និង សួនច្បារពីសម័យនោះកំពុងត្រូវបានបំផ្លាញ និង អភិវឌ្ឍន៍ឡើងវិញដើម្បីបង្កើតកន្លែងសម្រាប់សំណង់ធំៗ។ ទីសំគាល់ដែន មហោស្រពជាតិដោយលោកម៉ូលីវណ្ណត្រូវបានវាយរំលំនៅឆ្នាំ ២០០៨។ ចលនាមួយកំពុងងើបឡើងនៅកម្ពុជាដើម្បីថែរក្សាឱ្យគង់វង្សនូវកេរដំណែលសម័យនិយមនេះ។ ភូមិគ្រឹះចាស់ៗជួនកាលកំពុងត្រូវបានគេប្រែទៅជាសណ្ឋាគារហាង ដូចជា ខ្មែរបាំងឆ័ត្រ។

វិមាននិងទីរំលឹកដល់ការប្រល័យពូជសាសន៍កំឡុងសម័យខ្មែរក្រហមនៅទសវត្សឆ្នាំ ១៩៧០ គឺសារមន្ទីរប្រល័យពូជសាសន៍ទួលស្លែង (អតីតវិទ្យាល័យមួយបានប្រើជាជំរុំប្រមូលផ្តុំ) និងនៅជាយក្រុងនៃទីក្រុងនេះមជ្ឈមណ្ឌលប្រល័យពូជសាសន៍ជើងឯក។ វិមានមិត្តភាពកម្ពុជា-វៀតណាមត្រូវបានប្រគល់ឱ្យដោយពួកកុម្មុយនិស្តវៀតណាម ជានិមិត្តរូបនៃមិត្តភាពខ្មែរ-យួនកំឡុងទសវត្សឆ្នាំ១៩៧០ ដែលបន្តបន្ទាប់ពីការរំដោះកម្ពុជាពីរបបខ្មែរក្រហម។

### ២.១.២ ឧស្សាហកម្ម និងសិប្បកម្ម

មន្ទីឧស្សាហកម្ម និងសប្បកម្មរាជធានីភ្នំពេញ គឺជាសេនាធិការជំនាញស្ថិតនៅក្រោមឱវាទក្រសួងឧស្សាហកម្ម និងសិប្បកម្ម ដែលមានតួនាទីចូលរួមជំរុញការអភិវឌ្ឍន៍វិស័យឧស្សហកម្ម សហគ្រាសធុនតូចមធ្យម និងសិប្បកម្ម (SME) រួមទាំងស្តង់ដារនិងមាត្រាសាស្ត្រនៅទូទាំងរាជធានីភ្នំពេញ ដោយចូលរួមអនុវត្តយ៉ាងសកម្មនូវគោលនយោបាយអភិវឌ្ឍន៍ឧស្សាហកម្មកម្ពុជាឆ្នាំ២០១៥-២០២៥ និងទិសដៅយុទ្ធសាស្ត្ររបស់ក្រសួងឧស្សហកម្ម និងសិប្បកម្ម។[18] យើងដឹងហើយថា ឧស្សហកម្ម ជាវិស័យមួយដែលជាសសរទ្រូង និងឆ្អឹងខ្នងនៃសេដ្ឋកិច្ចប្រទេសកម្ពុជា និងបង្កើតបានការងារជាច្រើនជូនប្រជាពលរដ្ឋ។ ក្នុងន័យនេះមន្ទីឧស្សហកម្ម និងសិប្បកម្មរាជធានីភ្នំពេញបានខិត ខំប្រឹងប្រែងជំរុញការអភិវឌ្ឍ វិស័យឧស្សហកម្មសហគ្រាសធុនតូច មធ្យមនិងសិប្បកម្មឱ្យក្លាយជាកម្លាំងចលករ មួយយ៉ាងសំខាន់ក្នុងការជំរុញកំណើនសេដ្ឋកិច្ច និងសង្គមជាតិតាមរយៈការបង្កើតឱកាសការងារស្របច្បាប់ និងបង្កើតប្រាក់ចំនូលរបស់ប្រជាជន ស្របតាមខ្លឹមសារយុទ្ធសាស្ត្រចតុកោណដំណាក់ការទី៤ ក្នុងអាណត្តិទី៦ របស់រាជរដ្ឋាភិបាលកម្ពុជា (២០១៨-២០២៣)[19] គឺដើម្បីសម្រេចឱ្យបាននូវកំណើនសេដ្ឋកិច្ចខ្ពស់ប្រកដដោយចីរភាព ពង្រឹងនីវការប្រកួតប្រជែង និងផលិតភាពក្នុងគោលដៅបង្កើតការងារកាត់បន្ថយភាពក្រីក្រ និងលើកកម្ពស់កម្រិតជីវភាពរបស់ប្រជាពលរដ្ឋដែលជាអន្តរកាលឆ្ពោះទៅសម្រេចឋានៈប្រទេសមានចំនូលមធ្យមកំរិតខ្ពស់នៅឆ្នាំ២០២០ បើគិតមកត្រឹមត្រីមាសទី៣ ឆ្នាំ២០១៩នេះទៅទូទាំងរាជធានីភ្នំពេញមាន៖

- ❖ រោងចក្រវិនិយោគ
- • មានចំនួន៧៣២រោងចក្រ។
- • ពលកម្មសរុបមានចំនួន៤៣៧,៨៦១នាក់។
- ❖ ឧស្សាហកម្មតូចនិងសិប្បកម្ម
- • ចំនួន៤,៤៦៨ មូលដ្ឋានក្នុងនោះមាន៖ក្រសួង៦៦៤មន្ទី៣,៦៦៦ និងអត់ច្បាប់១២៨។

[18] គោលនយោបាយអភិវឌ្ឍន៍ឧស្សាហកម្មកម្ពុជាឆ្នាំ២០១៥-២០២៥

[19] យុទ្ធសាស្ត្រចតុកោណដំណាក់ការទី៤

- ចំនួនពលកម្មសរុប៨០,៥១៩នាក់ ក្នុងនោះស្រី៤៦,៨៨៣នាក់។
- តម្លៃបរិមាណផលិតផលសរុប៤៤,០៦៥ លានរៀល។ [20]

### ១.១.៣ រ៉ែ និងថាមពល

រាជធានីភ្នំពេញមានការរីកចម្រើនលើគ្រប់វិស័យ ក្នុងនោះមានវិស័យរ៉ែ និងថាមពលដែលទាមទារនូវការគ្រប់គ្រង អនុវត្តច្បាប់ឱ្យមានសុវត្ថិភាពល្អ បរិស្ថានល្អដូចជា៖ ការគ្រប់គ្រងការជីករណ្ដៅដី អាជីវកម្មបូមខ្សាច់ ជីកអាចម៍ដី ដេប៉ូលក់ ស្តុកខ្សាច់ ស្ថានីយប្រេងឥន្ធនៈ ទីតាំងលក់ ស្តុកហ្គាស ឧស្ម័ន ដែលជាតម្រូវការចាំបាច់របស់ប្រជាពលរដ្ឋក្នុងរាជធានីភ្នំពេញ។

- **បញ្ហាប្រឈម**
  - ម្ចាស់ស្ថានីយប្រេងឥន្ធនៈម្ចាស់អាជីវកម្មលក់ ស្តុកហ្គាស ឧស្ម័នខ្លះមិនសហការល្អជាមួយមន្ទីជំនាញ
  - ការដឹកជញ្ជូនអាចម៍ដី ខ្សាច់មិនទាន់មានលក្ខណៈបច្ចេកទេសត្រឹមត្រូវតាមការកំណត់របស់ក្រសួង បង្កឱ្យប៉ះពាល់ដល់បរិស្ថាន។
  - ចំណេះដឹងរបស់ម្ចាស់អាជីវកម្មនៅមានកម្រិត។
  - ខ្វះមន្ត្រីបម្រើការងារក្នុងអង្គភាព។
- **ដំណោះស្រាយ**
  - សហការជាមួយអាជ្ញធរដែនដីដើម្បីជំរុញឱ្យម្ចាស់ស្ថានីយប្រេងឥន្ធនៈនិងម្ចាស់អាជីវកម្មលក់ស្តុកហ្គាស ឧស្ម័នសុំច្បាប់ធ្វើអាជីវកម្ម។
  - សហការជាមួយអជ្ញាធរដែនដីដើម្បីអនុវត្តតាមខ្លឹមសារ សារាចរណ៍លេខ ០៣១០ រថ អ ធរ សរច របស់ ក្រសួងរ៉ែ និងថាមពល។[21]
  - បន្តផ្សព្វផ្សាយច្បាប់ស្តីពីការគ្រប់គ្រងប្រេងកាត និងផលិតផលប្រេងកាត។
  - ស្នើសុំក្របខណ្ឌបន្ថែម។

### ១.១.៤ គមនាគមន៍

គមនាគមន៍បានបំពេញតួនាទីយ៉ាងខ្លាំង ក្នុងការជួយជំរុញវិស័យនានាឱ្យរីកចម្រើនក្រៅពីជួយសម្រួលផ្នែកចរាចរណ៍សម្រាប់ប្រជាពលរដ្ឋ ក្នុងរាជធានីជាពិសេសក៏បានរួមចំណែកដល់ការទាក់ទាញវិស័យទេសចរ-ណ៍ផងដែរ។ ក្នុងការអនុវត្តកន្លងមករាជធានីមានផ្លូវសំខាន់ៗដូចខាងក្រោម៖

---

[20] របាយការណ៍កម្មវិធីវិនិយោគបីឆ្នាំរំកិលរាជធានីភ្នំពេញ

[21] សារាចរណ៍លេខ ០៣១០ រថ អ ធរ សរច របស់ ក្រសួងរ៉ែ និងថាមពល

| ថ្នាក់គ្រប់គ្រង | ផ្លូវអ៊ុតកៅស៊ូ | ផ្លូវស្រោចកៅស៊ូ | ផ្លូវចាក់បេតុង | ផ្លូវគ្រួសក្រហម | ផ្លូវដី |
|---|---|---|---|---|---|
| រាជធានីភ្នំពេញ | ៥,៤៦៧,៨៧៥ | ៤៩,៦៥៣ | ២,០៧១,៣៧៥ | | |
| ខណ្ឌ | ៣០៤,៣១៥ | ១៤៤,៥៣៩ | ៥៥,៩៦៦ | ៣២,៤៥០ | ៥១,៧៥០ |
| សង្កាត់ | ៥៩៨,៥៧៥ | ៥៥,២៦៥ | ៧១៥,១៣៥ | ៣១៥,២៩៥ | ៤១២,៦៩០ |
| សរុប | ៦,៣៧០,៧៦៥ | ២៤៩,៤៥៧ | ២,៨៤២,៤៧៦ | ៣៨៦,៧៤៥ | ៤៦៤,៤៤០ |

- **បញ្ហាប្រឈមលើកិច្ចដំណើរការ និងថែទាំ**

ដោយសារការសាងសង់ និងជួសជុសផ្លូវកន្លងមក មានអ្នកអនុវត្តមួយចំនួនតូចពុំទាន់អនុវត្តបានតាមបទដ្ឋានបច្ចេកទេសឱ្យបានពេញលេញ និងយន្តការត្រួតពិនិត្យនៅមានកម្រិត ដែលជាហេតុធ្វើឱ្យផ្លូវមួយចំនួនប្រឈមមុខនឹងភ្លៀងធ្លាក់ខ្លាំង ទឹកជន់លិចផ្លូវជាច្រើនក៏ជាមូលហេតុធ្វើឱ្យផ្លូវងាយទទួលរងនូវការខូចខាត។ របាយការណ៍សម្មភាពចំពោះការជួសជុលផ្លូវគមនាគមន៍ទូទាំងរាជធានីភ្នំពេញមាននៅក្នុងឧបសម្ព័ន្ធ។

### ១.១.៥ សេវាកម្ម

បច្ចុប្បន្ននេះសេវាកម្មគឺជាកម្លាំងចលករមួយយ៉ាងសំខាន់ ក្នុងការរួមចំណែកពន្លឿនផ្នែកសេដ្ឋកិច្ចជាពិសេសបានផ្តល់ប្រយោជន៍ជាច្រើនដល់ផ្នែកពាណិជ្ជកម្មដូចជាការផ្តល់សេវាទំនិញធំ (រថយន្តដឹកកុងទីន័រ) និងរថយន្តក្រុងក៏ជា មធ្យោបាយដឹកជញ្ជូនសាធារណៈដ៏មានប្រសិទ្ធភាពមានតម្លៃថាក និងបានជួយជំរុញសេវាកម្មទេសចរណ៍ឱ្យកាន់ តែរីកចម្រើន។ ក្រៅពីនេះក៏មានសេវាកម្មសំខាន់ៗមួយចំនួនទៀតដូចជាការផ្គត់ផ្គង់ទឹកស្អាត អគ្គីសនីសេវាកម្មទេសចរណ៍ និងសេវាកម្មផ្សេងៗទៀតជាច្រើន។

### ក. ការផ្គត់ផ្គង់ទឹកស្អាត

ដើម្បីបំពេញទៅនឹងសេចក្តីត្រូវការរបស់អតិថិជនដែលចេះតែកើនឡើង ពីមួយថ្ងៃទៅមួយថ្ងៃឥតឈប់ឈររដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញបាននឹងកំពុងផលិតទឹកស្អាតប្រមាណ ២២១,៥០៩,២១៤ម$^3$/ឆ្នាំ ឬ ប្រហែល ៦០៦,៨៧៤ម$^3$/ថ្ងៃ និងមានអតិថិជនសរុបចំនួន៨៨,៨៨៣ បណ្តាញនៅឆ្នាំ២០១៩។[22]

### ខ. ការផ្គត់ផ្គង់អគ្គិសនី

ការផ្គត់ផ្គង់អគ្គិសនីក្នុងរាជធានីភ្នំពេញអំឡុងឆ្នាំ២០១៨ កន្លងមកមានការកើនឡើងយ៉ាងខ្លាំងដែលជាភស្តុតាងបញ្ជាក់ពីកំណើនសេដ្ឋកិច្ចរបស់ប្រជាពលរដ្ឋកម្ពុជា។ នៅឆ្នាំ២០១៨ អានុភាពអតិបរិមាក្នុងរាជធានី

[22] របាយការណ៍ធនធានទឹក

ភ្នំពេញមានប្រមាណ ៨៨៧ MW និងថាមពលលក់ប្រមាណ៨,៦៧៥,១៦៦,៦៥៤ GWh ដែលបានផ្គត់ផ្គង់ជូនអតិថិជន គ្រប់ប្រភេទចំនួន៦៩៥,៧៧០។ [23] តាមទិន្នន័យឆ្នាំ២០១៨របស់អគ្គិសនីកម្ពុជាចំនួនអតិថិជនតាមប្រភេទមាន៖

- **បញ្ហាប្រឈម**
  - នៅក្នុងគម្រោងពង្រីកផ្លូវនានា កន្លងមកពុំមានការកំណត់ទីតាំងដាំបង្គោលអគ្គិសនីឱ្យបានច្បាស់លាស់ (គិតពីអ័ក្សផ្លូវ) ធ្វើឱ្យការអនុវត្តគម្រោងមានភាពប្រទាំងប្រទើសជាមួយប្រជាពលរដ្ឋ បង្កឱ្យមានការយឺតយ៉ាវ និងធ្វើឱ្យប្រព័ន្ធបណ្តាញអគ្គិសនីដែលបានរុះរើរួចគ្មានសោភ័ណ្ឌភាព និងសុវត្ថិភាព។
  - ដោយសារចញ្ចើមផ្លូវបច្ចុប្បន្នមានទទឹងខ្លី និងមានបង្គោលហេដ្ឋរចនាសម្ព័ន្ធក្រោមដីសម្រាប់បម្រើសេវាសាធារណៈស្មុគស្មាញៈបង្កការលំបាកក្នុងការអនុវត្តជីកកប់កាបក្នុងគម្រោងថ្មី។
  - កំណើនតម្រូវការអគ្គិសនីឆ្លុះបញ្ចាំងឱ្យឃើញនូវកំណើនសេដ្ឋកិច្ចកម្ពុជា។ បច្ចុប្បន្ននៅក្នុងរាជធានីភ្នំពេញមានការសាងសងសំណងអាគារខ្ពស់ៗ និងផ្ទះល្វែងជាច្រើន ធ្វើឱ្យត្រង់ស្វូចែកចាយអគ្គិសនីដែលមានស្រាប់ទទួលរងនូវការដើរលើសបន្ទុកស្ទើគ្រប់ទីកន្លែង និងមានការលំបាកក្នុងការស្វែងរកទីតាំងថ្មីដើម្បីតម្លើងត្រង់ស្វូរ ប្រព័ន្ធខ្សែបណ្តាញ ដើម្បីចែកចាយអគ្គិសនីឱ្យបានសមស្របតាមកំណើននសតម្រូវការរបស់ប្រជាពលរដ្ឋ។
- **សំណូមពរ**
  - សំណូមពរឱ្យមានទីតាំងដាំ(គិតពីអ័ក្សផ្លូវ) បង្គោលអគ្គិសនីឱ្យបានច្បាស់លាស់និងដំណោះស្រាយផលប៉ះពាល់ឱ្យបានចប់សព្វគ្រប់ជាមុន ទើបអគ្គិសនីកម្ពុជាចុះរុះរើប្រព័ន្ធបណ្តាញអគ្គិសនីរបស់ខ្លួនតាមក្រោយដើម្បីតាមក្រោយដើម្បីធានាបាននូវសោភ័ណ្ឌភាព និងសុវត្ថិភាព។
  - ស្នើសុំឱ្យមានការរៀបចំ "គន្លងបច្ចេកទេស" ដោយកំណត់ទីតាំងច្បាស់លាស់គិតពីរបងផ្ទះប្រជាពលរដ្ឋទៅតាមលំដាប់នៃហេដ្ឋរចនាសម្ព័ន្ធដែលបម្រើសេវាសាធារណៈបង្កប់ក្នុងដី។
  - ស្នើសុំរដ្ឋបាលរាជធានីជួយសម្រួលផ្តល់ទីតាំងតម្លើងត្រង់ស្វូរលើចិញ្ចើមផ្លូវសាធារណៈឬក៏ទីសាធារណៈមួយចំនួនផ្សេងទៀត ដើម្បីឆ្លើយតបនឹងសេចក្តីត្រូវការថាមពលពីប្រជាពលរដ្ឋក៏ដូចជាស្នើសុំពីអគ្គិសនីកម្ពុជា។

[23] របាយការណ៍អគ្គិសនីកម្ពុជា

### ២.១.៦ ទេសចរណ៍

បច្ចុប្បន្នវិស័យទេសចរណ៍ បានដើរតួនាទីយ៉ាងសំខាន់ក្នុងសេដ្ឋកិច្ចសង្គម ដែលប្រទេសជាច្រើននៅក្នុងពិភពលោកកំពុងយកចិត្តទុកដាក់យ៉ាងខ្លាំង ដោយសារវិស័យនេះបាននាំមកនូវរូបិយប័ណ្ណអន្តរជាតិជួយជំរុញកំណើនផលិតផលក្នុងស្រុកសរុប (GDP) បង្កើតការងារនិងប្រាក់ចំណូលដល់ប្រជាពលរដ្ឋលើកកម្ពស់និងថែរក្សាបរិស្ថានធម្មជាតិនិងវប្បធម៌ការបង្កើននូវកិច្ចសហការអន្តរជាតិក៏ដូចជាការនាំមកនូវសន្តិភាពជាដើម។ ជាក់ស្តែងក្នុងឆ្នាំ២០១៨ ភ្ញៀវទេសចរណ៍អន្តរជាតិចូលមកទស្សនា កម្ពុជាមានចំនួន ៦.២លាននាក់ ក្នុងអត្រាកំណើន ១០.៧% និងប្រាក់ចំណូលប្រមាណ ៤.៣៧៣លាន ដុល្លារអាមេរិកចាក់បញ្ចូលក្នុងសេដ្ឋកិច្ចជាតិ រួមចំណែកប្រមាណ ១២% នៃផលិតផលក្នុងស្រុកសរុប និងបង្កើនការងារដល់ប្រជាពលរដ្ឋដោយផ្ទាល់ប្រមាណជាង៦២០០០នាក់។ ក្នុងការព្យាករណ៍កម្ពុជានឹងទទួលភ្ញៀវទេសចរណ៍អន្តរជាតិចំនួនប្រមាណ៧លាននាក់ នៅឆ្នាំ២០២០ នាំមកនូវចំណូលសរុបប្រមាណ៥,០០០លានដុល្លាអាមេរិក និងបង្កើតនូវឱកាសការងារប្រមាណពីរលានកន្លែង។ ដោយសារសារៈសំខានខាងលើនេះ ការអភិវឌ្ឍវិស័យទេសចរណ៍ត្រូវបានកំណត់នៅក្នុងយុទ្ធសាស្ត្រចតុកោណ របស់រាជរដ្ឋាភិបាល គឺជាវិស័យអាទិភាពមួយក្នុងចំណោមវិស័យអាទិភាពទាំង១០នៅក្នុងការកសាងនិងជំរុញកំណើនសេដ្ឋកិច្ចជាតិ។[24] ទន្ទឹមនេះដោយសាររាជធានីភ្នំពេញ គឺជាមជ្ឈមណ្ឌលសេដ្ឋកិច្ចនយោបាយវប្បធម៌ ទេសចរណ៍ ការទូត និងមានសក្តានុពលធំធេងនៃផ្នែកធនធានវប្បធម៌ និងប្រវត្តិសាស្ត្រ មានហេដ្ឋរចនាសម្ព័ន្ធល្អប្រសើរ និងមានតំនប់ទាក់ទាញទេសចរណ៍ជាច្រើនទៀតរាជរដ្ឋាភិបាលបានកំណត់ជាប៉ូលមួយក្នុងចមណោមប៉ូលអាទិភាពទាំងបួននៅក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ទេសចរណ៍ជាតិ ដើម្បីទាក់ទាញភ្ញៀវទេសចរណ៍ឱ្យចូលមកទស្សនាកម្សាន្ត និងលម្ហែក៏ដូចជាការប្រកួតប្រជែងក្នុងគោលដៅទីផ្សារនៅក្នុងតំបន់ផងដែរ។

កំណើនទសចរណ៍ជាតិចូលមករាជធានីភ្នំពេញប្រចាំឆ្នាំជាមធ្យម មានប្រមាណ១២% ម្យាងវិញទៀតវិស័យទេសចរណ៍មានលក្ខណៈជាប្រព័ន្ធដោយពាក់ព័ន្ធទៅនឹងស្ថាប័ន និងផ្នែកផ្សេងៗជាច្រើននៅក្នុងផ្នែកវប្បធម៌ និងសេដ្ឋកិច្ចសង្គមដែលទាមទារឱ្យមានការគាំទ្រនិងកិច្ចសហប្រតិបត្តិការល្អហេតុនេះការធ្វើផែនការអភិវឌ្ឍនិងគ្រប់គ្រងទេសចរណ៍រាជធានីភ្នំពេញ ពិតជាមានសារៈសំខាន់ចាំបាច់ត្រូវធ្វើឱ្យបានត្រឹមត្រូវជាពីសេសការលើកគម្រោងថវិកាកម្មវិធីវិនិយោគបីឆ្នាំរំកិល២០២០-២០២២ ឱ្យបានសមស្របទៅនឹងគម្រោងផែនការអាទិភាពសកម្ម ភាពអាទិភាពនានា ដើម្បីសម្រេចគោលបំណង និងទិដៅនៃផែនការរបស់បន្ទីទេសចរណ៍ដែលបានលើកក៏ដូចជា អភិវឌ្ឍន៍ទេសចរណ៍រាជធានី ស្របតាមគោលនយោបាយរបស់ក្រសួងទេសចរណ៍ដែលមានកំណត់

[24] របាយការណ៍ក្រសួងទេសចរណ៍

ច្បាស់លាស់នូវ សកម្មភាពថវិកា និងរយៈពេលនៃការសម្រេចបានសំដៅធានាឱ្យការវិភាជថវិកាមានប្រសិទ្ធភាព និងមានតុល្យភាព ទៅតាមគោលបំណងគោលនយោបាយរវាងកម្មវិធីនិងយុទ្ធសាស្ត្រអាទិភាពនៅក្នុងផែនការយុទ្ធសាស្ត្រដែលក្រសួងបានរៀបចំ។

### ២.១.៧ វិស័យការងារ

បានផ្តោតយកចិត្តទុកដាក់លើគោលដៅសំខាន់ៗ គឺការចុះធ្វើអធិការកិច្ចការងារនៅតាមសហគ្រាសគ្រឹះស្ថាននៅរាជធានីភ្នំពេញ តាមប្រកាសលេខ៣៤១ ក.ប/ប្រ.ក ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០១៦ ស្តីពីការកំណត់ និងគ្រប់គ្រងសហគ្រាសគ្រឹះស្ថាននៅរាជធានីភ្នំពេញ ដើម្បីត្រួតពិនិត្យការអនុវត្តច្បាប់ស្តីពីការងារ ដោយលើកកម្ពស់ការអនុវត្តនូវលក្ខខណ្ឌការងារអនាម័យ និងសន្តិសុខសុវត្ថិភាពការងារនៅកន្លែងធ្វើការឱ្យកាន់តែប្រសើរឡើងនិងបន្តផ្សព្វផ្សាយអនុសញ្ញាអន្តរជាតិនិងលិខិតបទដ្ឋានគតិយុត្តនានា។

លើកកម្ពស់ការបម្រើសេវាកម្មសាធារណៈ ការលក់ឯកសារលតាប័ត្រ និងលិខិតបោះពុម្ពផ្សេងៗ និងលើកកម្ពស់ ប្រសិទ្ធភាពការផ្សះផ្សាវិវាទការងារ ដែលកើតមាននៅតាមបណ្តាសហគ្រាសគ្រឹះស្ថានតាមពាក្យបណ្តឹងរបស់កម្មករនិយោជិតដែលទាមទារផលប្រយោជន៍ស្របច្បាប់ស្តីពីការងារ។

## ២.២ ស្ថានភាពសង្គមកិច្ច

### ២.២.១ ការងារសង្គមកិច្ច

ដើម្បីរួមចំណែកឱ្យប្រជាពលរដ្ឋក្នុងរាជធានីភ្នំពេញបានរស់នៅប្រកបដោយសេចក្តីសុខទាំងផ្លូវកាយ និងផ្លូវចិត្តគឺបំណងប្រាថ្នាដ៏ចំបងរបស់រដ្ឋបាលរាជធានី ស្របអានគោលនយោបាយរបស់រាជរដ្ឋាភិបាលផ្អែកតាមលក្ខណៈរបស់រាជធានីភ្នំពេញដែលមានប្រជាជនច្រើន និងគ្រប់សមាសភាពដូចជាអាជីវករសេវាករមន្ត្រីរាជការបុគ្គលិក និយោជិក និយោជក់ អ្នកមានជីវភាពធូរធារអ្នកក្រីក្រព្រះសង្ឃអ្នកកាន់សាសនាផ្សេងៗតម្រូវអោយរដ្ឋ-បាលរាជធានីយកចិត្តទុកដាក់ខ្ពស់លើការងារសង្គមដែលកន្លងមកការងារនេះ យើងសង្កេតឃើញថាមានសក្តានុពលផងនឹងមានបញ្ហាប្រឈមមួយចំនួនផងដែរ។

រាជរដ្ឋាភិបាលកម្ពុជាក្នុងនីតិការទី ៦ នេះបានកំណត់ក្នុងកម្មវិធីនយោបាយស្តីពីការកាត់បន្ថយភាពក្រីក្ររបស់ប្រជាពលរដ្ឋដោយផ្អែកលើយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤។ ក្រសួងសង្គមកិច្ចអតីតយុទ្ធជន និងយុវនីតីសម្បទាដែលជាសេនាធិការឱ្យរដ្ឋាភិបាលបានដាក់ចេញនូវផែនការយុទ្ធសាស្ត្របីយ៉ាងនឹងដាក់ចេញកម្មវិធីរដ្ឋបាលអាទិភាព ៨ ចំណុចដើម្បីចូលរួមផែនការយុទ្ធសាស្ត្រថវិកាឆ្នាំ២០២០-២០២២។ [25] យោងតាម

[25] ផែនការយុទ្ធសាស្ត្រថវិកាឆ្នាំ២០២០-២០២២។

ផែនការយុទ្ធសាស្ត្ររបស់ក្រសួងសង្គមកិច្ចអតីតយុវជន និងយុវនីតីសម្បទានិងស្របតាមផែនការអភិវឌ្ឍនៅរដ្ឋបាលរាជធានីភ្នំពេញ (ផែនការយុទ្ធសាស្ត្រថវិកានិងផែនការប្រតិបត្តិ ២០២០-២០២២)។

មន្ទីរសង្គមកិច្ចអតីតយុវជននិងយុវនីតីសម្បទារាជធានីភ្នំពេញ មានបេសកកម្មអនុវត្តផ្តល់សេវាសុខមាលភាពជូនជនរងគ្រោះនិងងាយរងគ្រោះ មាន ជនចាស់ជរាគ្មានទីពឹង ជនពិការ ជនរស់នៅតាមចិញ្ចើមថ្នល់ កុមារកំព្រានិងកុមារងាយរងគ្រោះ ស្ត្រីបម្រើសេវាកម្សាន្ត ជនដែលផ្ទុកមេរោគអេដស៍ និងមានមេរោគសាហាវ ជនក្រីក្រជួបការលំបាកក្នុងសហគមន៍ និងសម្របសម្រួលបើកផ្តល់របបសន្តិសុខសង្គមជូន អតីតមន្ត្រីរាជការស៊ីវិល និងអតីតយុវជនប្រកបដោយសមធម៌និងមានតម្លាភាពរួមមាន៖

- ការងារអភិវឌ្ឍន៍សុខមាលភាពជនរងគ្រោះជនងាយរងគ្រោះ
- កិច្ចការគ្រួសារ
- អភិវឌ្ឍន៍សុខភាពកុមារនិងស្តារនីតិសម្បទា
- ការងារក្រុមប្រឹក្សាជាតិដើម្បីកុមារ
- អភិវឌ្ឍន៍វិស័យពិការភាព
- អភិវឌ្ឍន៍សុខមាភាពមនុស្សចាស់
- អភិវឌ្ឍរបបសន្តិសុខសង្គមមន្ត្រីរាជការស៊ីវិលនិងអភិវឌ្ឍន៍អតីតយុទ្ធជន
- អភិវឌ្ឍសុខមាលភាពជាដៃគូ

មន្ត្រីសង្គមកិច្ចអតីតយុទ្ធជននិងយុវនីតិសម្បទារាជធានីភ្នំពេញ ដោយនៅក្នុងរាជធានីភ្នំពេញជាបេះដូងនៃប្រទេសជាតិជាមជ្ឈមណ្ឌលសេដ្ឋកិច្ចនយោបាយ អភិវឌ្ឍន៍ វប្បធម៌ ទេសចរណ៍កំណើនសេដ្ឋកិច្ចរីកចម្រើនយ៉ាងឆាប់រហ័ស។

## ២.២.២ ស្ថានភាពអប់រំ និងកីឡា

### ១. វិស័យភាពអប់រំ

ស្ថានភាពអប់រំនៅរាជធានីភ្នំពេញ មានគ្រឹះស្ថានសិក្សាសាធារណៈសាលាអប់រំពិសេសថ្នាក់អប់រំបរិយាបន្នថ្នាក់សមារណកម្ម ដែលធានាបាននូវការប្រមូលកុមារកំព្រា ក្រីក្រ ពិការភ្នែក គរថ្លង់ ខ្សោយសតិបញ្ញា ថ្នាក់ពន្លឿនសម្រាប់ប្រមូលកុមារចូលរៀនយឺតដែលមានអាយុច្រើន អាគារធនធានថ្នាក់អប់រំ បច្ចេកទេសគម្រោងកែលម្អនៅមធ្យមសិក្សាសាលារៀនជំនាន់ថ្មី និងគ្រឹះស្ថានសិក្សាឯកជន ដៃគូរអភិវឌ្ឍន៍ចាប់ពីថ្នាក់មត្តេយ្យរហូតដល់ថ្នាក់ឧត្តមសិក្សា និងក្រោយឧត្តមសិក្សាដែលធានាឱ្យប្រជាជនក្នុងរាជធានីអាចបញ្ជូនកូនចៅដល់ និងក្នុងវ័យគ្រប់អាយុសិក្សាឱ្យចូលរៀនសូត្របានគ្រប់ៗគ្នា។ ក្រៅពីនេះនៅមានកម្មវិធីអប់រំក្រៅប្រព័ន្ធ ដែលធានានូវការបើកថ្នាក់អក្ខរកម្ម ថ្នាក់សមមូលថ្នាក់ចូលរៀនឡើងវិញ ថ្នាក់បណ្តុះបណ្តាលមុខវិជ្ជាជីវៈ និងបំនិន

ជីវិតក្នុងមជ្ឈមណ្ឌលសិក្សាសហគមន៍ជូនដល់កូនចៅប្រជាពលរដ្ឋក្នុងមូលដ្ឋាន ទិសដៅគឺឈានទៅសម្រេចវត្ថុបំណងគោលនយោបាយ អប់រំ និងដើម្បីបក្សីគ្នាជាមួយក៏នយោបាយអភិវឌ្ឍន៍ដោយចីរភាព (គោលដៅទី៤ស្ដីពីការអប់រំ ឆ្នាំ២០៣០) ដោយសង្កត់ធ្ងន់លើ "ការអប់រំបរិយាប័ន្ន" និង "ការសិក្សាពេញមួយជីវិត" ដែលជាវត្ថុបំណងគោលនយោបាយអប់រំសំខាន់។ ទន្ទឹមនឹងនោះយើងក៏នៅមានចំណុចសេសសល់មួយចំនួនដូចជា: កុមារមួយចំនួនដើរលេងច្រើន ហើយគេចវេះមិនព្រមចូលរៀនកុមារមួយចំនួនតូចមិនបានរៀនចប់កម្រិតថ្នាក់មូលដ្ឋានម្ដាយឬអាណាព្យាបាលមួយចំនួនតូចមិនយកចិត្តទុកដាក់តាមដានការសិក្សារបស់កូន និងទំនាក់ទំនងជាមួយគ្រូគណនាយក។ ម្យ៉ាងទៀតសាលារៀនមួយចំនួនតូចខ្វះអាគារសិក្សា អាគារសិក្សាខ្លះចាស់ទ្រុឌទ្រោមគ្មានលទ្ធភាពជួសជុល ម្យ៉ាងកំណើនសិស្សកើនឡើងពីមួយឆ្នាំទៅមួយឆ្នាំពិសេសតំបន់អភិវឌ្ឍន៍ជាយក្រុងដែលចាំបាច់ត្រូវជួសជុល និងសាងសង់អាគារសិក្សាបន្ថែម និងសាលាមួយចំនួនតូចនៅមានទីធ្លាលិចទឹកពេលភ្លៀងធ្លាក់ខ្លាំង។

នៅក្នុងប្រទេសកម្ពុជាមានសាលារៀន វិទ្យាស្ថាន និង សាកលវិទ្យាល័យ ជាច្រើនសម្រាប់បំពេញតម្រូវការដល់សិស្សានុសិស្សដែលបានបញ្ចប់ថ្នាក់សិក្សានៅថ្នាក់ទុតិយភូមិ រឺ មធ្យមសិក្សា ហើយពួកគេអាចបន្តចូលរៀននៅថ្នាក់ឧត្តមសិក្សាបានដូចជានៅ សកលវិទ្យាល័យរដ្ឋ និង ឯកជន។ សកលវិទ្យាល័យទាំងនោះមានមុខវិជ្ជាជាច្រើនដូចជា: អក្សរសាស្ត្រអង់គ្លេស ព័ត៌មានវិទ្យា គ្រប់គ្រង គណនេយ្យ វិស្វករសំណង់ គ្រប់គ្រងសណ្ឋាគារ មគ្គុទេសន៍ អស្សាណូវិទ្យា។ល។ សាកលវិទ្យាល័យភូមិន្ទភ្នំពេញ បានចាប់ផ្ដើមតាំងពីឆ្នាំ១៩៦០ មកម្ល៉េះ។

សព្វថ្ងៃមានសិស្ស៥ពាន់នាក់ និង មានសាស្ត្រាចារ្យ ២០០នាក់។[26] នេះជាមោទនភាពមួយរបស់ ប្រទេសកម្ពុជា ដែលមានសាកលវិទ្យាល័យធំបែបនេះ ហើយការអប់រំប្រកបដោយភាពស្វាហាប់និងម៉ត់ចត់ ធ្វើអោយនិស្សិតបន្ទាប់ពីបាន បញ្ចប់ថ្នាក់មានសម្ថតភាព ក្នុងការស្វែងរកការងារធ្វើ និងប្រកួតប្រជែងដើម្បីមាន អនាគតល្អក្នុងសង្គមជាតិ និង ជួយដល់ប្រទេសជាតិ។ អគារសាងសង់ឡើងនៅសម័យអាណានិគមបារាំងនៅក្នុងទីក្រុងភ្នំពេញ។ ហើយនៅពេលបច្ចុប្បន្ននេះវិស័យអបរំកំពុងមានការរីកចម្រើនឡើងជាលំដាប់ដោយសារតែការសិក្សារអបរំពីសំណាក់លោកគ្រូអ្នកគ្រូ ដែលមានបទពិសោធន៍ជាច្រើនឆ្នាំទើបធ្វើអោយការសិក្សារអប់រំរបស់មនុស្សសម័យបច្ចុប្បន្នមានការចេះដឹងច្រើនហើយទើបធ្វើអោយប្រទេសជាតិមានការរីកចម្រើនឡើងជាលំដាប់។ ហើយនៅក្នុងអំឡុងឆ្នាំ២០១៦ កំណើនការចេះដឹងរបស់យុវវ័យនៅតាមគ្រឹះស្ថានឧត្តមសិក្សានានាមានការរីកចម្រើនយ៉ាងខ្លាំងផងដែរ។

១.វិទ្យាស្ថានពុទ្ធសាសនបណ្ឌិត្យ

---

[26] ទិន្នន័យក្រសួងអប់រំ យុវជន និងកីឡា

២.សាលាភូមិន្ទរដ្ឋបាល ឬ École Royale d'Administration

៣.សាកលវិទ្យាល័យភូមិន្ទភ្នំពេញ (ស.ភ.ភ.ភ. រឺ RUPP) ឬ L'université Royale de Phnom Penh (URPP) គឺជាស្ថាប័នអប់រំជាន់ខ្ពស់ធំ និងចំណាស់បំផុតនៅកម្ពុជា។ កាលពីឆ្នាំ ២០០៨ សាកលវិទ្យាល័យនេះមាននិស្សិតជាង ១០ ០០០ នាក់ ទូទាំងបរិវេណសាកលវិទ្យាល័យបី និងផ្តល់នូវវគ្គសិក្សាគុណភាពខ្ពស់ទូលំទូលាយក្នុងមហាវិទ្យាល័យវិទ្យាសាស្ត្រ មហាវិទ្យាល័យវិទ្យាសាស្ត្រសង្គម និង មនុស្សសាស្ត្រ និង វិទ្យាស្ថានភាសាបរទេស (វ.ភ.ប. រឺ IFL)។ មានស្ថាប័នអប់រំជាន់ខ្ពស់ប្រហែលហាសិបនៅកម្ពុជា ភាគច្រើនក្នុងនោះគ្មានបរិវេណទីធ្លាទេ។ ការបរិច្ចាគអន្តរជាតិជាច្រើន ដូចជា ថ្ងៃថ្មី កម្ពុជា ចាត់ចែងសុខុបត្ថម្ភវត្ថុ ខាងអប់រំឯករាជ្យជាការបន្ថែមដល់សាលាសាធារណៈសម្រាប់សិស្សនិស្សិត។

៤.សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រនិងវិទ្យាសាស្ត្រសេដ្ឋកិច្ច (ស.ភ.ន.ស. រឺ RULE)

៥.សាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ (ស.ភ.វ.ស. រឺ RUFA)

៦.សាកលវិទ្យាល័យភូមិន្ទកសិកម្ម (ស.ភ.ក. រឺ RUA)

៧.សាកលវិទ្យាល័យជាតិគ្រប់គ្រង (ស.ជ.គ. រឺ NUM)

៨.វិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជា (វ.ប.ក. រឺ ITC)

៩.វិទ្យាស្ថានពុទ្ធសាសនបណ្ឌិត្យត្រូវបានបង្កើតឡើងនៅថ្ងៃ ១២ ឧសភា ១៩៣០ និងក៏ជាស្ថាប័នពុទ្ធសាសនាបណ្ឌិត្យរបស់រដ្ឋដ៏សំខាន់នៅកម្ពុជា។

**២. វិស័យកីឡា**

កម្ពុជា មានការលេងកីឡាជាង៣០ឆ្នាំមកហើយ ឥឡូវនេះកម្ពុជាកំពុងតែរឹតបន្តឹងនិងបង្កើនវិស័យកីឡាបន្ថែមទៀត។ កីឡាដែលមានការពេញនិយមមាន កីឡាបាល់ទាត់ ហើយនិង កីឡាសិល្បៈប្រយុទ្ធដូចជា ល្បុក្កតោ ប្រដាល់សេរី (ក្បាច់គុណប្រដាល់សព្វថ្ងៃ)ហើយនិង កីឡាចំបាប់តាមបែបប្រពៃណី] ប្រជាជនខ្មែរហាត់ក្បាច់ប្រយុទ្ធទាំងនេះទុកជាគ្រឿងការពារខ្លួន និងដើម្បីសុខភាព។ ទីកន្លែងជួបជុំដែលសំខាន់ជាងគេគឺនៅក្នុងទីក្រុងភ្នំពេញ ពហុកីឡាដ្ឋានជាតិអូឡាំពិក ដែលមានចំណុះប្រជាជនអាចចូលទស្សនាបាន៥ម៉ឺននាក់ ទោះបីជាប្រទេសនេះមិនដែលបានធ្វើជាម្ចាស់ផ្ទះល្បែងអូឡាំពិកក៏ដោយ។ ពហុកីឡាដ្ឋាននេះ បានកសាងឡើងនៅឆ្នាំ ១៩៦៤។ វាក៏ជាកន្លែងហ្វឹកហាត់សម្រាប់ក្រុមកីឡាករបាល់ទាត់ជម្រើសជាតិកម្ពុជាផងដែរ និងជាទីប្រកួតជម្រើសជើងឯក (Cambodian Premier League)។ នៅពេលបញ្ចប់ការសាងសង់ កីឡាដ្ឋាននេះធ្លាប់ជាកីឡាដ្ឋានមួយក្នុងចំណោមកីឡាដ្ឋានធំបំផុតនៅអាស៊ី។ សព្វថ្ងៃនេះវាគឺជាកីឡាដ្ឋានធំបំផុតទី៦នៅអាស៊ីអាគ្នេយ៍។ កីឡាបាល់ទះ បាល់បោះ និង តៃក្វាន់ដូ ជាញឹកញាប់បានទទួលជាម្ចាស់ផ្ទះនៅកីឡាដ្ឋាននេះ។ មជ្ឈមណ្ឌលកីឡាជាតិកម្ពុជាល្បីល្បាញដោយសារការធ្វើជាម្ចាស់ផ្ទះលើការប្រកួតហែលទឹក ប្រដាល់ និង បាល់ទះ។ ក្លិប

បាល់ទាត់ក្នុងស្រុកគួរឱ្យកត់សំគាល់រួមមាន ក្លឹបបាល់ទាត់ភ្នំពេញក្រោន ក្លិបបាល់ទាត់ណាហ្គាវើល ក្លឹបបាល់ទាត់ព្រះខ័នរាជស្វាយរៀង និងក្លិបបាល់ទាត់បឹងកេត។

### ២.២.៣ ស្ថានភាពសុខាភិបាល

- គោលដៅជាយុទ្ធសាស្ត្រសម្រាប់ឆ្នាំ២០២០-២០២២[27]
  - ផ្តល់ការធានារ៉ាប់រងសុខភាពសង្គមមួយពេញលេញនៅរាជធានីភ្នំពេញមានរយៈការប្រើប្រាស់សេវាហិរញ្ញប្បទានសុខាភិបាលបេឡាជាតិរបបសន្តិសុខសង្គម (ប.ស.ស) មូលនិធិសមធម៌និងការលើកលែងបង់ថ្លៃ។
  - ធ្វើឱ្យប្រសើរឡើងនូវគុណភាពសេវាសុខាភិបាលនៅតាមមូលដ្ឋានសុខាភិបាលសាធារណៈ (មណ្ឌលសុខភាព និងមន្ទីរពេទ្យបង្អែក)តាមរយៈការកែលំអនិងសាងបន្ថែមហេដ្ឋារចនាសម្ព័ន្ធ រូបវន្តបំពាក់ឧបករណ៍បរិក្ខារពេទ្យទំនើបៗ បង្កើនសមត្ថភាពធនធានមនុស្ស។
  - សម្របសម្រួលនិងសហការជាមួយដៃគូអភិវឌ្ឍន៍សុខាភិបាលតាមរយពង្រឹងការអនុវត្តសារាចរសេចក្តីណែនាំដឹការ និងមគ្គុទ្ទេសក៍ការព្យាបាលជំងឺរបស់ក្រសួងសុខាភិបាលនិងរដ្ឋបាលរាជធានីភ្នំពេញ។
- **សមិទ្ធផលសំខាន់ៗសម្រេចបានកន្លងមក**
  - ប្រជាពលរដ្ឋជាពិសេសជនមានចំណូលទាបនិងមធ្យមទៅទទួលសេវាសុខភាពដោយគ្មានរបាំងឧបសគ្គភូមិសាស្ត្រនិងរបាំងឧបសគ្គហិរញ្ញវត្ថុនៅមណ្ឌលសុខភាពទាំង ៤៣ ទីតាំងមន្ទីរពេទ្យបង្អែកទាំងប្រាំបីកន្លែងនិងមន្ទីរពេទ្យជាតិនៅរាជធានីភ្នំពេញ។
  - អត្រាស្លាប់ទារកអាយុក្រោម ១ ឆ្នាំបានធ្លាក់ចុះពី ៣៨នាក់ ក្នុងឆ្នាំ ២០០០ មកត្រឹម ១៧ នាក់ក្នុងចំណោម1000 កើតរស់ក្នុងឆ្នាំ ២០១៥។ អត្រាមរណភាពមាតាបានធ្លាក់ចុះពី ៤៣៧ នាក់ក្នុងចំណោម ១ សែនកូនកើតរស់ក្នុងឆ្នាំ ២០០០ មកក្រុម ១៧០ នាក់ក្នុងចំណោម ១ សែនកូនកើតរស់ឆ្នាំ ២០១៥។ ភាគរយនៃស្ត្រីសម្រាលកូននៅមូលដ្ឋានសុខាភិបាលបានកើនឡើងពី ៧០.៧% នៅឆ្នាំ២០០០ ដល់ ៩៥.៩% នៅឆ្នាំ២០១៥។ តាមរយៈសុចនាករសុខភាពសំខាន់ៗទាំងនេះបានបញ្ជាក់ថាស្ថានភាពនៅរាជធានីភ្នំពេញមានភាពប្រសើរឡើងយ៉ាងឆាប់រហ័សក្នុងកំឡុងពីរទសវត្សរ៍ចុងក្រោយនេះ។
- **ការងារអាទិភាពឆ្ពោះទៅកាន់គោលដៅជាយុទ្ធសាស្ត្រ**
  - កែលម្អនិងបំពាក់ឧបករណ៍បរិក្ខារពេទ្យ (Medical Equipment) បន្ថែមនៅគ្រប់មន្ទីរពិសោធន៍របស់មន្ទីរពេទ្យបង្អែកទាំង ៨ នឹងបង្កើនសមត្ថភាពអ្នកបច្ចេកទេសមន្ទីរពិសោធន៍។

[27] គោលដៅជាយុទ្ធសាស្ត្រសម្រាប់ឆ្នាំ២០២០-២០២២

- ដំឡើងសមត្ថភាពប៉ុស្តិ៍សុខភាពទៅជាមណ្ឌលសុខភាពយ៉ាងតិច ៣ ទីតាំងមុនបំណាច់ឆ្នាំ ២០២២។
- សង់អគារមន្ទីរពេទ្យបន្ថែមនៅមន្ទីរពេទ្យបង្អែក
- សហការនិងអនុវត្តជាមួយបេឡាជាតិរបបសន្តិសុខសង្គម (ប.ស.ស) ក្នុងការផ្តល់សេវាសុខាភិបាលដល់សមាជិក ប.ស.ស ឱ្យបានល្អ។
- ដំឡើងកម្រិតសមត្ថភាពមន្ទីរពេទ្យបង្អែកCPA១ទៅជាមន្ទីរពេទ្យបង្អែកCPA២ចំនួន ១ទីតាំង
- ផ្តល់សេវាសុខាភិបាលជូនប្រជាពលរដ្ឋក្រីក្រ តែស្វែងរកការព្យាបាលនៅមូលដ្ឋានសុខាភិបាលសាធារណៈដោយប្រើប្រាស់ថវិកាមូលនិធិសមធម៌ឱ្យបានល្អ។
- អនុវត្តឱ្យបានល្អនូវរាល់សារាចរសេចក្តីណែនាំ ដីការ និងមគ្គុទេសក៍ការព្យាបាលជំងឺរបស់ក្រសួងសុខាភិបាលនិងរដ្ឋបាលរាជធានីភ្នំពេញ។
- គ្រប់មណ្ឌលសុខភាពផ្តល់សេវាំណុំសកម្មភាពអាប្បបរមាពេញលេញនិងការអប់រំសុខភាព។ មន្ទីរពេទ្យបង្អែកផ្តល់សេវាសំណុំសកម្មភាពបង្គ្រប់នឹងបង្កើនអត្រាប្រើប្រាស់គ្រែ។
- បញ្ជ្រាបចំណេះដឹងការទប់ទល់បង្ការជំងឺមិនឆ្លង និងរបៀបរស់នៅប្រកបដោយសុខមាលភាពជូនប្រជាពលរដ្ឋរាជធានីភ្នំពេញ។
- ណែនាំ និងចាត់វិធានការលើងដៃគូរអភិវឌ្ឍន៍សុខាភិបាលឯកជនដែលមិនផ្តល់ឬផ្តល់មិនទៀងទាត់នូវរបាយការណ៍សកម្មភាពរបស់គាត់។
- រៀបចំបង្កើតនិងបំពាក់ឧបករណ៍បរិក្ខារពេទ្យបន្ថែមជូនផ្នែកសល្យសាស្ត្រ ហ្នឹងថ្ងៃសង្គ្រោះបន្ទាន់នៅមន្ទីរពេទ្យបង្អែករាជធានីភ្នំពេញដើម្បីទទួលព្យាបាលអ្នករងគ្រោះថ្នាក់ចរាចរណ៍។

- **មន្ទីរពេទ្យរដ្ឋ**
  - មន្ទីរពិសោធន៍
  - មន្ទីរពិសោធន៍កសិកម្មជាតិ
  - មន្ទីរពិសោធន៍មជ្ឈមណ្ឌលវិទ្យុសាស្ត្រ និងរូបភាពវេជ្ជសាស្ត្រ
  - មន្ទីរពិសោធន៍វេជ្ជសាស្ត្រភ្នំពេញ
  - មន្ទីរពិសោធន៍សាមគ្គី
  - មន្ទីរពិសោធន៍សារមន្ទីរជាតិភ្នំពេញ
  - មន្ទីរពេទ្យ
  - មន្ទីរពេទ្យកាល់ម៉ែត
  - មន្ទីរពេទ្យកេតុមាលា

- មន្ទីរពេទ្យបង្អែកចំការមន
- មន្ទីរពេទ្យបង្អែកច្បារអំពៅ
- មន្ទីរពេទ្យបង្អែកដង្កោ
- មន្ទីរពេទ្យបង្អែកពោធិ៍ចិនតុង
- មន្ទីរពេទ្យបង្អែកព្រែកព្នៅ
- មន្ទីរពេទ្យបង្អែកមានជ័យ
- មន្ទីរពេទ្យបង្អែករាជធានីភ្នំពេញ ហៅ ពេទ្យសម្តេចក្រុង
- មន្ទីរពេទ្យបង្អែកសែនសុខ
- មន្ទីរពេទ្យបង្អែកសម្តេចឪ
- មន្ទីរពេទ្យព្រះកុសមៈ ហៅ ពេទ្យលោកសង្ឃ
- មន្ទីរពេទ្យមិត្តភាពខ្មែរសូវៀត ហៅ ពេទ្យរុស្ស៊ី

▪ **មណ្ឌលសុខភាពរដ្ឋ**

- មណ្ឌលសុខភាព
- មណ្ឌលសុខភាព៧មករា
- មណ្ឌលសុខភាពឃ្មួញ
- មណ្ឌលសុខភាពចាក់អង្រែ
- មណ្ឌលសុខភាពដង្កោ
- មណ្ឌលសុខភាពដូនពេញ
- មណ្ឌលសុខភាពទឹកថ្លា
- មណ្ឌលសុខភាពទួលស្វាយព្រៃ
- មណ្ឌលសុខភាពផ្សារដើមថ្កូវ
- មណ្ឌលសុខភាពពន្សាំង
- មណ្ឌលសុខភាពពោធិ៍ចិនតុង
- មណ្ឌលសុខភាពស្ទឹងមានជ័យ
- មណ្ឌលសុខភាពអន្លង់ក្ងាន
- មណ្ឌលសុខភាពពញ្ញាពន់

▪ **មន្ទីរពេទ្យឯកជន**

- មន្ទីរពិសោធន៍
- ក្រុមហ៊ុនមន្ទីរពិសោធន៍កម្ពុជា
- មន្ទីរពិសោធន៍ប៊ីយ៉ូម៉េដភ្នំពេញ
- មន្ទីរពិសោធន៍សុភមង្គល
- មន្ទីរពិសោធន៍ស៊ីធីស្កេន
- មន្ទីរពិសោធន៍សុភមង្គលឡាប
- វិទ្យាស្ថានប៉ាស្ទ័រ
- មន្ទីរពេទ្យ
- មន្ទីរពេទ្យគន្ធបុប្ផា នៅជិតវត្តភ្នំ
- មន្ទីរពេទ្យគន្ធបុប្ផាទី២
- មន្ទីរពេទ្យគន្ធបុប្ផាទី៣ នៅជិតព្រះបរមរាជវាំង
- មន្ទីរពេទ្យជោរ៉ៃភ្នំពេញ នៅច្បារអំពៅ
- មន្ទីរពេទ្យប៉ាស៊ីហ្វិកភ្នំពេញ
- មន្ទីរពេទ្យរ៉ូយ៉ាល់ភ្នំពេញ ទឹកថ្លា
- មន្ទីរពេទ្យរ៉ូយាល់រតនៈ រង្វង់មូលទួលគោក
- មន្ទីរពេទ្យវិសាលសុខ
- មន្ទីរពេទ្យសែនសុខ
- មន្ទីរពេទ្យស្ត្រីនគរទេព
- មន្ទីរពហុព្យាបាល
- ប៉ូលីគ្លីនិកម៉ៅសារី
- មន្ទីរពហុព្យាបាលចិន្តា
- មន្ទីរពហុព្យាបាលណារិទ្ធ
- មន្ទីរពហុព្យាបាលហុងអ៊ីន
- មន្ទីរពហុព្យាបាលហ្វឺសគ្លីនិក
- មន្ទីរពហុព្យាបាលនិងសម្ភពចោមចៅ
- មន្ទីរពហុព្យាបាលនិងសម្ភពដេអិន
- មន្ទីរពហុព្យាបាលនិងសម្ភពរតនៈវិសាល

- មន្ទីរពហុព្យាបាលនិងសម្ភពវិបុលសុខ
- មន្ទីរពហុព្យាបាលនិងសម្ភពសុក្រិត
- មន្ទីរពហុព្យាបាលនិងសម្ភពសុខលាភមេត្រី
- មន្ទីរពហុព្យាបាលនិងសម្ភពសុវណ្ណារ៉ា
- មន្ទីរពហុព្យាបាលនិងសម្ភពអង្គរធំ
- មន្ទីរពហុព្យាបាលហ៊្សីនហ៊្សីន
- មន្ទីរពហុព្យាបាលសៀនតាយ
- មន្ទីរព្យាបាល
- គ្លីនិក215ភ្នំពេញ
- គ្លីនិកកែសម្ផស្សកូរ៉េខាងត្បូង
- គ្លីនិកខាងហ្ស៊ឺរ
- គ្លីនិកគឹមសុង
- គ្លីនិកដំបូន្មានប្រចាំថ្ងៃ
- គ្លីនិកឃឹមម៉ានី
- គ្លីនិកចិននៅភ្នំពេញ
- គ្លីនិកចោមចៅ
- គ្លីនិកណាហ្គា
- គ្លីនិកធ្មេញអ៊ឹងហួត
- គ្លីនិកធ្មេញឡាយវ៉ាវី
- គ្លីនិកព្រីនសេស
- គ្លីនិកព្យាបាលដោយចលនាភ្នំពេញ
- គ្លីនិកព្យាបាលភ្នែកភ្នំពេញ
- គ្លីនិកមេគង្គ
- គ្លីនិករ៉ាក់ចាក់អង្រែក្រោម
- គ្លីនិករ៉ាក់ទឹកថ្លា
- គ្លីនិករ៉ាក់ភ្នំពេញ១
- គ្លីនិករ៉ាក់ភ្នំពេញ២

- គ្លីនិកវ៉ាចសំអុល
- គ្លីនិកលីស្រីវីណា
- គ្លីនិកវុឌ្ឍីស័ក្តិ
- គ្លីនិកវេជ្ជបុត្រ
- គ្លីនិកសម្ភពសូរិយា
- គ្លីនិកសិង្ហបុរី MW Medical]
- គ្លីនិកសុខភាពសង្គម
- គ្លីនិកសើស្បែកភ្នំពេញ
- គ្លីនិកសៀងហៃ
- គ្លីនិកឯកជនមនោរម្យ
- គ្លីនិកឯកជនសួគ៌ា
- គ្លីនិកឯកជនហំសម្បត្តិ
- មន្ទីរព្យាបាលខាយរ៉ូព្រែកធីក
- មន្ទីរព្យាបាលនិងថែរក្សាស្បែកដឺរម៉ាយែរ
- មន្ទីរព្យាបាលធ្មេញខ្មែរ
- មន្ទីរព្យាបាលធ្មេញដួងវណ្ណា
- មន្ទីរព្យាបាលធ្មេញដួងសិទ្ធិ
- មន្ទីរព្យាបាលធ្មេញប៉ាស៊ីហ្វិក
- មន្ទីរព្យាបាលធ្មេញបស្ទិម
- មន្ទីរព្យាបាលធ្មេញស៊ិនហ្សេត
- មន្ទីរព្យាបាលធ្មេញអន្តរជាតិ
- មន្ទីរព្យាបាលនិងសម្ភពឥន្ទ្រទេវី
- មន្ទីរព្យាបាលនិងសម្ភពអ៊ុំសារ៉ន
- មន្ទីរមព្យាបាលសុខភាពវ៉ាក់
- មន្ទីរព្យាបាលអប្សារាភ្នំពេញ
- វ៉ាម៉ាប៉ូលីគ្លីនិក
- សុភាគ្លីនិកនិងសម្ភព

- មជ្ឈមណ្ឌល
- មជ្ឈមណ្ឌលកែសម្ផស្សខេមរ៉ូគ្លីនិក
- មជ្ឈមណ្ឌលវ៉ាក់សាំងអប្បារាភ្នំពេញគ្លី
- បន្ទប់ពិគ្រោះ និង ព្យាបាលជំងឺ
- បន្ទប់ពិគ្រោះជំងឺតាន់តឹកស្រេង
- បន្ទប់ពិគ្រោះនិងព្យាបាលជំងឺកុមារឈឺប៊ុនណា
- បន្ទប់ពិគ្រោះនិងព្យាបាលជំងឺមាត់ធ្មេញថៃសុខបញ្ញា
- បន្ទប់ពិគ្រោះនិងព្យាបាលជំងឺវេជ្ជបណ្ឌិតចាន់ងី
- បន្ទប់ពិគ្រោះពិនិត្យព្យាបាលជំងឺសនស៊ីថា
- បន្ទប់ពិគ្រោះព្យាបាលជំងឺសុខទៀង
- បន្ទប់ពិគ្រោះនិងព្យាបាលជំងឺសុខសាន្ត
- បន្ទប់ពិគ្រោះនិងព្យាបាលជំងឺសើស្បែក
- បន្ទប់ពិគ្រោះនិងព្យាបាលជំងឺអ៊ុនវុទ្ធី
- ឱសថស្ថាន
- ឱសថស្ថានឌីយ៉ាម៉ង់
- ឱសថស្ថានចេនឡា
- ឱសថស្ថានបញ្ញាមហោសថ
- ឱសថស្ថានបាយ័ន
- ឱសថស្ថានប៉ាស៊ីហ្វិកភាគខាងលិច
- ឱសថស្ថានបូជលើ
- ឱសថស្ថានបូព្រី
- ឱសថស្ថានផ្សារតាប៉ាង
- ឱសថស្ថានព្រំចន្ទា
- ឱសថស្ថានភ្នំពេញ
- ឱសថស្ថានមយូរ៉ា
- ឱសថស្ថានម៉ារីណា
- ឱសថស្ថានវិមានស័ក្ខសិទ្ធ

- ឱសថស្ថានវេស្ទីន
- ឱសថស្ថានសិរីនាថ
- ឱសថស្ថានសុផាន់ណា
- ឱសថស្ថានហេងចំរើន
- ឱសថស្ថានហ្វាម៉ាតខ្មែរ-សូវៀត
- ឱសថស្ថានហ្វាម៉ាតនរោត្តម
- ឱសថស្ថានអង្គរធីម
- ឱសថស្ថាន MedCare
- ឱសថស្ថានរង ១កប ១ខប...។[28]

## ២.៣ ស្ថានភាពនៃការប្រើប្រាស់ដីធ្លីការគ្រប់គ្រងធនធានធម្មជាតិបរិស្ថាន

### ២.៣.១ ស្ថានភាពនៃការប្រើប្រាស់ដីធ្លី

ក្នុងគោលបំណងគ្រប់គ្រង និងប្រើប្រាស់ដីធ្លីឱ្យបានត្រឹមត្រូវនិងផ្តល់ផលប្រយោជន៍ជាអតិបរមាដល់សង្គមជាតិឱ្យស្របតាមគោលការណ៍ច្បាប់ កន្លងមកនេះរដ្ឋបាលរាជធានីភ្នំពេញបានរៀបចំយុទ្ធសាស្ត្រគ្រប់គ្រងដីធ្លីដោយផ្តោតសំខាន់លើវិធានការពង្រឹងប្រព័ន្ធគ្រប់គ្រងការលប់បំបាត់ភាពអនាធិបតេយ្យ ក្នុងការកាន់កាប់ដីដោយខុសច្បាប់និងការដាក់ចេញនូវវិធានការសមស្របដើម្បីទប់ស្កាត់ការប្រមូលដី ដោយមិនបានប្រើប្រាស់និងមិនផលិត។ វិធានការនៃធ្វើឡើងដើម្បីបង្កើនប្រសិទ្ធភាពក្នុងការគ្រប់គ្រង និងប្រើប្រាស់ដីទំនេររបស់រដ្ឋនិងឯកជនព្រមទាំងការដោះស្រាយតាមបទបញ្ញត្តិច្បាប់ ដែលឯកជនកាន់កាប់ដីរដ្ឋដោយមិនសមស្របតាមលិខិតបទដ្ឋានគតិយុត្តិ។

រដ្ឋបាលរាជធានីភ្នំពេញបន្តជម្រុញការធ្វើបញ្ជីសារពើភ័ណ្ឌអចលនទ្រព្យរបស់រដ្ឋ ព្រមទាំងការចុះបញ្ជីជាលក្ខណៈប្រព័ន្ធទូទាំងរាជធានីភ្នំពេញកាត់បន្ថយទំនាស់ដីធ្លីនិងធានាសុវត្ថិភាពកម្មសិទ្ធិនិងការលុបបំបាត់ ភាពអនាធិបតេយ្យក្នុងការកាន់កាប់ដែលដោយបន្តធ្វើការដោះស្រាយវិវាទដីធ្លីនិងធានាសុវត្ថិភាពកម្មសិទ្ធិ និងលុបបំបាត់ភាពអនាធិបតេយ្យក្នុងការកាន់កាប់ដីដោយបន្តធ្វើការដោះស្រាយវិវាទដីធ្លី ដោយប្រើប្រាស់យន្តការច្បាប់ដើម្បីធានាយុត្តិធម៌គួបផ្សំជាមួយនឹងការដោះស្រាយវិវាទដីធ្លីក្រៅប្រព័ន្ធតុលាការ។ ទន្ទឹមនឹងនេះដែរក៏មានការយកចិត្តទុកដាក់ផងដែរចំពោះសំណង់លំនៅឋានគ្រួសារក្រីក្រ និងក្រុមជនងាយរងគ្រោះដោយការសហការជាមួយដៃគូអភិវឌ្ឍន៍នានាផ្តល់ទីតាំងសមស្របដល់សហគមន៍ក្រីក្រ។ បច្ចុប្បន្នក្រោមការដឹកនាំរបស់រាជរដ្ឋាភិ

[28] ទិន្នន័យក្រសួងសុខាភិបាល

បាលរដ្ឋបាលរាជធានីភ្នំពេញកំពុងរៀបចំចុះបញ្ជីដីមានលក្ខណៈជាប្រព័ន្ធជូនប្រជាពលរដ្ឋនៅលើដីឯកជនរបស់រដ្ឋជាយូរមកហើយ។

ក្នុងគោលបំណងធានាប្រសិទ្ធភាពក្នុងការប្រើប្រាស់ដីធ្លីរាជធានីភ្នំពេញបាន ជំរុញការរៀបចំផែនការប្រើប្រាស់ដីធ្លីសម្រាប់ ការអភិវឌ្ឍកសិកម្ម ឧស្សាហកម្មពាណិជ្ជកម្មការការពារវប្បធម៌ការថែរក្សាធនធានធម្មជាតិទេសចរណ៍លំនៅឋានតំបន់បម្រុងទុក និង តំបន់អភិរក្សឱ្យចំទឹកដែលជៀសវាងការប្រើប្រាស់ដីភ្លេងមិនត្រឹមត្រូវតាមគោលការណ៍កំណត់។ បន្តអនុវត្តគោនយោបាយរបស់រាជរដ្ឋាភិបាលលើការយកពន្ធលើដីធ្លីទំនេរដែលមិនប្រើប្រាស់ និងពន្ធលំនៅដ្ឋានលើកលែងដីកសិកម្មបង្កបង្កើនផលជាលក្ខណៈគ្រួសារ។

- **បញ្ហាប្រឈម**
  - ប្រជាជនមួយចំនួននៅតែមិនព្រមបង់ពន្ធលើដីទំនេរមិនប្រើប្រាស់។
  - រោងចក្រមួយចំនួនមិនបានសាងសង់តាមប្លង់អនុវត្តរបស់រាជធានី។
  - មានឃ្លាំងផ្ទុកទំនិញមួយចំនួនដែលមានទីតាំងក្នុងខណ្ឌទាំង 4 ក្នុងរាជធានីភ្នំពេញនៅឡើយ។
  - ដីក្នុងតំបន់មួយចំនួនម្ចាស់ដីបានបែងចែកជាដីឡូត៍មានផ្លូវតូចៗដោយមិនបានឆ្លងកាត់មន្ទីរជំនាញនិងការសម្រេចរបស់រដ្ឋបាលរាជធានីភ្នំពេញ។
  - ប្រជាជនទិញដីស្តុកដោយមិនបានប្រើប្រាស់។
  - ការរំលោភយកដីសាធារណៈរបស់រដ្ឋ។
  - ការយល់ដឹងពីច្បាប់ភូមិបាលនៅមានកម្រិត។
  - ធនធានមនុស្សពាក់ព័ន្ធការងារបច្ចេកទេសនិងការយល់ដឹងនៅមានកម្រិត។
  - ខ្វះឧបករណ៍ចុះធ្វើការសិក្សានៅតំបន់គោលដៅ។
  - ឯកសារវិភាគទិន្នន័យលើការប្រើប្រាស់ដីនៅមានកម្រិត។
- **ដំណោះស្រាយ**
  - ចុះបញ្ជីដីជូនប្រជាពលរដ្ឋ និងចុះបញ្ជីដីបន្ត។
  - សិក្សាគម្រោងប្លង់មេរាជធានីភ្នំពេញនិងធ្វើបច្ចុប្បន្នភាព។
  - ចុះត្រួតពិនិត្យការដ្ឋានសំណង់។
  - ដោះស្រាយវិវាទដីធ្លីនិងវិវាទសំណង់។
  - ផ្សព្វផ្សាយច្បាប់អនុក្រឹត្យលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធដីធ្លីនិងសំណង់។

## ២.៣.២ ស្ថានភាពបរិស្ថាន

### ក. ស្ថានភាពទូទៅនិងបញ្ហាប្រឈម

ក្នុងបច្ចុប្បន្នភាពរាជធានីភ្នំពេញបានបោះជំហានយ៉ាងឆាប់រហ័សឆ្ពោះទៅកាន់ ការអភិវឌ្ឍគ្រប់វិស័យ ដែលធ្វើ អោយជីវភាពរស់នៅរបស់ប្រជាពលរដ្ឋកាន់តែប្រសើរឡើងពីមួយថ្ងៃទៅមួយថ្ងៃ។ ហើយទន្ទឹមនឹងនេះ បញ្ហាបរិស្ថានបានក្លាយជាបញ្ហាក្តៅ នឹងមានផលប៉ះពាល់យ៉ាងជាក់លាក់ទៅលើជីវភាពរស់នៅរបស់ប្រជាពលរដ្ឋក្នុងបណ្តាឆ្នាំចុងក្រោយនេះ។ បញ្ហាបរិស្ថានមួយចំនួនមានដូចខាងក្រោមនេះ ៖

### ខ. ការគ្រប់គ្រងសំណល់រឹង

បរិមាណសំណល់ កើនឡើងជាប្រចាំពីមួយថ្ងៃទៅមួយថ្ងៃដែលធ្វើឱ្យមានការព្រួយបារម្ភចំពោះបញ្ហាទុកដាក់សំណល់រឹងទាំងនេះទោះបីជាការផ្តល់សេវាបានល្អប្រសើរមួយភាគធំក៏ដោយ ក៏នៅតែមានបញ្ហាប្រឈមដែលត្រូវយកចិត្តទុកដាក់ដូចជាការប្រើប្រាស់ទីលានចាក់សំរាមជាដើម។ ដំណោះស្រាយបញ្ហានេះរាជធានីភ្នំពេញបានរៀប ចំយុទ្ធសាស្ត្រកាត់បន្ថយសំណល់ ជាជំហានៗ ដោយចាប់ផ្តើមពីការផ្តល់ការអប់រំដល់ប្រជាពលរដ្ឋម្ចាស់មូលដ្ឋានផលិតកម្ម អាជីវកម្មសេវាកម្មលើការគ្រប់គ្រងសំរាមរបស់ខ្លួនតាមរយៈការញែកការទុកដាក់ក្នុងថង់ឬធុងសំរាមឱ្យបានត្រឹមត្រូវនិងការបញ្ចេញសំរាមទៅតាមប្រភេទ និងពេលវេលាដែលបានកំណត់ដើម្បីងាយស្រួលក្នុងការប្រមូលដឹកជញ្ជូននិងងាយស្រួលក្នុងការកែច្នៃការប្រើប្រាស់ឡើងវិញ និងគួបផ្សំដោយអនុវត្តវិធានការច្បាប់តាមរយៈការចេញលិខិតណែនាំឬផាកពិន័យចំពោះបុគ្គលឬមូលដ្ឋានដែលអនុវត្តផ្ទុយពីការណែនាំឬច្បាប់បានកំណត់។

### គ. ស្ថានភាពបំពុលទឹក

គុណភាពទឹកសាធារណៈមានការធ្លាក់ចុះ ដោយសារបច្ចុប្បន្ននេះសំណល់រាវប្រភេទទឹកស្អុយដែលមកពីការប្រើប្រាស់បង្គន់ និងផ្នែកផលិតកម្មដែលចេញពីប្រភពនានានៅក្នុងរាជធានីភ្នំពេញបានបង្ហូរចូលទៅក្នុងប្រភពទឹកធម្មជាតិបឹងប្រឡាយទន្លេដោយពុំបានធ្វើប្រតិកម្មសំអាតជាមុនឬការធ្វើប្រតិកម្មនោះមិនសមស្របតាមលក្ខណៈបច្ចេកទេស។ ជាហេតុធ្វើឱ្យកំហាប់សារធាតុបំពុលក្នុងប្រភពទឹកសាធារណៈមានការកើនឡើងគួរឱ្យបារម្ភ។

### ឃ. ស្ថានភាពគុណភាពខ្យល់

ស្ថានភាពនៃការបំពុលខ្យល់ក្នុងរាជធានីភ្នំពេញមានប្រភពមកពី

- ប្រភពចល័ត ការបំភាយផ្សែងចេញពីយានយន្តការហុយធូលីដីបណ្តាលមកពីការសាងសង់លូប្រឡាយ និងការដឹកជញ្ជូនសម្ភារៈ (សំណង់ដី ដីខ្សាច់ ថ្ម...)

- ប្រភពអចល័ត ការហុយធូលីដីចេញពីការដ្ឋានសំណង់គ្រប់ប្រភេទ ការឆេះសំរាមនៅទីលានបញ្ចេញផ្សែងចេញពីរោងចក្រ សហគ្រាស ការដ្ឋានខ្សាច់ អគ្គីភ័យ ការដុតសំណល់វេជ្ជសាស្ត្រ ឡឥដ្ឋ ការដុតសំរាមតាមទីសាធារណៈ...។

▪ **បញ្ហាប្រឈម**

- ការយល់ដឹងរបស់ប្រជាជននៅមានកម្រិតទៅលើការទុកដាក់សំណល់
- ប្រជាពលរដ្ឋមិនទាន់កែប្រែឥរិយាបថនៃការទទួលខុសត្រូវទៅលើសំរាមរបស់ខ្លួននៅឡើយ
- ប្រជាពលរដ្ឋមិនទាន់យល់នូវបទដ្ឋានគតិយុត្តលើវិស័យបរិស្ថាន
- ការកើនឡើងនូវបរិមាណសំរាមសំណល់រឹងមួយថ្ងៃទៅមួយថ្ងៃ
- ការប្រើសេវាប្រមូលដឹកជញ្ជូនសំរាមសំណល់រឹងពុំទាន់បានគ្របដណ្តប់ទូទាំងរាជធានីភ្នំពេញ
- ការទុកដាក់សំរាមសំណល់រឹងនៅទីលានចាក់សំរាមមិនត្រឹមត្រូវតាមលក្ខណៈបច្ចេកទេស
- ខ្វះការគាំទ្រនិងលើកទឹកចិត្តដល់សកម្មភាពកែច្នៃសំរាមសំណល់រឹង
- នៅតាមប្រភពបំពុលទឹកមួយចំនួនមិនបានបំពាក់អាងប្រតិកម្មសំអាតសំណល់រាវ
- មានការសាងសង់លំនៅដ្ឋានចូលក្នុងដីប្រឡាយបឹងនិងទន្លេ
- ការមិនបានរៀបចំបំពាក់បច្ចេកទេសសម្អាតផ្សែងនិងធូលីភាគល្អិតនៅតាមប្រភពបំពុល
- ការដុតសំរាមសំណល់រឹងនៅតាមទីវាល។

▪ **ដំណោះស្រាយ**

- បង្កើនការអប់រំនិងផ្សព្វផ្សាយគ្រប់រូបភាពដល់ប្រជាពលរដ្ឋឱ្យមានការយល់ដឹងលើការងារគ្រប់គ្រងបរិស្ថាន
- គាំទ្រនិងលើកទឹកចិត្តដល់ការកែច្នៃសំរាម
- ត្រូវបង្កើនសេវាប្រមូលនិងដឹកជញ្ជូនសំណល់គ្រប់ប្រភេទប្រកបដោយប្រសិទ្ធភាព
- ជំរុញប្រភពបំពុលឱ្យបំពាក់បច្ចេកទេសសម្អាតសំណល់រាវនិងខ្យល់
- បង្កើនប្រសិទ្ធភាពលើការងារត្រួតពិនិត្យប្រភពបំពុលបរិស្ថាន
- ជំរុញគ្រប់មូលដ្ឋានសិប្បកម្ម សេវាកម្មអាជីវកម្ម និងផលិតកម្ម ត្រូវអនុវត្តច្បាប់ និងលិខិតបទដ្ឋានគតិយុត្តនានានៃវិស័យបរិស្ថាន

**ខ. ការប្រែប្រួលអាកាសធាតុ**

ការប្រែប្រួលអាកាសធាតុបានធ្វើឱ្យរបបទឹកភ្លៀងមិនទៀងទាត់ ព្រមទាំងកំដៅថ្ងៃកើនឡើងផងដែរ។ ដើម្បីទប់ទល់នឹងស្ថានភាពបែបនេះរដ្ឋបាលរាជធានីភ្នំពេញបានអនុវត្តនូវវិធានការនិងធ្វើសកម្មភាពជាច្រើនសម្រាប់

បន្ទាំដូចជាការជួសជុលស្ពាននិងពង្រីកប្រព័ន្ធលូនិងការរៀបចំកសាងស្ថានីយបូមទឹកបន្ថែម។ ក្រៅពីនេះការត្រៀមរៀបចំបង្ការដើម្បីផ្សព្វផ្សាយដល់ប្រជាពលរដ្ឋឱ្យយល់ដឹងពីការប្រែប្រួលអាកាសធាតុ។ សីតុណ្ហភាពជាធម្មតាស្ថិតនៅចន្លោះចាប់ពី ២២ ទៅ ៣៥ °C (៧២ ទៅ ៩៥ °F) និងធាតុអាកាសគឺស្ថិតនៅក្រោមឥទ្ធិពលមូសុងនិវត្តន៍។ មូសុងនិរតីបក់ចូលដីគោកនាំមកនូវខ្យល់ផ្ទុកដោយសំណើមពីឈូងសមុទ្រថៃ និង មហាសមុទ្រឥណ្ឌាពីខែឧសភា ដល់តុលា។ មូសុងឦសានបក់នាំរដូវប្រាំងមក ឱ្យបន្តពីខែ វិច្ឆិកា ដល់មីនា។ ទីក្រុងនេះរងនូវការធ្លាក់ភ្លៀងខ្លាំងបំផុតចាប់ពីខែកញ្ញា ដល់ តុលា ដែលមានរយៈកាលក្តៅហែងក្នុងខែមករា និង កុម្ភៈ។ ទីក្រុងនេះមានពីររដូវ។ រដូវវស្សាដែលមានចាប់ពីខែឧសភា ដល់ តុលាបង្ហាញឱ្យឃើញសីតុណ្ហភាពខ្ពស់នាំមកនូវដោយសំណើមខ្ពស់។ រដូវប្រាំងបន្តចាប់ពីខែវិច្ឆិកា ដល់ មេសា នៅពេលដែលសីតុណ្ហភាពអាចធ្លាក់មកដល់ ២២ °C (៧២°F)។ ប៉ុន្តែសីតុណ្ហភាពអាចឈានមកដល់ ៤០ °C (១០៤ °F) ក្នុងខែមេសា។ ខែល្អបំផុតដើម្បីមកទស្សនាទីក្រុងនេះគឺខែវិច្ឆិកា ដល់ កុម្ភៈនៅពេលសីតុណ្ហភាពមានសំណើម និង ភ្លៀងធ្លាក់មានកំរិតទាបជាងគេ។

### ២.៣.៣ ការងារធនធានទឹក

មន្ទីរធនធានទឹកនិងឧតុនិយមរាជធានីភ្នំពេញមានបុគ្គលិកសរុបចំនួន ២៤ រូបស្រី ៥ រូប។ ក្នុងនោះមន្ត្រីវិស្វករចំនួន ១៤ រូបស្រី ២ រូប មន្ត្រីបច្ចេកទេសមធ្យមចំនួន ៨ រូបស្រី ៣ រូបនិងកម្មករសាមញ្ញចំនួនពីររូបស្រីមួយរូប។[29] មន្ត្រីមានមន្ត្រីជំនាញដែលអាចបំពេញការងារបានតាមតម្រូវការ និងមានបំពាក់នូវឧបករណ៍មួយចំនួនដូចជាឧបករណ៍ គូប៉ូសម្រាប់បម្រើការងារសិក្សាគ្រោងប្លង់ និងម៉ាស៊ីនបូមទឹកសម្រាប់អន្តរាគមន៍គ្រោះរាំងស្ងួតទឹកជំនន់ផងដែរ។ បច្ចុប្បន្នមន្ទីរបានខិតខំជួសជុលថែទាំស្ពារ និងសាងសង់ប្រព័ន្ធធារាសាស្ត្រឡើងវិញនឹងបន្តដឹកនាំមន្ត្រីជំនាញចុះសិក្សាវាស់វែងលើគម្រោងស្ពារប្រឡាយស្រោចស្រពសំណង់លូប្រឡាយរំដោះទឹក និងប្រព័ន្ធធារាសាស្ត្រដែលមានស្រាប់។ល។ជាមួយគ្នានេះដែរមន្ទីរបានត្រៀមជួយអន្តរាគមន៍បូមទឹកសង្គ្រោះស្រូវប្រាំងនិងវស្សាដែលជួបគ្រោះរាំងស្ងួតនៅពេលខាងមុខ។

ទន្ទឹមនឹងនេះមន្ទីរនៅមានបញ្ហាខ្វះខាតមធ្យោបាយធ្វើដំណើរ និងថវិកាមានកម្រិតដែលចាត់ទុកជាកង្វល់មួយជាពិសេសនៅពេលជួបប្រទះស្ថានភាពរាំងស្ងួតរយៈពេលមធ្យម និងវែងដែលប៉ះពាល់ដល់ផលដំណាំស្រូវបន្លែបង្ការផ្សេងៗព្រមទាំងសត្វពាហនៈផងដែរ។ ផ្ទៃដីស្រោចស្រពស្រែវស្សាក្នុងផែនការចំនួន ៨.៧៩៩ ហ.ត និងស្រូវប្រាំងចំនួន ៩៨០ ហ.ត បានទឹកស្រោចស្រពពីប្រភពទឹកស្ទឹងព្រែកត្នោតបឹងតាមោកនិងបឹងសំពោងដែលកំពុងរងការគំរាមកំហែងពីបម្រែបម្រួលអាកាសធាតុ។ ម្យ៉ាងទៀតប្រព័ន្ធធារាសាស្ត្រដែលមានស្រាប់រួមមាន

[29] របាយការណ៍សមិទ្ធផលមន្ទីរធនធានទឹករាជធានីភ្នំពេញ

ប្រឡាយទំនប់សំណង់ទ្វារទឹក ដែលទទួលទឹកពីស្ទឹងបឹងទាំងនោះបានខូចខាតដោយសារខ្វះការថែទាំនិងរង គ្រោះទឹកជំនន់នាពេលកន្លងមកតែត្រូវធ្វើការជួសជុលស្តារឡើងវិញ។ ជាមួយគ្នានេះក៏មានការជន់លិចស្រែ ដំណាំនិងផ្ទះសម្បែងប្រជាពលរដ្ឋមួយចំនួនដោយសារប្រព័ន្ធដោះទឹក គោករាក់ ដែលចាំបាច់ត្រូវស្តារឡើងវិញ និងមានការរំលោភយកដីមាត់បឹង និងប្រឡាយពីសំណាក់ប្រជាពលរដ្ឋដោយមិនមានការទប់ស្កាត់ពីអាជ្ញាធ រមូលដ្ឋានដែលបញ្ហានេះត្រូវបានដោះស្រាយជាបណ្តើរដោយបោះវែងបោះបង្គោល និងសាងសង់ទំនប់ការពារ រក្សាផ្ទៃបឹងទុកឱ្យបានច្បាស់លាស់ទន្ទឹមនេះការងារឧតុនិយម និងផលសាស្ត្រដែលត្រូវបានតាមដានពីកម្ពស់ ទឹកនឹងទឹកទន្លេក៏នៅមានជួបបញ្ហាខ្វះខាត ដោយសារមិនទាន់មានឧបករណ៍គ្រប់គ្រាន់និងបច្ចេកទេសនៅមាន កម្រិត។ ជាមួយបញ្ហាប្រឈមទាំងនេះសកម្មភាពជាអាទិភាពសំខាន់ៗដែលត្រូវដោះស្រាយចំពោះមុខរួមមាន៖

- បន្តជួសជុលថែទាំប្រព័ន្ធធារាសាស្ត្រដែលមានស្រាប់
- ស្តារប្រព័ន្ធប្រឡាយរំដោះទឹកហ្នឹងអាងស្តុកទឹក
- ត្រៀមរៀបចំអន្តរាគមន៍បូមទឹកសង្គ្រោះស្រូវប្រាំងនិងវស្សា
- បន្តសាងសង់ទំនប់កំណត់ព្រំរក្សាផ្ទៃបឹង
- ដំឡើងឧបករណ៍តម្រងទឹកភ្លៀង

▪ **បញ្ហាប្រឈម**

- ខ្វះទឹកស្រោចស្រពនារដូវប្រាំងនិងគ្រោះរាំងស្ងួត
- ប្រព័ន្ធធារាសាស្ត្រខូចខាតនិងខ្វះការចូលរួមថែទាំពីប្រជាពលរដ្ឋ
- មានការជន់លិចទឹកនារដូវវស្សា
- មានការរំលោភលើដីចំណីបឹងនិងប្រឡាយ
- ខ្វះមធ្យោបាយនិងឧបករណ៍ច្រមុះទឹកភ្លៀង។

ជាមួយបញ្ហាប្រឈមខាងលើនេះសកម្មភាពជាអាទិភាពសំខាន់ៗដែលត្រូវដោះស្រាយនៅចំពោះមុខរួមមាន៖ (១)ជុលថែទាំប្រព័ន្ធធារាសាស្ត្រដែលមានស្រាប់ (២) ស្តារប្រព័ន្ធប្រឡាយរំដោះទឹកនិងអាងស្តុកទឹក (៣) ត្រៀម រៀបចំអន្តរាគមន៍បូមទឹកសង្គ្រោះស្រូវប្រាំងនិងវស្សា (៤) បន្តសាងសង់ទំនប់កំណត់ព្រំរក្សាផ្ទៃបឹង (៥) ដំឡើង ឧបករណ៍តម្រងទឹកភ្លៀង។

## ២.៤ ស្ថានភាពនៃការគ្រប់គ្រងរដ្ឋបាលនិងសន្តិសុខសណ្តាប់ធ្នាប់សាធារណៈ

ចាប់តាំងពីថ្ងៃបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានីខេត្តក្រុងស្រុកខណ្ឌអាណត្តិទី០៣ កាលពីថ្ងៃទី២៦ ខែឧសភា ឆ្នាំ២០១៩ មករដ្ឋបាលរាជធានីបានកំពុងខិតខំយកចិត្តទុកដាក់អនុវត្តតាមកម្មវិធីនយោបាយនិង យុទ្ធសាស្ត្រចតុកោណដំណាក់កាលទី០៤ របស់រាជរដ្ឋាភិបាលកម្ពុជាដែលមានអភិបាលកិច្ចល្អជាស្នូលឱ្យ

ទទួលបានជោគជ័យក្នុងនោះសំខាន់គឺការអនុវត្តកំណែទម្រង់រដ្ឋបាលនៅថ្នាក់ក្រោមជាតិការអនុវត្តច្បាប់ប្រឆាំងអំពើពុករលួយ និងការអនុវត្តគោលនយោបាយ "ភូមិ-ឃុំមានសុវត្ថិភាព" ព្រមទាំងខិតខំធានាឱ្យបានរឹងមាំនូវស្ថិរភាពនយោបាយសន្តិសុខ សុវត្ថិភាពនិងសណ្តាប់ធ្នាប់សង្គមនៅក្នុងរាជធានីភ្នំពេញ។ រដ្ឋបាលរាជធានីភ្នំពេញបានយកចិត្តទុកដាក់លើការងារសំខាន់ៗដែលទាក់ទងស្ថានភាពនៃការគ្រប់គ្រងរដ្ឋបាលសន្តិសុខសណ្តាប់ធ្នាប់សាធារណៈនៅក្នុងផែនការអភិវឌ្ឍមានដូចខាងក្រោម៖

**២.៤.១ ការងារអភិបាលកិច្ច**

**ក. ការផ្តល់សេវាសាធារណៈ**

រដ្ឋបាលរាជធានីភ្នំពេញ បានដាក់ឱ្យដំណើរការអង្គភាពច្រកចេញចូលតែមួយស្របពេលខ្លឹមសារអនុក្រឹត្យលេខ១៨អនក្រ.បកចុះថ្ងៃទី ០៨ ខែកុម្ភៈ ឆ្នាំ២០១៧ ស្តីពីការបង្កើតយុទ្ធការច្រកចេញចូលតែមួយ[30] សម្រាប់ការផ្តល់សេវារដ្ឋបាលនៅថ្នាក់ក្រោមជាតិ ក្នុងការអនុវត្តការងារផ្តល់សេវារដ្ឋបាលជូនរាជធានីភ្នំពេញបានឈរលើគោលការណ៍នៃការផ្តល់សេវាឆាប់រហ័សរាជរស់និងមានតម្លាភាពនិងប្រកាសលេខ ៣៨៧១ ប្រ.កចុះថ្ងៃទី០៨ ខែសីហា ឆ្នាំ២០១៨[31] របស់ក្រសួងមហាផ្ទៃស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃអង្គភាពច្រកចេញចូលតែមួយរាជធានីខេត្តនិងតាមអនុក្រឹត្យនេះរាជរដ្ឋាភិបាល បានធ្វើប្រតិភូកម្មមុខងារមួយចំនួនមករដ្ឋបាលថ្នាក់ក្រោមជាតិដែលមាន ១៥ វិស័យក្នុងនោះមានការងារនីត្យានុកូលកម្មការងាររដ្ឋបាល វិស័យសុខាភិបាល វិស័យទេសចរណ៍ វិស័យសាធារណការនិងដឹកជញ្ជូន វិស័យវប្បធម៌ វិស័យវិចិត្រសិល្បៈ វិស័យព័ត៌មាន វិស័យបរិស្ថាន វិស័យឧស្សាហកម្មនិងសិប្បកម្ម វិស័យរ៉ែនិងថាមពល វិស័យពាណិជ្ជកម្ម វិស័យរៀបចំដែនដីនគរូបនីយកម្មនិងសំណង់ វិស័យកសិកម្មរុក្ខាប្រមាញ់និងនេសាទ និង វិស័យការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ។

**ខ. ការចូលរួម**

បច្ចុប្បន្ននេះរាជធានីភ្នំពេញ ទទួលបានការគាំទ្រការចូលរួមសហការអនុវត្តពីគ្រប់ស្ថាប័នអង្គភាពពាក់ព័ន្ធខណ្ឌសង្កាត់និងប្រជាពលរដ្ឋនៅក្នុងមូលដ្ឋាន ។ ការចូលរួមនេះគឺជាកត្តាសំខាន់ក្នុងការអភិវឌ្ឍព្រោះរដ្ឋបាលរាជធានីតែឯងមិនអាចធ្វើការអភិវឌ្ឍដ៏ធំនេះបានទេ។ ផ្តើមចេញពីគោលការណ៍នេះការចូលរួមរបស់ប្រជាពលរដ្ឋមានះការស្តាបនាផ្លូវហើយមានសប្បុរសជនមួយចំនួនបានចូលរួម ១០០% តែម្តងនិងទុនបដិភាគផ្សេងៗទៀតបានតាមមូលដ្ឋាន។ ក្រៅពីនេះប្រជាពលរដ្ឋក៏បានចូលរួមក្នុងការធ្វើផែនការអភិវឌ្ឍន៍ក្នុងមូលដ្ឋាន(សង្កាត់)ប្រជាការពារការរិះគន់ស្ថាបនានិងការចូលរួមផ្សេងៗទៀតផងដែរ។

[30] អនុក្រឹត្យលេខ១៨អនក្របក.

[31] ប្រកាសលេខ ៣៨៧១ ប្រក.

**គ. គណនេយ្យភាពនិងតម្លាភាព**

ដើម្បីឱ្យការបំពេញរដ្ឋបាល និងការផ្តល់សេវាឱ្យកាន់តែល្អប្រសើរថែមទៀតនោះរដ្ឋបាលរាជធានីបាន រៀបចំប្រព័ន្ធផ្តល់ព័ត៌មានត្រឡប់តាមរយៈប្រអប់សំបុត្របណ្តឹងប្រជាពលរដ្ឋ ព័ត៌មានទាន់ហេតុការណ៍ និង ប្រព័ន្ធព័ត៌មានវិទ្យា។ ទន្ទឹមនឹងនេះ រដ្ឋបាលរាជធានីបានរៀបចំចាត់ចែងដល់មន្ត្រី ដែលត្រូវប្រកាសទ្រព្យសម្បត្តិ បំពេញបែបបទឱ្យទាន់ពេលវេលា។

**២.៤.២ ការអភិវឌ្ឍមណ្ឌលធនធានមនុស្ស**

ការអភិវឌ្ឍធនធានមនុស្ស គឺជាតម្រូវការចាំបាច់របស់រដ្ឋបាលរាជធានីភ្នំពេញនឹងបន្តគាំទ្រដល់ការអភិវឌ្ឍ សមត្ថភាពដល់រដ្ឋបាលខណ្ឌនិងសង្កាត់ក្នុងគោលបំណងបង្កើនសមត្ថភាពដល់ក្រុមប្រឹក្សា និងគណៈអភិបាល មន្ត្រី និងបុគ្គលិកសំដៅពង្រឹងការអនុវត្តតួនាទីនិងក្លាហាននិងភារកិច្ចរបស់ខ្លួនក្នុងការផ្តល់សេវាសាធារណៈជូន ប្រជាពលរដ្ឋប្រកបដោយប្រសិទ្ធភាពនិងគុណភាព។ ដើម្បីគាំទ្រដល់ដំណើរការអភិវឌ្ឍសមត្ថភាពក្រុមប្រឹក្សា រាជធានីភ្នំពេញបានអនុម័ត និងដាក់ឱ្យដំណើរការតាមរយៈការចេញសេចក្តីសម្រេចលេខ ៣២៩ សររ.គរម ចុះ ថ្ងៃទី២២ ខែសីហា ឆ្នាំ២០១៥ ស្តីពីការបង្កើតមណ្ឌលអភិវឌ្ឍន៍ធនធានមនុស្សខេត្តរាជធានីភ្នំពេញ។[32]

ទោះបីជាមណ្ឌលអភិវឌ្ឍន៍នេះបានបង្កើតហើយក៏ដោយ ក៏មានបញ្ហាប្រឈមជាច្រើនដែលកំពុងជួប ប្រទះដូចជាការងារកំណែទម្រង់តាមបែបវិមជ្ឈការ ផ្តល់សេវាកម្មការគ្រប់គ្រងរដ្ឋបាលនិងការគ្រប់គ្រងបុគ្គលិក ដែលទាមទារឱ្យមានការយល់ដឹងស៊ីជម្រៅអំពីកិច្ចការទាំងនេះ។ ដើម្បីឱ្យការអនុវត្តកាន់តែមានប្រសិទ្ធភាពប៉ុន្តែ សមត្ថភាពមន្ត្រីនៅមានកម្រិតត្រូវ៖

- ការទុកដាក់ឯកសារនិងការរៀបចំប្រព័ន្ធឆ្លើយតបពិសេសតាមតម្រូវការរបស់ស្ថាប័ន ដល់ប្រជាពលរដ្ឋនៅ មានការខ្វះខាត
- ផែនការបណ្តុះបណ្តាលរបស់រាជធានី ខណ្ឌ និងសង្កាត់នៅពុំទាន់រៀបចំឱ្យល្អ
- ពុំទាន់មានគ្រូបង្គោលដែលមានសមត្ថភាពគ្រប់គ្រាន់សម្រាប់បណ្តុះបណ្តាលនៅថ្នាក់រាជធានី។

**២.៤.៣ វិស័យមុខងារសាធារណៈ**

មន្ទីរមុខងារសាធារណៈរាជធានីភ្នំពេញ បានអនុវត្តគោលនយោបាយនិងផែនការការងាររបស់ក្រសួងមុខ ងារសាធារណៈដើម្បីធានានូវការអភិវឌ្ឍសេដ្ឋកិច្ចសង្គម និងការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោម ជាតិ។ មន្ទីរមុខងារសាធារណៈរាជធានីភ្នំពេញមានតួនាទីភារកិច្ចជួយគណៈអភិបាល និងក្រុមប្រឹក្សារាជធានី ក្នុងការគ្រប់គ្រងមន្ត្រីរាជការស៊ីវិលតាមការធ្វើប្រតិភូកម្មអំណាចដល់ថ្នាក់ក្រោមជាតិលើ វិស័យមុខងារសា-

[32] សេចក្តីសម្រេចលេខ ៣២៩ សររគរម.

ធារណៈ។ ដូចជាការការពារផលប្រយោជន៍មន្ត្រីរាជការស៊ីវិលផ្អែកតាមច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនិងលិខិតបទដ្ឋានគតិយុត្តជាធរមាន។ ម្យ៉ាងទៀតបានពិនិត្យផ្ទៀងផ្ទាត់ផ្តល់យោបល់គ្រប់គ្រងតាមដាននិងពិនិត្យលើសំណើនានាពាក់ព័ន្ធនឹងការប្រែប្រួលស្ថានភាពរដ្ឋបាល និងគ្រួសាររបស់មន្ត្រីរាជការស៊ីវិលនិងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងការគ្រប់គ្រងមន្ត្រីរាជការថ្នាក់ក្រោមជាតិ តាមការផ្ទេរភារកិច្ចពីក្រសួង។ រៀបចំផែនការបណ្តុះបណ្តាលធនធានមនុស្សនិងសម្របសម្រួលបញ្ជូនមន្ត្រីរាជការទៅទទួលការបណ្តុះបណ្តាល។ ពិនិត្យផ្តល់យោបល់លើសំណើសុំប្រើប្រាស់មន្ត្រីក្របខណ្ឌមន្ត្រីជាប់កិច្ចសន្យានិងបុគ្គលិកអណ្តែតនៅថ្នាក់ក្រោមជាតិ។ ពិនិត្យផ្ទៀងផ្ទាត់និងរៀបចំបៀវត្សរបស់មន្ត្រីរាជការមន្ត្រីជាប់កិច្ចសន្យា និងបុគ្គលិកអណ្តែតនៅថ្នាក់ក្រោមជាតិបានទាន់ពេលវេលាស្របតាមសារាចរណែនាំរបស់រាជរដ្ឋាភិបាលកម្ពុជា។

រាជរដ្ឋាភិបាលកម្ពុជាបានចេញសារាចរណែនាំលេខ០១ សរណន ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០០៦ ស្តីពីការអនុវត្តផែនការក្របខណ្ឌប្រចាំឆ្នាំក្នុងនោះបានចែងច្បាស់លាស់អំពីលក្ខខណ្ឌចំពោះមន្ត្រីរាជការដែលមានសិទ្ធិស្នើសុំប្តូរទីកន្លែងបម្រើការងារមករាជធានីភ្នំពេញ។[33]

## ២.៤.៤ ការគ្រប់គ្រងដែនដីនិងការគ្រប់គ្រងស្ថិតិ

បច្ចុប្បន្ននេះរាជធានីភ្នំពេញមាន ១៤ខណ្ឌ ១០៥សង្កាត់ និង ៩៥៣ភូមិ ហើយមានរចនាសម្ព័ន្ធច្បាស់លាស់ស្របតាមច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានីខេត្តក្រុងស្រុកខណ្ឌ និងច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំសង្កាត់។ ការចេញចូលស្នាក់នៅរបស់ប្រជាពលរដ្ឋនៅគ្រប់មូលដ្ឋានជាពិសេសការស្នាក់នៅបណ្តោះអាសន្នបានគ្រប់គ្រងយ៉ាងហ្មត់ចត់ និងបានដល់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរឱ្យប្រជាពលរដ្ឋអាយុចាប់ពី ១៥ ឆ្នាំឡើងទៅឱ្យបានគ្រប់គ្នា។ បានចុះបញ្ជីអត្រានុកូលដ្ឋានឱ្យប្រជាពលរដ្ឋនឹងខិតខំលុបបំបាត់ឱ្យបាននូវកំហុសឆ្គងលើការងារនេះជាពិសេសលើការងារចុះបញ្ជីកំណើត។ ការគ្រប់គ្រងជនបរទេសចូលមកស្នាក់នៅឬមកធ្វើទស្សនកិច្ចក្នុងរាជធានីជាភារកិច្ចដែលបាន និងកំពុងយកចិត្តទុកដាក់ដើម្បីភ្ជាប់ឱ្យបានការកែប្រែប្រួលរបស់ជនអន្តោប្រវេសន៍ក្នុងមូលដ្ឋានដោយជំរុញការធ្វើវិញ្ញាបនបត្រទទួលស្គាល់ឬប័ណ្ណស្នាក់នៅអចិន្ត្រៃយ៍ឱ្យបានគ្រប់គ្នានិងមានវិធានការម៉ឺងម៉ាត់ចំពោះអ្នកស្នាក់នៅល្មើសច្បាប់។

រដ្ឋបាលរាជធានីភ្នំពេញបានអភិវឌ្ឍន៍ និងបន្តធ្វើផែនការជាមួយមន្ទីររៀបចំដែនដីនគរូបនីយកម្មសំណង់និងសូរិយោដីរាជធានីបានកែសម្រួលប្លង់ប្រើប្រាស់ដីធ្លី និងរៀបចំគម្រោងប្លង់អភិវឌ្ឍន៍តំបន់ភាគខាងជើងនឹងបន្តការសិក្សាគម្រោងប្លង់អភិវឌ្ឍន៍តំបន់ភាគខាងកើត និងខាងលិចរាជធានីសិក្សាប្លង់អភិវឌ្ឍន៍តំបន់ព្រែកប្រានិងតំបន់ភាគខាងត្បូង(ប្លុកបឹងទំពុននិងបឹងជើងឯក)។

[33] សារាចរណែនាំលេខ០១ សរណន

ចំពោះកិច្ចសហប្រតិបត្តិការ ជាមួយទីក្រុងនានានៃបណ្តាប្រទេសក្នុងសហគមន៍អន្តរជាតិរាជធានីភ្នំពេញបានទទួលលទ្ធផលជាវិជ្ជមាននូវជំនួញបច្ចេកទេស និងបទពិសោធន៍សម្រាប់ការអភិវឌ្ឍរាជធានីក៏ដូចជាការបណ្តុះបណ្តាលធនធានមនុស្សនិងទស្សនកិច្ចសិក្សា។

**២.៤.៥ ការធានាសន្តិសុខនិងសណ្តាប់ធ្នាប់សាធារណៈ**

រាជធានីភ្នំពេញបានកំណត់យកវិស័យសន្តិសុខជាតិ ជាវិស័យអាទិភាពមួយដ៏សំខាន់ធ្វើជាគ្រឹះគ្របដណ្តប់ និងជាស្នូលនៃការអនុវត្តយុទ្ធសាស្ត្រចតុកោណ ដំណាក់កាលទី៤[34] របស់រាជរដ្ឋាភិបាលឱ្យទទួលបានជោគជ័យពង្រឹងស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច និងការអភិវឌ្ឍរាជធានីភ្នំពេញលើគ្រប់វិស័យបង្កើនទំនុកចិត្តដល់អ្នកវិនិយោគគិនភ្ញៀវ ទេសចរនិងប្រជាពលរដ្ឋរស់នៅប្រកបមុខរបររកស៊ីក្នុងភាពសុខដុមរមនា។ ព្រះរាជាណាចក្រកម្ពុជាមិនមានការកើតឡើងនូវអំពើភេរវកម្មឡើយហើយក៏មិនមែនជាប្រទេសដែលផលិតគ្រឿងញៀនដែរ។ ប៉ុន្តែកម្ពុជាក៏ដូចជាប្រទេសមួយចំនួននៅក្នុងតំបន់របស់យើង គឺតែងតែទទួលរងនូវឥទ្ធិពលនៃគ្រឿងញៀនជាពិសេសការលួចធ្វើចរាចរណ៍ឆ្លងកាត់នៅប្រទេសជិតខាងនិងការជួញដូរប្រើប្រាស់ក្នុងស្រុក។ ក្រៅពីបញ្ហាគ្រឿងញៀនក៏នឹងមានប្រភេទបទល្មើសឆ្លងដែនមានការចាត់តាំងមួយចំនួនទៀត ដូចជាបទល្មើសហិរញ្ញវត្ថុអំពើជួញដូរមនុស្សជាពិសេសការនាំស្ត្រីកម្ពុជាទៅបរទេស តាមរូបភាពអាពាហ៍ពិពាហ៍ក្លែងក្លាយឬផ្ទុយពីឆន្ទៈបានកើតឡើងគួរឱ្យកត់សម្គាល់។ ជាមួយគ្នានេះការជ្រៀតចូលនៃបទល្មើសបច្ចេកវិទ្យាបាននិង កំពុងបំពុលបរិយាកាសសន្តិសុខសណ្តាប់ធ្នាប់ក្នុងសង្គមផងដែរជាពិសេសបទល្មើសចាប់ជំរិតតាមប្រព័ន្ធទូរគមនាគមន៍ (VoIP ) បញ្ហាទាំងនេះនគបាលកម្ពុជាបាននិងកំពុងតែសហការយ៉ាជិតស្និតជាមួយមន្ត្រីអនុវត្តច្បាប់នៃប្រទេសចិន។

រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជាក្រោមការដឹកនាំដ៏ឈ្លាសវៃរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** មានទស្សនវិស័យច្បាស់លាស់ និងមានការប្តេជ្ញាខ្ពស់បានធ្វើសមាហរណកម្មកម្ពុជាចូលក្នុងតំបន់និងពិភពលោក ដើម្បីរួមគ្នាលើកកម្ពស់កិច្ចសហប្រតិបត្តិការរក្សាសន្តិសុខ សណ្តាប់ធ្នាប់សង្គមក្នុងតំបន់ និងក្នុងប្រទេសខ្លួនជាពិសេសកិច្ចសហការទប់ស្កាត់ការរីករាលដាលនៃអំពើភេរវកម្ម ឧក្រិដ្ឋកម្មឆ្លងដែនបទល្មើសហិរញ្ញវត្ថុ បទល្មើសបច្ចេកវិទ្យាការជឿជួញដូរមនុស្ស ការជួញដូរដោយខុសច្បាប់នូវសារធាតុណាកូទីន គ្រឿងញៀនប៉ះពាល់សរសៃប្រសាទ សារធាតុសំយោគនិងកិច្ចការពារវិនិយោគិនបរទេស។ ទន្ទឹមគ្នានេះដែររាជរដ្ឋាភិបាលកម្ពុជាបានចេញនូវយុទ្ធសាស្ត្រជាច្រើនក្នុងការប្រឆាំងឧក្រិដ្ឋកម្មឆ្លងដែនគ្រប់ប្រភេទដូចជា៖

- ពង្រឹងកិច្ចការពារឱ្យបានគត់មត់នូវអធិបតេយ្យជាតិ បូរណៈភាពទឹកដី ការពាររដ្ឋធម្មនុញ្ញព្រះមហាក្សត្រ និង រាជរដ្ឋាភិបាលស្របច្បាប់លើកស្ទួយគោលនយោបាយសុខដុមនីយកម្ម ពង្រឹងសន្តិសុខផ្ទៃក្នុងរក្សា

[34] យុទ្ធសាស្ត្រចតុកោណ ដំណាក់កាលទី៤

សាមគ្គីភាព ឯកភាពផ្ទៃក្នុងជាតិ មិនទុកឱ្យមានការរំលោភបំពាន និងបំផ្លិចបំផ្លាញដោយប្រការណាមួយឡើយ ។

- បង្កើតយន្តការថ្នាក់ជាតិប្រឆាំងភេរវកម្ម ប្រឆាំងការជួញដូរមនុស្ស ជាពិសេសស្ត្រី និងកុមារ និងការប្រឆាំងគ្រឿងញៀនខុសច្បាប់ ។
- ដាក់ចេញគោលនយោបាយសាមគ្គីជាតិ ឯកភាពជាតិ សុខដុមនីកម្មមិនរើសអើងពូជសាសន៍ពណ៌សម្បុរ និងសាសនា ។
- កសាង និងធ្វើវិសោធនកម្មច្បាប់មួយចំនួន ពិសេសបានអនុម័តនូវក្រមព្រហ្មទណ្ឌ ដើម្បីប្រឆាំងឧក្រិដ្ឋកម្មឆ្លងដែននិងច្បាប់ប្រឆាំងបទល្មើសបច្ចេកវិទ្យា។ អនុវត្តតាមគោលនយោបាយ និងយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាល និងក្រោមការចង្អុលដឹកនាំរបស់ក្រសួងមហាផ្ទៃអគ្គស្នងការដ្ឋាននគរបាលជាតិបានដាក់ចេញយុទ្ធសាស្ត្រទាំង០៥ និងវិធានការសំខាន់ៗ ជាច្រើនសំដៅបង្ការ ទប់ស្កាត់ និងបង្ក្រាបនូវរាល់សកម្មភាពឧក្រិដ្ឋកម្មឆ្លងដែនគ្រប់ប្រភេទត្រូវបាននគរបាលជាតិកម្ពុជា កំពុងបានចាត់តាំងអនុវត្តគឺផែនការការពារសន្តិភាពជូនភ្ញៀវទេសចរណ៍ និងវិនិយោគិនបរទេស យុទ្ធនាការបង្ការ ទប់ស្កាត់ និងបង្ក្រាបអំពើលួចឆក់ពិសេសលួចឆក់ជនបរទេស និងយុទ្ធនាការពង្រឹងសន្តិសុខ សណ្តាប់ធ្នាប់ សុវត្ថិភាពសង្គម សំដៅធ្វើឱ្យស្ថានការណ៍សន្តិសុខ សណ្តាប់ធ្នាប់សង្គមមានភាពកាន់តែល្អប្រសើរ និងបានបង្កើនភាពកក់ក្តៅដល់ប្រជានពលរដ្ឋក៏ដូចជាភ្ញៀវទេសចរណ៍ និងវិនិយោគិនបរទេសផងដែរ ។
- បានជំរុញការអនុវត្តច្បាប់ចរាចរណ៍ផ្លូវគោកតាមរយៈការរឹតបន្តឹង ការអនុវត្តវិធានការត្រួតពិនិត្យ និងផាកពិន័យលើយានយន្តល្មើសច្បាប់ត្រួតពិនិត្យដើមទី ត្រួតពិនិត្យអ្នកបើកបរក្រោមឥទ្ធពលគ្រឿងស្រវឹងដែលបង្កគ្រោះថ្នាក់ចរាចរណ៍ បើកបរដឹកលើសចំណុះសំពីងសំពោងសំដៅកាត់បន្ថយអត្រាគ្រោះថ្នាក់ចរាចរ-ណ៍។ ជាមួយនេះបានយកចិត្តទុកដាក់ជំរុញការរៀបចំសណ្តាប់ធ្នាប់តាមដងផ្លូវសំខាន់ៗ ក្នុងរាជធានីភ្នំពេញចំណតជុំវិញផ្សារធំថ្មីសួនច្បាររមណីយដ្ឋាន និងទីសារជាណៈធ្វើឱ្យមានការរីកចម្រើនបន្ថែមមួយកម្រិតថែមទៀត ។
- ក្រៅពីនេះបានប្រមូលផ្តុំការពារប្រកបដោយសុវត្ថិភាពនូវរាល់ពិធីបុណ្យ និងបណ្តាព្រឹត្តការណ៍ជាតិ អន្តរជាតិសំខាន់ៗដែលប្រារព្ធធ្វើឡើងនៅរាជធានីភ្នំពេញ ចំនួន ២.០១៨លើក។ ចំពោះបញ្ហាបាតុកម្ម និងកូដកម្មភាគច្រើនជាការតវ៉ារបស់បញ្ហាជម្លោះដីធ្លី សិទ្ធិសំនៅដ្ឋាន បញ្ឈប់ការចាប់ខ្លួនសកម្មជនដីធ្លី បញ្ហាព្រំដែនសំដំឡើងប្រាក់ខែគោលរបស់កម្មករ, ការគោរពសិទ្ធិមនុស្ស, ការអនុវត្តច្បាប់ស្តីពីការងារនិងការប្រមូលផ្តុំតវ៉ាទាមទារបញ្ហាផ្សេងៗកើតឡើងចំនួន១.៣៨៨លើក។ រាល់ការតវ៉ាទាមទារនេះសុទ្ធតែត្រូវបានសម្តេតកិច្ចធ្វើការសម្របសម្រួលដោះស្រាយឱ្យមានភាពស្ងប់ស្ងាត់ទៅវិញ ។

ទន្ទឹមនឹងលទ្ធផលដែលសម្រេចបានជាវិជ្ជមាននៅមានបញ្ហាប្រឈមមួយចំនួន ដែលត្រូវយកចិត្តទុកដាក់ដោះស្រាយឱ្យបានល្អនាពេលខាងមុខ និងទៅអនាគតមានជាអាទិ៍ៈ ៖

- ការចូលរួមអនុវត្តច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានីភ្នំពេញ នៅមានការលំបាកដោយសារមិនទាន់មានលិខិតបទដ្ឋានគតិយុត្តិគ្រប់គ្រាន់សម្រាប់អនុវត្តនៅតាមរដ្ឋបាលថ្នាក់ក្រោមជាតិ។
- បញ្ហាសន្តិសុខ សុវត្ថិភាព សណ្តាប់ធ្នាប់សង្គមនៅមិនទាន់ធានាបានល្អតាមសំណូមពរ ។
- បញ្ហាចរាចរណ៍ និងសណ្តាប់ធ្នាប់តាមដងផ្លូវ និងជុំវិញទីផ្សារនៅមានភាពស្មុគស្មាញ អាស្រ័យដោយកំណើនយ៉ាងឆាប់រហ័សនៃមធ្យោបាយយានយន្ត និងប្រជាជន ។
- បញ្ហាលំនៅដ្ឋាន និងបរិស្ថាន ក៏នៅតែចោទ អាស្រ័យដោយកំណើនយ៉ាងឆាប់រហ័សនៃប្រជាជន ។
- ប្រព័ន្ធដឹកជញ្ជូនក្នុងរាជធានីភ្នំពេញមិនទាន់បានរៀបចំបានសមស្រប ជាពិសេសសម្រាប់យានយន្តធំៗ និងរថយន្តក្រុង ដែលបង្កការកកស្ទះចរាចរ និងសណ្តាប់ធ្នាប់សាធារណៈ ។
- ការផ្តល់សេវាសាធារណៈជូនប្រជាពលរដ្ឋក៏នៅមិនទាន់ឆ្លើយតបបានតាមសំណូមពរ ។

បញ្ហាប្រឈមទាំងនេះចាំបាច់ត្រូវតែរួមគ្នាដោះស្រាយជាបណ្តើរៗ និងមានការចូលរួមសហការគាំទ្រពីអាជ្ញាធរមានសមត្ថកិច្ច និងប្រជាពលរដ្ឋដើម្បីធានាបាននូវអភិបាលកិច្ចល្អ និងសណ្តាប់ធ្នាប់សាធារណៈសន្តិសុខសុវត្ថិភាពសង្គមនៅក្នុងរាជធានីភ្នំពេញ ។

ឆ្នាំ២០២០-២០២២ ជាដំណាក់កាលមានសារៈសំខាន់បំផុតដែលរាជធានីភ្នំពេញ ត្រូវបន្តខិតខំជំរុញយ៉ាងខ្លាំងក្លាលើគ្រប់ផ្នែក ក្នុងការរក្សាស្ថេរភាពនយោបាយសន្តិសុខ សុវត្ថិភាព សណ្តាប់ធ្នាប់ សាធារណៈក្នុងរាជធានីភ្នំពេញ។ ហេតុនេះ គណៈបញ្ជាការឯកភាពរដ្ឋបាលរាជធានីភ្នំពេញ ដាក់ចេញនូវគោលការណ៍សំខាន់ៗមានដូចខាងក្រោម៖

**១. មានស្ថិតិប្រជាពលរដ្ឋច្បាស់លាស់:**

- ពង្រឹងយន្តការគ្រប់គ្រងអ្នកស្នាក់នៅបណ្តោះអាសន្ន និងស្ថិតិប្រជាពលរដ្ឋ
- ផ្សព្វផ្សាយអំពីនីតិវិធីនៃការផ្លាស់ប្តូរទីលំនៅដ្ឋាន
- ជំរុញការចេញអត្តសញ្ញាណប័ណ្ណជូនប្រជាពលរដ្ឋ ទាំងអ្នកផុតសុពលភាព ខូចឬជ្រុះបាត់ឱ្យបាន គ្រប់ៗគ្នានិងបន្តការផ្តល់សៀវភៅស្នាក់នៅសៀវភៅគ្រួសារ សំបុត្រកំណើត និងផ្សព្វផ្សាយនីតិវិធីការធ្វើអត្តសញ្ញាណប័ណ្ណ/សៀវភៅស្នាក់នៅ សៀវភៅគ្រួសារ តាមប្រពន័ន្ធព័ត៌មានវិទ្យា។
- បណ្តុះបណ្តាលដល់មន្ត្រីជំនាញ និងពង្រឹងយន្តការត្រួតពិនិត្យការស្នាក់នៅរបស់ជនបរទេស ។

**២. ភូមិ សង្កាត់មានសុវត្ថិភាព និងការគ្រប់គ្រងសណ្តាប់ធ្នាប់សាធារណៈល្អ:**

- ចាត់វិធានការប្រឆាំងបទល្មើស ឱ្យមានប្រសិទ្ធភាព ដោយខិតខំធ្វើឱ្យបទល្មើសព្រហ្មទណ្ឌគ្រប់ប្រភេទមានការចុះថយបន្ថែមទៀត ពិសេសបទល្មើសដែលជះឥទ្ធិពលគំរាមកំហែងដល់សុវត្ថិភាពនិងជីវភាពសង្គម សំដៅធ្វើឱ្យប្រជាពលរដ្ឋទទួលបានសេចក្តីសុខ ទាំងផ្លូវកាយ និងផ្លូវចិត្តមានឱកាសប្រកបរបរទទួលទានប្រកបដោយភាពកក់ក្តៅ
- ខិតខំជំរុញការដោះស្រាយបញ្ហាអន្តោប្រវេសន៍ គ្រប់គ្រងជនអន្តោប្រវេសន៍និងដោះស្រាយបញ្ហាល្មើសច្បាប់របស់ជនបរទេសអោយមានប្រសិទ្ធភាពតាមច្បាប់។
- បង្កើតប៉ុស្តិ៍យាមកាម និងពង្រឹងកម្លាំងប្រជាការពារដោយធ្វើការបណ្តុះបណ្តាលពង្រឹងសមត្ថភាពដល់សមត្ថកិច្ចនិងពង្រឹងការអនុវត្តគោលនយោបាយភូមិឃុំមានសុវត្ថិភាព។
- ពង្រឹងយន្តការគ្រប់គ្រងសន្តិសុខឯកជន។
- សហការគ្រប់គ្រងជលយានឱ្យចូលចតតាមកន្លែងដែលបានកំណត់។

**៣. កាត់បន្ថយការកកស្ទះចរាចរណ៍និងគ្រោះថ្នាក់ចរាចរណ៍៖**

- ការលំអប្រព័ន្ធចរាចរណ៍ការដាក់ស្លាកសញ្ញាភ្លើងចរាចរណ៍ឱ្យបានគ្រប់គ្រាន់ និងពង្រឹងសមត្ថភាពដល់មន្ត្រីទទួលបន្ទុក
- បង្កើនការផ្សព្វផ្សាយអប់រំប្រជាពលរដ្ឋឱ្យយល់ដឹងអំពីច្បាប់ចរាចរណ៍ និងពង្រឹងយន្តការអនុវត្តច្បាប់ចរាចរណ៍ឱ្យបានពេញលេញនិងមានប្រសិទ្ធភាព។
- ពង្រឹងយន្តការត្រួតពិនិត្យបច្ចេកទេសយានយន្តជាប្រចាំ និងពង្រឹងគុណភាពការបង្រៀននិងប្រឡងយកប័ណ្ណបើកបរនិងជំរុញការធ្វើស្លាកលេខយានយន្តគ្រប់ប្រភេទ។
- រៀបចំនិងពង្រឹងយន្តការគ្រប់គ្រងចំណតរថយន្ត។
- រៀបចំប្រព័ន្ធដឹកជញ្ជូនសាធារណៈគ្រប់ប្រភេទ។
- សហកាគ្រប់គ្រងជលយានឱ្យចូលចតបានកន្លែងដែលបានកំណត់។

**៤. សហគមន៍គ្មានការប្រើប្រាស់គ្រឿងញៀន៖**

- ជំរុញការអនុវត្តផែនការរបស់រាជរដ្ឋាភិបាលស្តីពីយុទ្ធនាការប្រយុទ្ធប្រឆាំងបទល្មើសគ្រឿងញៀនខុសច្បាប់លើកទី៤ដើម្បីបង្ការ បង្ក្រាបបទល្មើសគ្រឿងញៀនឱ្យមានប្រសិទ្ធភាពខ្ពស់។
- រៀបចំឱ្យប្រសើរឡើងនៅមណ្ឌលកែប្រែនិងកសាងមណ្ឌលកែប្រែបន្ថែមសម្រាប់ជនរងគ្រោះដោយសារការប្រើប្រាស់គ្រឿងញៀន។

- បណ្តុះបណ្តាលបច្ចេកទេសដល់មន្ត្រីទទួលបន្ទុកការងារប្រឆាំងគ្រឿងញៀននិងបណ្តុះបណ្តាលវិជ្ជាជីវៈដល់ជនរងគ្រោះ។

**៥. ប្រជាពលរដ្ឋទទួលបានការផ្តល់សេវាសាធារណៈឆាប់រហ័សៈ**

- បណ្តាលបច្ចេកទេសដល់មន្ត្រីជំនាញ និងរៀបចំឱ្យមានប្រព័ន្ធព័ត៌មានដែលងាយនឹងទទួលបាន។
- រៀបចំវិធានការគ្រប់គ្រងសង្គមឱ្យបានល្អ និងបង្កើនការរៀបចំសណ្តាប់ធ្នាប់ទីប្រជុំជនឱ្យមានរបៀបរៀបរយល្អបង្កើនការឃោសនាអប់រំ ច្បាប់ស្តីពីចរាចរណ៍ផ្លូវគោកថ្មីនិងចាត់វិធានការរឹតបន្តឹងការអនុវត្តច្បាប់ចរាចរណ៍ថ្មីឱ្យបានតឹងរ៉ឹងបំផុត ដើម្បីកាត់បន្ថយគ្រោះថ្នាក់ចរាចរណ៍ឱ្យនៅទាបជំរុញវិធានការកាត់បន្ថយគ្រោះថ្នាក់ដោយសារអាវុធជាតិផ្ទុះព្រមទាំង បង្កើនវិធានការបង្ការពន្លត់អគ្គិភ័យឱ្យមានប្រសិទ្ធភាព។

# ជំពូកទី៣

# របបគំហើញនៃការអភិវឌ្ឍ

# ជំពូកទី៣
# របបគំហើញនៃការអភិវឌ្ឍ

## ៣.១. ការស្ថាបនាផ្លូវ

### ៣.១.១ គម្រោងរៀបចំបង្កើតផ្លូវថ្មើរជើងថ្មីនៅរាជធានីភ្នំពេញ

នារសៀលថ្ងៃពុធ ទី២៩ ខែមករា ឆ្នាំ២០២០នេះ រដ្ឋបាលរាជធានីភ្នំពេញ បានបើកកិច្ចប្រជុំស្តីពីគម្រោងរៀបចំផ្លូវថ្មើរជើង នៅតាមបណ្តោយទន្លេចតុមុខ ចាប់ពីមុខប្រៃសណីយ៍កម្ពុជា រហូតដល់មុខព្រះបរមរាជវាំង ការដោះស្រាយផលប៉ះពាល់ ក្នុងគម្រោងសាងសង់ស្ពានឆ្លងកាត់ទន្លេបាសាក់ ចន្លោះពីស្ពានព្រះមុនីវង្ស និងស្ពានទន្លេបាសាក់ តាខ្មៅ និងគម្រោងស្ថាបនាផ្លូវតភ្ជាប់ ពីតំបន់អភិវឌ្ឍន៍ទីក្រុងរណបជ្រោយចង្វារ ទៅកាន់មហាវិថីឈ្នះ ឈ្នះ ត្រង់ចំណុចពហុកីឡដ្ឋានមរតកតេជោ។[35]

ក្រុមការងារពិសេសរបស់រដ្ឋបាលរាជធានីភ្នំពេញ បានចុះសិក្សាពីបញ្ហាផ្សេងនិងកំណត់ទីតាំងមួយចំនួនដើម្បីឆ្ពោះបង្កើតផ្លូវថ្មើរជើង ដែលចេញពីមុខប្រៃសណីយ៍កម្ពុជា រហូតដល់មុខព្រះបរមរាជវាំង នៅពេលឆាប់ៗនេះ ដែលឆ្លើយតបទៅនឹងតម្រូវការភ្ញៀវទេសចរជាតិ និងអន្តរជាតិ។

ថ្លែងក្នុងកិច្ចប្រជុំក្រុមការងារបច្ចេកទេសរបស់សាលារាជធានីភ្នំពេញ នាល្ងាចថ្ងៃទី២៩ខែមករានេះ លោក សាំ ពិសិដ្ឋ ប្រធានមន្ទីរសាធារណការ និងដឹកជញ្ជូនរាជធានីភ្នំពេញ បានឱ្យដឹងថា ក្រុមការងារត្រៀមកែលម្អផ្លូវ ចិញ្ចើមផ្លូវ សួនច្បារ ដាំដើមឈើ និងភ្លើងលម្អពណ៌នាពេល រាត្រី រួមទាំង ផ្សាររាត្រី ផាប់ស្ទ្រីត ផ្សារណាត់ ផ្សារកសិផល ក្លឹបកម្សាន្ត ស្តាយបា កន្លែងលក់វត្ថុអនុស្សាវរីយ ផលិតផលកសិកម្ម ចំណតយានយន្ត និងចំណតផែទូកទេសចរណ៍ ដែលឆ្លើយតបទៅនឹងតម្រូវការ នៃការបង្កើតផ្លូវថ្មើរជើងប្រកបដោយភាពទាក់ទាញ។ លោកបានបញ្ជាក់ថា គម្រោងកែលម្អទាំងនេះ គឺមានភាពបន្សុីគ្នា ដែលធានាបានសុខដុមនីយកម្ម រវាងវិស័យទេសចរណ៍ និងការរៀបចំហេដ្ឋារចនាសម្ព័ន្ធទីក្រុង គឺធានាបានសណ្តាប់ធ្នាប់ ចរាណ៍ និងមិនរំខាន់ដល់ផ្លូវថ្មើរជើង។

**ឯកឧត្តម ឃួង ស្រេង** អភិបាល នៃគណៈអភិបាលរាជធានីភ្នំពេញ បានបញ្ជាក់ថា គម្រោងបង្កើតផ្លូវថ្មើរជើងនេះ នឹងក្លាយជាកញ្ចប់ទេសចរណ៍ថ្មី សម្រាប់រាជធានីភ្នំពេញ ដើម្បីទាក់ទាញភ្ញៀវទេសចរឱ្យមកលេងរាជធានីភ្នំពេញ បានកាន់តែច្រើន។ ឯកឧត្តមបានបញ្ជាក់ថាផ្លូវថ្មើរជើងនេះ ភ្ញៀវទេសចរអាចមានជម្រើសដើរ

[35] ព័ត៌មានរបស់សាលារាជធានីភ្នំពេញ
https://l.facebook.com/l.php?u=http%3A%2F%2Fwww.phnompenh.gov.kh%2F%3Ffbclid%3DIwAR13fAxsLExFXIU0OlpXcMO9q5pf-Z92CNFRQXCuAPxgS3jlNhDJZi0mw_k&h=AT15xL1lNmS1uBTYTy6a-k7ogh1Uzo4tXsUgCn_aq7eYMP8t7m4vJ5qIyQ_U9YSP_Ylp0vYr7ekeyNlLFRdnE-xPZi-MEpKuEzB2jmWrKpAj-nEjfxa4z0Z1R7z1Vg3Dau4OjQ

លេងកម្សាន្តច្រើន ដូចជានៅតំបន់រមណីយដ្ឋានប្រវត្តិសាស្ត្រ វត្តភ្នំ សួនកុមារ ប្រៃសណីយ៍ ផ្សាររាត្រី តំបន់ទេសភាពមាត់ទន្លេដ៏ស្រស់ស្អាត វត្តឧណ្ណាលោម សារមន្ទីរជាតិ ព្រះបរមរាជវាំង ដែលធ្វើឱ្យភ្ញៀវដើរទស្សនាកម្សាន្ត សប្បាយប្រកបដោយភាពរីករាយ។ ឯកឧត្តមអភិបាលបានណែនាំដល់ក្រុមការងារឱ្យសិក្សាពីពេលវេលា ប្រព័ន្ធបញ្ចៀសចរាចរណ៍ និងកន្លែងចំណតយានយន្ត ឱ្យបានត្រឹមត្រូវ ដើម្បីឱ្យកញ្ចប់សេវាទេសចរណ៍ថ្មីនេះ បានដំណើរការដោយរលូន គ្មានការរំខានដល់ប្រជាពលរដ្ឋ។

សូមបញ្ជាក់ថា កញ្ចប់ទេសចរណ៍ផ្លូវថ្មើរជើងនេះ អាចបង្កើតឡើង ក្នុងមួយសប្តាហ៍ចំនួន៣ថ្ងៃ គឺចាប់ពីថ្ងៃសុក្រ ថ្ងៃសៅរ៍ និងថ្ងៃអាទិត្យ ចាប់ពីម៉ោង១៦រសៀល ដល់ម៉ោង១២យប់ហើយមិនអនុញ្ញាតឱ្យមានយានជំនិះផ្សេងៗ ឆ្លងកាត់ឡើយ គឺសម្រាប់តែថ្មើរជើងតែប៉ុណ្ណោះ។

### ៣.១.២ ការស្ថាបនា មហាវិថីថ្មី១ខ្សែ ទទឹង៣០ម៉ែត្រ និងបណ្តោយជាង៥គីឡូម៉ែត្រ

ការស្ថាបនាមហាវិថីថ្មីមួយខ្សែដែលមានទទឹង៣០ម៉ែត្រ និងបណ្តោយផ្លូវជាង៥គីឡូម៉ែត្រ ដោយចាប់ពីផ្លូវលេខ១០០៣ ផ្លូវបត់ចូលផ្សារទំនើបអេអនម៉លសែនសុខ ស្របប្រឡាយមេខាងជើងរាជធានីភ្នំពេញ រហូតដល់មហាវិថីឈ្នះឈ្នះ ក្នុងខណ្ឌឫស្សីកែវ បានដំណើរបើកការដ្ឋានហើយ។[36]

ពិធីបើកការដ្ឋានបានធ្វើឡើងនាព្រឹកថ្ងៃទី០៧ ខែកញ្ញា ឆ្នាំ២០២០ នៅលើកបណ្តោយផ្លូវនេះ ក្នុងសង្កាត់ស្វាយប៉ាក ខណ្ឌឫស្សីកែវ ក្រោមអធិបតីភាព **ឯកឧត្តម ឃួង ស្រេង** អភិបាល នៃគណៈអភិបារាជធានីភ្នំពេញ និងមានការចូលរួមពីប្រជាពលរដ្ឋជាច្រើននាក់។

ប្រធានមន្ទីរសាធារណការ និងដឹកជញ្ជូនរាជធានីភ្នំពេញ លោក សំ ពិសិដ្ឋ បានបញ្ជាក់ឱ្យដឹងថា មហា-វិថីថ្មីនេះ ភ្ជាប់មកមហាវិថីអង្គរ ឆ្ពោះមករង្វង់មូលកាំកូ។ ជាប្រភេទផ្លូវភ្លោះ មានប្រវែង ៥៨៦០ម៉ែត្រ ទទឹង ៣០ម៉ែត្រ ជាផ្លូវបេតុងអារមេ កម្រាស់ ២០សង់ទីម៉ែត្រ។ ក្នុងនោះ ផ្លូវសងខាង ១២ម៉ែត្រ សួនកណ្តាល ២ម៉ែត្រ និងចិញ្ចើមផ្លូវសងខាង ២ម៉ែត្រ ផ្លូវទ្វេទិស មាន៣គន្លងសម្រាប់រថយន្តទៅមក និង១គន្លងសម្រាប់ទោចក្រយានយន្តទៅមក។ ដាក់បណ្តាញលូសងខាងផ្លូវទំហំ ០,៨ម៉ែត្រ ប្រវែង ១១៧២០ម៉ែត្រ និងដាក់លូឆ្លងកាត់ទទឹងផ្លូវចំនួន៨កន្លែង។

---

[36] ព័ត៌មានរបស់សាលារាជធានីភ្នំពេញ https://l.facebook.com/l.php?u=http%3A%2F%2Fwww.phnompenh.gov.kh%2F%3Ffbclid%3DIwAR13fAxsLExFXIU0OlpXcMO9q5pf-Z92CNFRQXCuAPxgS3jlNhDJZi0mw_k&h=AT15xL1lNmS1uBTYTy6a-k7ogh1Uzo4tXsUgCn_aq7eYMP8t7m4vJ5qIyQ_U9YSP_Ylp0vYr7ekeyNlLFRdnE-xPZi-MEpKuEzB2jmWrKpAj-nEjfxa4z0Z1R7z1Vg3Dau4OjQ

លោក សាំ ពិសិដ្ឋ បានបញ្ជាក់ផងដែរថា នៅកណ្តាលសួនច្បារនៃមហាវិថីនេះ ក៏មានតម្លើងបង្គោលភ្លើងបំភ្លឺផ្លូវ ព្រែកជា២ ដាំដើមជ្រៃ ដើម្បីជារបាំងពន្លឺចាំងភ្នែក និងដាំស្មៅ ជាមួយនឹងការរៀបការ៉ូឡា និងរៀបខឿនចិញ្ចើមផ្លូវសងខាង និងដាំដើមឈើ តម្លើងភ្លើងស្តុបចរាចរចំនួន ៤កន្លែង លាបគំនូសចរាចរ និងតម្លើងស្លាកសញ្ញាចរាចរផងដែរ។

**ឯកឧត្តម ឃួង ស្រេង** បានមានប្រសាសន៍លើកឡើងថា ក្រោមការដឹកនាំរបស់សម្តេចតេជោ ហ៊ុន សែន បានធ្វើអោយប្រទេសជាតិ មានសន្តិភាពពេញលេញ មានឱកាសក្នុងការអភិវឌ្ឍប្រទេសជាតិអោយរីកចំរើនយ៉ាងឆាប់រហ័ស។ ជាក់ស្តែងកំណាត់ផ្លូវយើងបានស្ថាបនាឡើងជាផ្លូវថ្មី ដែលមានបណ្តោយរហូតជាង៥គីឡូម៉ែត្រ និងមានទទឹង៣០ម៉ែត្រ អាចកាត់បន្ថយការកកស្ទះចរាចរនៅតំបន់ភាគខាងជើងរាជធានីភ្នំពេញ។ **ឯកឧត្តម ឃួង ស្រេង** ក៏បានបញ្ជាក់ផងដែរថា កំណាត់ផ្លូវនេះ ស្ថាបនាដោយក្រុមហ៊ុនឯកជន តែស្ថិត ក្រោមការត្រួតពិនិត្យបច្ចេកទេសពីមន្ទីរសាធារណការ និងដឹកជញ្ជូនរាជធានីភ្នំពេញ។ ឯកឧត្តម ក៏បានស្នើសុំអោយប្រជាពលរដ្ឋចូលរួមសហការ និងយោគយល់ចំពោះផលប៉ះពាល់ និងការរំខានពីការដ្ឋាននេះ។
ក្នុងឱកាសនោះដែរ **ឯកឧត្តម ឃួង ស្រេង** ក៏បានអំពាវនាវអោយបងប្អូនប្រជាពលរដ្ឋ និងគណៈគ្រប់គ្រងវត្តអារាម វិហារសាសនាទាំងអស់ បង្កើនការប្រុងប្រយ័ត្នចំពោះបញ្ហាសុខភាព ទប់ស្កាត់ការរីករាលដាលនៃជំងឺកូវីដ-១៩ ដោយត្រូវអនុវត្តនូវរាល់វិធានការទាំងឡាយ ទៅតាមការណែនាំរបស់ក្រសួងសុខាភិបាល ពិសេសក្នុងកំឡុងពេលប្រារព្ធពិធីបុណ្យកាន់បិណ្ឌ និងភ្ជុំបិណ្ឌនេះ បើទោះបីមកដល់ពេលនេះស្ថានភាពបង្ការ និងគ្រប់គ្រងការរីករាលដាលនៃជំងឺកូវីដ-១៩នៅរាជធានីភ្នំពេញគ្មានការចម្លងក្នុងសហគមន៍ក៏ដោយប៉ុន្តែនៅលើពិភពលោក និងបណ្តាលទីក្រុងនៃប្រទេសមួយចំនួន ក្នុងតំបន់អាស៊ាន ជំងឺនេះនៅតែបន្តរីករាលដាលគួរឱ្យព្រួយបារម្ភ។

### ៣.១.៣ ការសម្រួលប្រព័ន្ធចរាចរស្តុបក្តាន់២ និងការពង្រីកផ្លូវសហព័ន្ធរុស្ស៊ី

គម្រោងនៃការកែសម្រួលប្រព័ន្ធចរាចរ និងប្តូរទីតាំងភ្លើងស្តុបនៅតំបន់ក្តាន់២ និងការពង្រីកផ្លូវសហព័ន្ធរុស្ស៊ីការជីកដាក់លូទំហំ១ម៉ែត្រជាមួយ នឹងការអ៊ុតកៅស៊ូនៅខាងជើងផ្លូវមុខគណៈរដ្ឋមន្ត្រីបានឈានមកដល់ទីបញ្ចប់ហើយហើយបើគិតមកដល់នឹងថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០២០នេះ ក្រុមការងារនៃមន្ទីរសាធារណៈការ និងដឹកជញ្ជូនរាជធានីភ្នំពេញ បាននឹងកំពុងរៀបការ៉ូឡាលើចិញ្ចើមផ្លូវនេះយ៉ាងសកម្មផងដែរ។[37]

---

[37] ព័ត៌មានរបស់សាលារាជធានីភ្នំពេញ
https://l.facebook.com/l.php?u=http%3A%2F%2Fwww.phnompenh.gov.kh%2F%3Ffbclid%3DIwAR13fAxsLExFXIU0OlpXcMO9q5pf-Z92CNFRQXCuAPxgS3jlNhDJZi0mw_k&h=AT15xL1lNmS1uBTYTy6a-k7ogh1Uzo4tXsUgCn_aq7eYMP8t7m4vJ5qIyQ_U9YSP_Ylp0vYr7ekeyNlLFRdnE-xPZi-MEpKuEzB2jmWrKpAj-nEjfxa4z0Z1R7z1Vg3Dau4OjQ

គម្រោងនៃការកែសម្រួលប្រព័ន្ធចរាចរនៅចំណុចតំបន់ក្ដាន់២ រដ្ឋបាលរាជធានីភ្នំពេញ ធ្វើឡើងក្នុងគោលបំណង ដើម្បីឱ្យស្ថានភាពចរាចរណ៍នៅតំបន់នេះមានភាពប្រសើរជាងមុន ខណៈដែលតំបន់នេះមានការកកស្ទះចរាចរណ៍រាល់ថ្ងៃ។

ពាក់ព័ន្ធនឹងការកែសម្រួលប្រព័ន្ធចរាចរនៅចំណុចតំបន់ក្ដាន់២ និងការជីកដាក់លូតាមបណ្ដោយខាងជើងផ្លូវសហព័ន្ធរុស្ស៊ីខាងលើ រដ្ឋបាលរាជធានីភ្នំពេញបានស្ថាបនាដោយពង្រីកកំណាត់មហាវិថីសហព័ន្ធរុស្ស៊ីចិញ្ចើមផ្លូវខាងជើងដោយចាប់ពីស្ថានីយប្រេងឥន្ទនៈតូតាល់ ដល់ផ្លូវកែងមហាវិថីស៊ីធីសេនជ័រចូលទីក្រុងរណបភ្នំពេញស៊ីធីសេនធរ (អតីតតំបន់អភិវឌ្ឍន៍បឹងកក់ )នឹងដាក់លូទំហំ១ម៉ែត្រ ដើម្បីរំដោះទឹកចេញពីដងមហាវិថីព្រះមុនីវង្សនិងមហាវិថីសហព័ន្ធរុស្ស៊ី។ ការកែសម្រួលប្រព័ន្ធចរាចរណ៍នៅត្រង់ចំណុចប្រសព្វក្ដាន់២រវាងវិថីស៊ីធីសេនធ័រ (ផ្លូវR៦) និងវិថីសាធារណៈរដ្ឋឆេកនេះ រដ្ឋបាលរាជធានីភ្នំពេញបានធ្វើការកែសម្រួលផ្ទៃសួនច្បារក្ដាន់ពីរមួយផ្នែកទៅជារង្វង់មូលក្ដាន់២ និងស្ថាបនាផ្លូវជុំវិញរង្វង់មូលនេះដោយរក្សារូបសំណាកក្ដាន់២ឱ្យនៅដដែល ។ ក្រោយពីដាក់អោយដំណើរការភ្លើងស្តុបថ្មី និងការពង្រីកផ្លូវខាងលើនេះ ឃើញថាតំបន់ខាងលើនេះកាត់បន្ថយនូវការកកស្ទះចរាចរណ៍បានមួយចំនួនធំ ហើយក៏ទទួលបាននូវការកោតសរសើរ និងសាទរពីសំណាក់ប្រជាពលរដ្ឋយ៉ាងខ្លាំងផងដែរ។

គួរបញ្ជាក់ថា ដើម្បីលើកសោភ័ណភាពរាជធានីភ្នំពេញឱ្យកាន់តែមានភាពស្រស់ស្អាតនិងមានសណ្ដាប់ធ្នាប់ល្អ រដ្ឋបាលរាជធានីភ្នំពេញគ្រោងនឹងស្ថាបនារបងថ្ម នៅមុខទីស្ដីការគណៈរដ្ឋមន្ត្រីតាមបណ្ដោយមហាវិថីសហព័ន្ធរុស្ស៊ីនេះប្រវែងជិត១គីឡូម៉ែត្រ ដោយចាប់ពីការ៉ាសសាំងតូតាល់រហូតដល់ស្តុបវត្តនាគវ័នបន្ថែមទៀត។

### ៣.១.៤ ការបើកគន្លងផ្លូវអាទិភាព រថយន្តក្រុងនៅចំកណ្ដាលទ្រូងផ្លូវ

អភិបាលនៃគណៈអភិបាលរាជធានីភ្នំពេញ **ឯកឧត្តម ឃួង ស្រេង** បានប្ដេជ្ញាថា នឹងកែសម្រួលផ្លូវរត់រថយន្តក្រុងសាធារណៈឱ្យកាន់តែប្រសើរឡើង ដើម្បីអោយបងប្អូនប្រជាពលរដ្ឋងាកមកប្រើប្រាស់រថយន្តក្រុងរថយន្តក្រុងសាធារណៈ មិនប្រើប្រាស់សេវាឯកជន ដោយរដ្ឋបាលរាជធានីភ្នំពេញ នឹងរៀបចំផ្លូវអទិភាពមួយសម្រាប់តែរថយន្តក្រុងតែម្ដងពោលគឺនឹងបើកគន្លងផ្លូវអាទិភាពរថយន្តក្រុងនៅចំកណ្ដាលទ្រូងផ្លូវ ដោយចាប់ពីចំណុចប្រសព្វមហាវិថីព្រះមុនីវង្ស និងផ្លូវហ្សាដឺហ្គោល ដល់ច្រមុះជ្រូកស្ទឹងមានជ័យ។[38]

[38] ព័ត៌មានរបស់សាលារាជធានីភ្នំពេញ
https://l.facebook.com/l.php?u=http%3A%2F%2Fwww.phnompenh.gov.kh%2F%3Ffbclid%3DIwAR13fAxsLExFXIU0OlpXcMO9q5pf-Z92CNFRQXCuAPxgS3jlNhDJZi0mw_k&h=AT15xL1lNmS1uBTYTy6a-k7ogh1Uzo4tXsUgCn_aq7eYMP8t7m4vJ5qIyQ_U9YSP_Ylp0vYr7ekeyNlLFRdnE-xPZi-MEpKuEzB2jmWrKpAj-nEjfxa4z0Z1R7z1Vg3Dau4OjQ

ការប្តេជ្ញាបែបនេះរបស់ **ឯកឧត្តមអភិបាល នៃគណៈអភិបាលរាជធានីភ្នំពេញ**បានធ្វើឡើងកាលពីរសៀលថ្ងៃទី ១៧ ខែមករា ឆ្នាំ២០២០ ក្នុងអង្គប្រជុំគណៈកម្មាធិការរៀបចំផ្លូវអាទិភាពរថយន្តក្រុង និងដឹកជញ្ជូនសាធារណៈ នៅសាលារាជធានីភ្នំពេញ។

**ឯកឧត្តម ឃួង ស្រេង** បានបញ្ជាក់ផងដែរថា នេះជាការងារចាំបាច់សម្រាប់រាជធានីភ្នំពេញ ដោយត្រូវធ្វើយ៉ាងណាឱ្យរថយន្តក្រុងសាធារណៈរបស់យើងធ្វើចរាចរណ៍ទៅដោយរលូន មិនមានការកកស្ទះចរាចរណ៍។ បើការងារនេះទទួលបានជោគជ័យហើយនោះ ប្រជាពលរដ្ឋនឹងងាកមកប្រើប្រាស់សេវាដឹកជញ្ជូនសាធារណៈរថយន្តក្រុងជាក់ជាមិនខាន។ អ្វីជាគម្រោងដែលយើងត្រូវអនុវត្តគឺយើងជ្រើសរើសយកផ្លូវមួយខ្សែដោយចាប់ចាកចេញពីផ្លូវប្រសព្វវាំងផ្លូវព្រះមុនីវង្សនិងផ្លូវហ្សាដឺហ្គោលជិតផ្សារធំថ្មីទៅដល់ច្រមុះជ្រូកស្ទឹងមានជ័យ។

ឯកឧត្តមអភិបាលរាជធានី ក៏បានបញ្ជាក់ផងដែរថា បើគម្រោងទីមួយនៅលើផ្លូវអទិភាពមួយខែនេះទទួលបានជោគជ័យ រដ្ឋបាលរាជធានីភ្នំពេញនឹងធ្វើការសិក្សាទៅលើបណ្តាញផ្លូវផ្សេងៗទៀត ដើម្បីធ្វើយ៉ាងណាឱ្យខ្សែរត់នៅក្នុងរាជធានីភ្នំពេញទទួលបានការគាំទ្រនិងពេញចិត្តពេញថ្លើមពីប្រជាពលរដ្ឋ។ ការងារនេះអាចសម្រេចបានគឺត្រូវតែមានការចូលរួមពីអាជ្ញាធរខណ្ឌនិងសមត្ថកិច្ចប៉ូលីសពាក់ព័ន្ធ។

លោក អ៊ាន សុខឃីម អភិបាលរដ្ឋាករស្វយ័តដឹកជញ្ជូនសាធារណៈ រថយន្តក្រុង រាជធានីភ្នំពេញ បានមានប្រសាសន៍ថា ក្រោយការសិក្សា ក្រុមការងារយើងមានជម្រើស២ ដើម្បីប្រើប្រាស់ផ្លូវអាទិភាពសម្រាប់រថយន្តក្រុងសាធារណៈ បែងចែកជា២ជម្រើសៈ (១) គន្លងផ្លូវអាទិភាពរថយន្តក្រុងនៅចំកណ្តាលទ្រូងផ្លូវ ដែលបង្កភាពងាយស្រួលដល់ការរៀបចំគំនូសសញ្ញា និងភ្លើងសញ្ញាចរាចរណ៍ ។ ប៉ុន្តែត្រូវធ្វើចំណតរង់ចាំនៅកណ្តាលទ្រូងផ្លូវ។ (២) គន្លងផ្លូវអាទិភាពរថយន្តក្រុងខាងស្តាំជាប់ចិញ្ចើមផ្លូវគឺបង្កភាពងាយស្រួលដល់ការឈប់ចតដាក់ និងទទួលអ្នកដំណើរ កាត់បន្ថយការចំណាយ ប៉ុន្តែមានផលប៉ះពាល់ដល់សណ្តាប់ធ្នាប់តាមចិញ្ចើមផ្លូវ និងអាជីវកម្មរបស់ប្រជាពលរដ្ឋអមសងខាងផ្លូវ។

ចំពោះគម្រោងទាំង២នេះ ឯកឧត្តម ឃួង ស្រេង ក្នុងប្រជុំនោះបានសម្រេចយកផ្លូវអាទិភាពនៅចំកណ្តាលទ្រូងផ្លូវ និងបានស្នើសុំមន្ទីរជំនាញ និងខណ្ឌពាក់ព័ន្ធទាំង៤ សហការជាមួយរដ្ឋាករស្វយ័តដឹកជញ្ជូនសាធារណៈ រថយន្តក្រុងអនុវត្តន៍គម្រោងនេះឱ្យបានជោគជ័យ និងជួយរៀបចំសណ្តាប់ធ្នាប់តាមដងផ្លូវពេលម៉ោងប្រតិបត្តិការរថយន្តក្រុង គឺពេលព្រឹកចាប់ពីម៉ោង ៦និង៣០នាទី ដល់ម៉ោង៩និង៣០នាទី សម្រាប់ទិសដៅចូលរីធានីភ្នំពេញពីស្ទឹងមានជ័យដល់ផ្សារធំថ្មី និងពេលល្ងាចចាប់ពីម៉ោង៤និង៣០នាទីដល់ម៉ោង ៧និង៣០នាទី សម្រាប់ទិសដៅចេញពីរាជធានីភ្នំពេញ (ផ្សារធំថ្មីដល់ច្រមុះជ្រូកស្ទឹងមានជ័យ) ។

### ៣.១.៥ គ្រោងកសាងផ្លូវក្រោមដីពីរខ្សែ

ផ្លូវក្រោមដី២ខ្សែនៅមុខសាកលវិទ្យាល័យភូមិន្ទភ្នំពេញ និងមុខវិទ្យាស្ថានភាសាបរទេសគ្រោងនឹងបើកការដ្ឋានស្ថាបនានាពេលដ៏ខ្លីខាងមុខនេះ [39] ខណៈដែលតាមបណ្ដោយផ្លូវសហព័ន្ធរុស្ស៊ី ទទួលរងការកកស្ទះចរាចរណ៍រាល់ថ្ងៃ នៅពេលសិស្សនិស្សិតជាង២ម៉ឺននាក់ចេញ និងចូលសាលាក្នុងមួយថ្ងៃៗ។

ដើម្បីជំរុញឱ្យគម្រោងនេះដំណើរការទៅដោយរលូនរដ្ឋបាលរាជធានីភ្នំពេញ កាលពីរសៀលថ្ងៃទី០៩ ខែមករា ឆ្នាំ២០២០បានបើកកិច្ចប្រជុំមួយដើម្បីពិភាក្សាលើគម្រោងស្ថាបនាផ្លូវក្រោមដីទាំងពីរខ្សែនេះអោយបានរលូននិងទទួលបានជោគជ័យ។

ប្រធានមន្ទីរសាធារណការ និងដឹកជញ្ជូនរាជធានីភ្នំពេញ លោក សំ ពិសិដ្ឋ បានបញ្ជាក់ឱ្យដឹងក្នុងកិច្ចប្រជុំនោះថា ជាគម្រោងដែលបាននឹងកំពុងសិក្សាទៅលើផ្លូវក្រោមដីទាំង២ខ្សែនេះ គឺមួយខ្សែរត់ក្រោមផ្លូវសហព័ន្ធរុស្ស៊ីនៅចំណុចមុខសាកលវិទ្យាល័យភូមិន្ទភ្នំពេញ ទម្លុះទៅផ្លូវ២៦៥ ដោយធ្វើចរាចរណ៍ទៅមក។ ចំណែកផ្លូវក្រោមដីមួយខ្សែទៀត គ្រោងនឹងធ្វើឡើងនៅមុខវិទ្យាស្ថានភាសាបរទេស ដោយចេញពីក្នុងសាលាមុជក្រោមផ្លូវសហព័ន្ធរុស្ស៊ី ទម្លុះមកផ្លូវ២៦១ស្ថិតក្នុងសង្កាត់ទឹកល្អក់ទី១ ខណ្ឌទួលគោក ។

ក្នុងគម្រោងនេះដែរ កំណាត់ផ្លូវសហព័ន្ធរុស្ស៊ី ចាប់ពីស្ពានអាកាស៥មករា រហូតដល់ស្ពានអាកាស៧មករា គឺគ្រោងនិងបិទរបាំងថ្មទ្រូងផ្លូវ មិនឱ្យធ្វើចរាចរឆ្លងកាត់តែម្ដង។ ក្នុងកិច្ចប្រជុំនោះដែរ ក៏បានពិភាក្សាវែកញែករកដំណោះស្រាយ ថាតើក្រសួងការងារនិងបណ្ដុះបណ្ដាលវិជ្ជាជីវៈ និងសុភាពាណិជ្ជកម្មកម្ពុជា នឹងចេញចូលច្រកណាមួយ។

**ឯកឧត្តម ឃួង ស្រេង** អភិបាល នៃគណៈអភិបាលរាជធានីភ្នំពេញ ក្នុងកិច្ចប្រជុំនោះបានជំរុញឱ្យក្រុមការងារធ្វើការសិក្សាឱ្យបានម៉ត់ចត់ លើកគម្រោងស្ថាបនាផ្លូវក្រោមដី ២ខ្សែនេះ។ ដោយលោកជំរុញឱ្យមានកិច្ចប្រជុំលើកក្រោយទៀត ដោយត្រូវអញ្ជើញនាយកសាលាទាំងពីរខាងលើ ក្រសួងការងារបណ្ដុះបណ្ដាលវិជ្ជាជីវៈ និង សភាពាណិជ្ជកម្មកម្ពុជា មកប្រជុំរួមគ្នាមួយដើម្បីរកដំណោះស្រាយរួម មុននឹងដាក់ឱ្យគម្រោងខាងលើដំណើរការព្រោះថា គម្រោងនេះត្រូវតែអនុវត្តហើយដោយសារតែមាននិស្សិតប្រមាណជាង២ម៉ឺននាក់ចេញពី

[39] ព័ត៌មានរបស់សាលារាជធានីភ្នំពេញ https://l.facebook.com/l.php?u=http%3A%2F%2Fwww.phnompenh.gov.kh%2F%3Ffbclid%3DIwAR13fAxsLExFXIU0OlpXcMO9q5pf-Z92CNFRQXCuAPxgS3jlNhDJZi0mw_k&h=AT15xL1lNmS1uBTYTy6a-k7ogh1Uzo4tXsUgCn_aq7eYMP8t7m4vJ5qIyQ_U9YSP_Ylp0vYr7ekeyNlLFRdnE-xPZi-MEpKuEzB2jmWrKpAj-nEjfxa4z0Z1R7z1Vg3Dau4OjQ

សកលវិទ្យាល័យទាំងពីរនេះ ហើយតែងតែមានកកស្ទះចរាចរណ៍រាល់ថ្ងៃខណៈដែលនិស្សិតចេញនិងចូលក្នុងសាលា។

### ៣.១.៦ ការបង្កើតរង្វង់មូលនៅកន្លែងតំបន់ក្តាន់២ និងការពង្រីកទទឹង

រដ្ឋបាលរាជធានីភ្នំពេញបានសម្រេចក្នុងការបង្កើតអោយមានរង្វង់មូលមួយកន្លែងនៅតំបន់ក្តាន់២ ជាមួយគ្នានោះរដ្ឋបាលរាជធានីភ្នំពេញក៏នឹងពង្រីកទទឹងផ្លូវ ប្រវែង៣ម៉ែត្រកន្លះលើផ្លូវសហព័ន្ធរុស្សីបន្ថែមទៀតចាប់ពីមុខទីស្តីការគណៈរដ្ឋមន្ត្រី រហូតដល់ស្ពានអាកាសតិចណូផងដែរ ដើម្បីដោះចរាចរណ៍នៅតំបន់នេះឱ្យកាន់តែប្រសើរឡើងខណៈដែរតំបន់នេះក្រោយពីបង្កើតអោយមានផ្លូវឆ្លងកាត់ចេញពីតំបន់បឹងកក់ បង្កអោយមានការកកស្ទះចរាចរណ៍រាល់ថ្ងៃនោះ។[40]

ការសម្រេចបែបនេះបានធ្វើឡើង ក្នុងកិច្ចប្រជុំមួយក្រោមអធិបតីភាព **ឯកឧត្តម ឃួង ស្រេង** អភិបាល នៃគណៈអភិបាលធានីភ្នំពេញ ជាមួយអាជ្ញាធរដែនដី និងមន្ត្រីជំនាញ កាលពីរសៀលថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០១៩ នៅសាលារាជធានីភ្នំពេញ។

**ឯកឧត្តម ឃួង ស្រេង** បានឱ្យដឹងថា គម្រោងកែសម្រួលលំហូរចរាចរណ៍នៅតំបន់ក្តាន់២នេះ នឹងត្រូវចាប់ផ្តើមអនុវត្តន៍នៅដើមឆ្នាំ២០២០នេះ ខណៈដែលតំបន់នេះកំពុងប្រឈមការកកស្ទះចរាចរណ៍ជារៀងរាល់ថ្ងៃ។

តាមរយៈការសិក្សាជាលក្ខណៈវិទ្យាសាស្ត្ររបស់ក្រុមនិស្សិតនៃវិទ្យាស្ថានបច្ចេកទេសកម្ពុជា បានបង្ហាញថា ក្នុងមួយថ្ងៃៗមានយានយន្តប្រមាណជាង៥ម៉ឺន៣ពាន់គ្រឿង បានឆ្លងកាត់នៅលើផ្លូវសហព័ន្ធរ៉ុស្ស៊ី ត្រង់ចំណុចប្រសព្វក្តាន់២ ខណៈយានយន្តជាង៥ម៉ឺនគ្រឿងទៀតបានចេញដំណើរពីផ្លូវបឹងកក់ ឆ្លងកាត់ផ្លូវសហព័ន្ធរុស្ស៊ីដែលធ្វើឱ្យចំណុចនេះប្រឈមការកកស្ទះជាប្រចាំស្ទើរពេញមួយថ្ងៃ។

ឯកឧត្តមអភិបាល បានបញ្ជាក់ថា ជាដំណោះស្រាយចំពោះមុខ រដ្ឋបាលរាជធានីភ្នំពេញបានសម្រេចកែលម្អចរាចរណ៍នៅតំបន់នេះ ដោយត្រូវបង្កើតជារង្វង់មូលត្រង់ចំណុចក្តាន់២ ដែលត្រូវចំណាយតិច ហើយស្ថាបនាលឿនរហ័ស ដោយពុំបាច់រង់ចាំការធ្វើផ្លូវក្រោមដីឡើយ។

ក្នុងកិច្ចប្រជុំនោះដែរ **ឯកឧត្តម ឃួង ស្រេង** ក៏បានពន្យល់អំពីមូលហេតុមួយចំនួនដែលធ្វើឱ្យចរាចរណ៍នៅត្រង់ចំណុចប្រសព្វក្តាន់២នេះមានការកកស្ទះជាប្រចាំផងដែរ ដោយឯកឧត្តមបញ្ជាក់ថា៖ការធ្វើចរាចរណ៍ចេញ

[40] ព័ត៌មានរបស់សាលារាជធានីភ្នំពេញ
https://l.facebook.com/l.php?u=http%3A%2F%2Fwww.phnompenh.gov.kh%2F%3Ffbclid%3DIwAR13fAxsLExFXIU0OlpXcMO9q5pf-Z92CNFRQXCuAPxgS3jlNhDJZi0mw_k&h=AT15xL1lNmS1uBTYTy6a-k7ogh1Uzo4tXsUgCn_aq7eYMP8t7m4vJ5qIyQ_U9YSP_Ylp0vYr7ekeyNlLFRdnE-xPZi-MEpKuEzB2jmWrKpAj-nEjfxa4z0Z1R7z1Vg3Dau4OjQ

ពីតំបន់បឹងកក់មកផ្លូវសហព័ន្ធរ៉ុស្ស៊ីច្រើនដោយសារការបិទផ្លូវរណបម្ខាងនៅមុខទីស្តីការក្រសួងការពារជាតិ និង ប្រព័ន្ធភ្លើងស្តុបមិនទាន់ល្អប្រសើរ ធ្វើឱ្យលំហូរចរាចរណ៍ណែនណាន់តាន់តាប់ ស្ទះខ្លាំង រហូតហៀទៅដល់មុខ គណៈរដ្ឋមន្ត្រី ដូច្នេះត្រូវតែដោះស្រាយបញ្ហានេះជាបន្ទាន់។

លោក សាំ ពិសិដ្ឋ ប្រធានមន្ទីរសាធារណការ និងដឹកជញ្ជូនរាជធានីភ្នំពេញ បានឱ្យដឹងថា គម្រោងកែលម្អ ប្រព័ន្ធ ចរាចរណ៍ឡើងវិញនៅត្រង់ចំណុចប្រសព្វក្តាន់២នេះ អាចធ្វើឱ្យប្រសើរឡើងអំពីលំហូរចរាចរណ៍ នៅតំបន់នេះ រហូតដល់ជាង៤០ភាគរយ។

### ៣.១.៧ គម្រោងបើកផ្លូវ២ខ្សែនៅអមសងខាងផ្លូវរថភ្លើងដើម្បីដោះចរាចរណ៍

រដ្ឋបាលរាជធានីភ្នំពេញសហកាជាមួយក្រសួងសាធារណការនិងដឹកជញ្ជូន គ្រោងបើកផ្លូវ២ខ្សែនៅអម សងខាងផ្លូវរថភ្លើងដើម្បីដោះចរាចរណ៍ផ្លូវសហព័ន្ធរុស្ស៊ី ខណៈដែលផ្លូវសហព័ន្ធរុស្ស៊ីបាននឹងកំពុងជួបបញ្ហាកក ស្ទះចរាចរណ៍រាល់ថ្ងៃ។[41]

ដើម្បីជំរុញឱ្យគម្រោងនៃការស្ថាបនាផ្លូវ២ខ្សែនេះទទួលបានជោគជ័យ អភិបាលនៃគណៈអភិបាលរាជ ធានីភ្នំពេញ **ឯកឧត្តម ឃួង ស្រេង** និង**ឯកឧត្តម ស៊ុន ចាន់ថុល** ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសាធារណការនិង ដឹកជញ្ជូន កាលពីរសៀលថ្ងៃទី១១ ធ្នូ ២០១៩ បានអញ្ជើញចុះពិនិត្យដោយផ្ទាល់ ដោយជិះរថភ្លើងតាមបណ្តោយ ផ្លូវរថភ្លើងចាប់ពីរ៉ាមុខសត្យមុនីចេតិយ៍ហូតទៅដល់ផ្លូវកប់ស្រូវ(មហាវិថីឈ្នះឈ្នះ)។

**ឯកឧត្តម ឃួង ស្រេង** បានបញ្ជាក់ថាក្នុងគម្រោងនៃការស្ថាបនាផ្លូវ២ខ្សែនេះ គឺមិនអាចផ្តាច់បានជាមួយនឹងការ ស្ថាបនាផ្លូវរថភ្លើងនោះទេ ដោយសារថាផ្លូវរថភ្លើងមានសារៈសំខាន់ខ្លាំងសម្រាប់សេដ្ឋកិច្ចកម្ពុជា ព្រោះតែការដឹក ជញ្ជូនតាមរថភ្លើងមានតម្លៃថោក ហើយវាក៏មិនធ្វើឱ្យខូចផ្លូវជាតិផងដែរ។

**ឯកឧត្តម ស៊ុន ចាន់ថុល** ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសាធារណការនិងដឹកជញ្ជូន បានឱ្យដឹងថាការចុះ ពិនិត្យនេះធ្វើឡើងដើម្បីពិនិត្យលទ្ធភាពក្នុងការសាងសង់ផ្លូវមេតុងអាមេ អមសងខាងផ្លូវរថភ្លើងចាប់ពីចំណុច មហាវិថីគឹមអ៊ីលសុង ដល់វិថីឈ្នះឈ្នះ(ហៅផ្លូវទំនប់កប់ស្រូវ) តភ្ជាប់ទៅផ្លូវល្បឿនលឿនរាជធានីភ្នំពេញ–ខេត្ត ព្រះសីហនុដើម្បីដោះការកកស្ទះចរាចរណ៍នាពេលបច្ចុប្បន្ននៅលើផ្លូវសហព័ន្ធរុស្ស៊ី ក៏ដូចជាដើម្បីសម្រួលដល់

[41] ព័ត៌មានរបស់សាលារាជធានីភ្នំពេញ https://l.facebook.com/l.php?u=http%3A%2F%2Fwww.phnompenh.gov.kh%2F%3Ffbclid%3DIwAR13fAxsLExFXIU0OlpXcMO9q5pf-Z92CNFRQXCuAPxgS3jlNhDJZi0mw_k&h=AT15xL1lNmS1uBTYTy6a-k7ogh1Uzo4tXsUgCn_aq7eYMP8t7m4vJ5qIyQ_U9YSP_Ylp0vYr7ekeyNlLFRdnE-xPZi-MEpKuEzB2jmWrKpAj-nEjfxa4z0Z1R7z1Vg3Dau4OjQ

ការធ្វើដំណើររបស់បងប្អូនប្រជាពលរដ្ឋក្នុងរាជធានីភ្នំពេញ និងសម្រួលដល់ការដឹកទំនិញឆ្លងកាត់ចូលក្នុងរាជធានីភ្នំពេញផងដែរ

ឯកឧត្តមទេសរដ្ឋមន្ត្រីបានគូសបញ្ជាក់ទៀតថា ក្រសួងសាធារណការនិងដឹកជញ្ជូន នឹងសហការជាមួយសាលារាជធានីភ្នំពេញ និងក្រុមហ៊ុនរាជាយស្ម័យយានកម្ពុជាធ្វើការសិក្សាលទ្ធភាពនិងផលប៉ះពាល់កំណាត់ផ្លូវនេះដើម្បីលើកសំណើដាក់ជូនរាជរដ្ឋាភិបាលពិនិត្យសម្រេចនិងស្វែងរកថវិកាសាងសង់ផងដែរ។

ឆ្លៀតក្នុងឱកាសនោះផងដែរ ឯកឧត្តមទេសរដ្ឋមន្ត្រីបានគូសបញ្ជាក់ពីសារសំខាន់ផ្លូវដែកដែលអាចដឹកជញ្ជូនទំនិញធុនធ្ងន់បានយ៉ាងមានប្រសិទ្ធភាពក្នុងតម្លៃថោក និងអាចទាក់ទាញការវិនិយោគពីបរទេសបង្កើតការងារធ្វើជូនប្រជាពលរដ្ឋ។

## ៣.២ ការស្តាបនាប្រពន្ធរំដោះទឹក និងបរិស្ថាន

### ៣.២.១ ប្រឡាយបង្ហូរទឹកមានសារៈសំខាន់ណាស់សម្រាប់ទីក្រុង

អភិបាល នៃគណៈអភិបាលរាជធានីភ្នំពេញ **ឯកឧត្តម ឃួង ស្រេង** បានបញ្ជាក់ថា ប្រឡាយបង្ហូរទឹកមានសារៈប្រយោជន៍យ៉ាងខ្លាំងសម្រាប់ប្រជាពលរដ្ឋទូទៅ ដោយសម្រាប់ប្រជាពលរដ្ឋដែលរស់នៅជនបទប្រកបមុខរបរធ្វើស្រែចំការ ប្រឡាយទឹកនេះហើយ ជាអ្នកផ្តល់ទឹកឱ្យប្រជាពលរដ្ឋស្រោចស្រពស្រែ ចម្ការ ផលដំណាំផ្សេងៗ។ តែសម្រាប់ប្រជាពលរដ្ឋនៅក្នុងរាជធានីភ្នំពេញវិញ ប្រឡាយបង្ហូរទឹកក៏មានសារៈសំខាន់ ខ្លាំងណាស់ដែរ ដោយវាអាចរំដោះទឹកលិចលង់លំនៅដ្ឋានរបស់បងប្អូនប្រជាពលរដ្ឋដែលរស់នៅទីក្រុងបានយ៉ាងប្រសើរ។[42] ការបញ្ជាក់បែបនេះរបស់ **ឯកឧត្តម ឃួង ស្រេង** បានធ្វើឡើងកាលពីព្រឹកថ្ងៃទី០៨ ខែកក្កដា ឆ្នាំ២០២០ ខណៈដែល ឯកឧត្តមបានដឹកនាំមន្ត្រីជំនាញ អាជ្ញាធរដែនដី ចុះពិនិត្យមើលស្ថានីយបូមទឹកលូប្រាំ និងប្រឡាយបង្ហូរទឹកលូប្រាំស្ថិតក្នុងសង្កាត់ស្ទឹងមានជ័យ៣ខណ្ឌមានជ័យ។

ក្នុងឱកាសនោះដែរ **ឯកឧត្តម ឃួង ស្រេង** ក៏បានជំរុញឱ្យមន្ត្រីពាក់ព័ន្ធ អាជ្ញាធរដែនដី កំណត់ឱ្យបានច្បាស់ពីដីសាធារណៈរបស់រដ្ឋ និងដីជាកម្មសិទ្ធិរបស់ប្រជាពលរដ្ឋ ខណៈដែលប្រឡាយខាងលើត្រូវបានប្រជាពលរដ្ឋមួយចំនួនសង់លំនៅដ្ឋានរំលោភនៅលើប្រឡាយជាមួយនឹងការចាក់ដីបំពេញប្រឡាយរំលោភយកជាកម្មផងដែរនោះ។

---

[42] ព័ត៌មានរបស់សាលារាជធានីភ្នំពេញ https://l.facebook.com/l.php?u=http%3A%2F%2Fwww.phnompenh.gov.kh%2F%3Ffbclid%3DIwAR13fAxsLExFXIU0OlpXcMO9q5pf-Z92CNFRQXCuAPxgS3jlNhDJZi0mw_k&h=AT15xL1lNmS1uBTYTy6a-k7ogh1Uzo4tXsUgCn_aq7eYMP8t7m4vJ5qIyQ_U9YSP_Ylp0vYr7ekeyNlLFRdnE-xPZi-MEpKuEzB2jmWrKpAj-nEjfxa4z0Z1R7z1Vg3Dau4OjQ

ឯកឧត្តមបញ្ជាក់ផងដែរថា ជាជំហររបស់រដ្ឋបាលរាជធានីភ្នំពេញ យើងនឹងបង្កើតឱ្យមានក្រុមការងារមួយដែលមានការចូលរួមពីការិយាល័យសុរិយោដីខណ្ឌ មន្ទីរសាធារណការនិងដឹកជញ្ជូនរាជធានីភ្នំពេញ ដើម្បីចុះបាញ់ថ្នាំកំណត់ទីតាំងឱ្យបានច្បាស់និងធ្វើការណែនាំប្រជាពលរដ្ឋដែលរំលោភប្រឡាយខាងលើអោយរុះរើចេញ។ បើតាមការបញ្ជាក់ទីអាជ្ញាធរមូលដ្ឋាន ថាប្រឡាយលូប្រាំនេះមានទទឹង៥០ម៉ែត្រ ដោយទុកផ្លូវសងខាង ហើយត្រូវបានប្រជាពលរដ្ឋរំលោភយកចំនួនជាង១០០គ្រួសារ ដោយក្នុងនោះ នៅភូមិឬស្សី១ សង្កាត់ស្ទឹងមានជ័យ៣ ចំនួន៣៥គ្រួសារ និងភូមិឬស្សី២ ចំនួន៧៦គ្រួសារ។ ពួកគាត់ទាំងនេះបានសង់លំនៅដ្ឋានរំលោភនៅលើតួប្រឡាយតែម្តង។

គួរបញ្ជាក់ថា ស្ថានីយបូមទឹកលូ៥ មានទីតាំងស្ថិតនៅចំណុចមុំបី ចំណុចប្រសព្វ៣ខណ្ឌ គឺខណ្ឌមានជ័យ ពោធិសែនជ័យ និងខណ្ឌដង្កោ។ ប្រឡាយនេះមានតួនាទីយ៉ាងសំខាន់ក្នុងការរំដោះទឹកជំនន់ទឹកភ្លៀងចេញពីតំបន់ជាច្រើននៅក្នុងខណ្ឌទាំង៣នេះតែម្តង។

ស្ថានីយបូមទឹកលូ៥នេះ គឺជាទីតាំងយុទ្ធសាស្ត្រមួយ ក្នុងការបូមទឹកចេញពីតំបន់ខាងកើតព្រលានយន្តហោះ តំបន់ចោមចៅ តំបន់ត្រពាំងថ្លឹង ភូមិគោកបញ្ជាន់ តំបន់ផ្សារស៊ិនជូវីផ្លាហ្សា តំបន់ថ្មគោល ផ្លូវ២០០៤ និងមួយផ្នែកទៀតពីសង្កាត់ទឹកថ្លា ខាងត្បូងមហាវិថីសហព័ន្ធរុស្ស៊ី ដែលមានទំហំផ្ទៃរងទឹកភ្លៀងរហូតដល់ ១០២៨ ហិកតា។ ស្ថានីយបូមទឹកលូ៥ សាងសង់ឡើងជាអគារថ្មី មានបណ្តោយ ១៨,៩ម៉ែត្រ ទទឹង ១០,៩ ម៉ែត្រ បំពាក់បំពង់បូមទឹក៤គ្រឿង ក្នុងនោះ បំពង់មុខកាត់៨តឹក ២គ្រឿង និងបំពង់មុខកាត់១ម៉ែត្រចំនួន២គ្រឿង ដែលអាចមានសមត្ថភាពបូមទឹកបាន៥ម៉ែត្រគូប ក្នុងមួយវិនាទី និងស្មើនឹង ២៨៨០០ម៉ែត្រគូប ក្នុង១ម៉ោង។ ប្រឡាយនេះនាំទឹកហូរទៅប្រឡាយម៉រ បន្តទៅជើងឯក និងបន្តទៅស្ទឹងជ្រៅ ខេត្តកណ្តាលទើបហូរចូលទន្លេ។

### ៣.២.២ ការដ្ឋានស្ថាបនាប្រព័ន្ធលូ ការដាំដើមឈើ នៅលើមហាវិថីព្រះនរោត្តម

អភិបាលនៃគណៈអភិបាលរាជធានីភ្នំពេញ **ឯកឧត្តម ឃួង ស្រេង** នាព្រឹកថ្ងៃទី ២១ ខែឧសភា ឆ្នាំ២០២០ នេះ បានដឹកនាំមន្ត្រីជំនាញនិងអាជ្ញាធរដែនដី ចុះពិនិត្យមើលការដ្ឋានស្ថាបនា ប្រព័ន្ធលូ ការរៀបចំការ៉ូឡា រៀបជាសួនច្បារជាមួយនឹងការដាំដើមឈើ នៅតាមបណ្តោយផ្លូវព្រះនរោត្តម និងនៅលើផ្លូវលេខ៤៦២ ក្នុងសង្កាត់ទន្លេបាសាក់ខណ្ឌចំការមន។ ការចុះត្រួតពិនិត្យការដ្ឋានខាងលើនេះ គឺដើម្បីជំរុញឱ្យការដ្ឋានខាងលើ ដំណើរការទៅដោយរលូនលឿននិងមានគុណភាពភាពស្របតាមស្តង់ដារបច្ចេកទេស ។

មន្ត្រីរដ្ឋបាលរាជធានីភ្នំពេញបានបញ្ជាក់ឱ្យដឹងថា ការដ្ឋានដែលកំពុងដំណើរការនៅលើមហាវិថីព្រះនរោត្តម គឺជាការដ្ឋានដាក់ប្រព័ន្ធលូ បង្ហូរទឹកមុខកាត់១ម៉ែត្រ ការរៀបចំការីឡានៅចិញ្ចើមផ្លូវ បង្កើតជាសួនច្បារជាមួយនឹងការដាំដើមឈើផងដែរ។ ចំណែកនៅលើកំណាត់ផ្លូវ៤៦២ ការដាក់ប្រព័ន្ធលូក្រុមការងារបានដាក់រួចរាល់ហើយ។ ការងារចំពោះមុខ អភិបាលនៃគណៈអភិបាលរាជធានីភ្នំពេញ ឯកឧត្តម ឃួង ស្រេង បានជំរុញ

ឱ្យរៀបចំការ៉ូឡាតាមចិញ្ចើមផ្លូវនេះឱ្យបានលឿន ស្អាតនិងមានគុណភាព ជាមួយការអ៊ុតកៅស៊ូនៅលើបណ្ដោយផ្លូវនេះអោយបានស្អាតផងដែរ ដោយចាប់ពីមហាវិថីព្រះនរោត្តមដល់ផ្លូវលេខ៦៣។

### ៣.២.៣ ការដ្ឋានប្រឡាយស្ទឹងមានជ័យ សម្រេចបានជាង១០០០ម៉ែត្រ

ក្រោមគំនិតផ្តើមរបស់ **ឯកឧត្តម ឃួង ស្រេង** អភិបាលរាជធានីភ្នំពេញ រដ្ឋបាលរាជធានីបានប្រែក្លាយប្រឡាយស្ទឹងមានជ័យពីទឹកស្អុយ ទៅជាប្រឡាយបេតុងយ៉ាងស្អាត គ្មានក្លិនស្អុយ និងអាចរំដោះទឹកចេញពីខណ្ឌ៣ ឬគ្រប់តំបន់ ហើយគម្រោងនេះ នឹងដោះស្រាយបញ្ហាទឹកលិចនៅខណ្ឌមានជ័យ ខណ្ឌសែនសុខ និងខណ្ឌពោធិ៍សែនជ័យ។[43]

ការដ្ឋានបុកស៊ីផាយនៅប្រឡាយស្ទឹងមានជ័យ មកដល់ពេលនេះ រដ្ឋបាលរាជធានីភ្នំពេញសម្រេចការងារបានជាង១០០០ម៉ែត្រហើយ ស្មើនិង៦៨ ភាគរយ ដោយគ្រោងនិងបញ្ចប់នៅខែកក្កដាខាងមុខនេះ។
លោក សាំ ពិសិដ្ឋ ប្រធានមន្ទីរសាធារណការនិងដឹកជញ្ជូនរាជធានីភ្នំពេញ បានអោយដឹងថា ការដ្ឋានសាងសង់ប្រឡាយស្ទឹងមានជ័យ មកដល់ពេលនេះ រដ្ឋបាលរាជធានីភ្នំពេញ សម្រេចបានការងារមួយចំនួនធំហើយ ក្នុងនោះរួមមាន ៖ ទី១ ការងារបុក Sheet Pile ចាក់និងតម្លើងបង្កាន់ដៃបានប្រវែង ៧៦៣ម៉ែត្រ។ ទី២ ចាក់លូប្រអប់៣ជួរ ទទឹង៨ម៉ែត្រ បានប្រវែង ២៥៧ម៉ែត្រ។ សរុបសាងសង់បានប្រវែង១០២០ម៉ែត្រ លើប្រវែងសរុប១៥០០ម៉ែត្រ ស្មើនឹង៦៨%។ ទី៣ ជាទិសដៅគ្រោងបញ្ចប់ នៅខែកក្កដា ឆ្នាំ២០២០ខាងមុខនេះ បើក្នុងករណីបានដោះស្រាយផលប៉ះពាល់បានទាន់ពេលវេលា។

គួរបញ្ជាក់ថា តំបន់ស្ទឹងមានជ័យ រដ្ឋបាលរាជធានី បាននឹងកំពុងស្ថាបនាប្រឡាយស្ទឹងមានជ័យដោយចាក់បេតុងបុកស៊ីផាយ ទទឹង៨ម៉ែត្រ ហើយគម្រោងនេះ ត្រូវបានបែងចែកជា៤តំណាក់កាល ។ ក្នុងនោះតំណាក់កាលទី១ មានប្រវែង៣២៦ម៉ែត្រ សងខាងប្រឡាយសរុបប្រវែង៦៥២ម៉ែត្រ ហើយក្នុងជំហានទី១នោះ រដ្ឋបាលរាជធានី បានសម្រេចចាប់ឆ្នោតប្រគល់ដីជូនប្រជាពលរដ្ឋដែលរស់នៅលើប្រឡាយចំនួន១៥២គ្រួសាររួចហើយ។

ប្រឡាយស្ទឹងមានជ័យ ដែលរដ្ឋបាលរាជធានីភ្នំពេញបាននឹងកំពុងធ្វើការអភិវឌ្ឍនេះ ឆ្លងកាត់ខណ្ឌចំនួន២ គឺខណ្ឌមានជ័យនិងខណ្ឌសែនសុខ ដែលមានប្រជាពលរដ្ឋរស់នៅនិងរងផលប៉ះពាល់ប្រឡាយនេះ ចំនួន

[43] ព័ត៌មានរបស់សាលារាជធានីភ្នំពេញ
https://l.facebook.com/l.php?u=http%3A%2F%2Fwww.phnompenh.gov.kh%2F%3Ffbclid%3DIwAR13fAxsLExFXIU0OlpXcMO9q5pf-Z92CNFRQXCuAPxgS3jlNhDJZi0mw_k&h=AT15xL1lNmS1uBTYTy6a-k7ogh1Uzo4tXsUgCn_aq7eYMP8t7m4vJ5qIyQ_U9YSP_Ylp0vYr7ekeyNlLFRdnE-xPZi-MEpKuEzB2jmWrKpAj-nEjfxa4z0Z1R7z1Vg3Dau4OjQ

ជាង៥០០គ្រួសារ ហើយប្រជាពលរដ្ឋទាំងអស់នេះ នឹងទទួលបានដីទំហំ៤គុណនិង៦ម៉ែត្រជាកម្មសិទ្ធិស្របច្បាប់នៅហ្នឹងកន្លែងតែម្តង។

ប្រឡាយស្ទឹងមានជ័យ បានដើរតួយ៉ាងសំខាន់ ក្នុងការនាំទឹកទំលាក់ចូលទៅបឹងទំពុន។ ជាគម្រោងតួប្រឡាយស្ទឹងមានជ័យមានទំហំ៨ម៉ែត្រ ចិញ្ចើម២ម៉ែត្រ សាងសង់ផ្លូវបេតុងទទឹង៦ម៉ែត្រ ផ្លូវមុខផ្ទះ៥ម៉ែត្រ ដីនៅសល់មុខផ្ទះ១ម៉ែត្រកន្លះនិងក្រោយផ្ទះកន្លះម៉ែត្រ៕

### ៣.២.៤ ការពង្រាយ បង្គន់អនាម័យ នៅតាមទីសាធារណៈនានាចំនួន១២កន្លែង

រដ្ឋបាលរាជធានីភ្នំពេញ យកចិត្តទុកដាក់ទៅលើការស្ថាបនាការកែលម្អសួនច្បារនៅក្នុងរាជធានីភ្នំពេញជាមួយនឹងការដាក់បង្គន់អនាម័យនៅតាមបណ្តាសួរច្បារនានានៅក្នុងរាជធានីភ្នំពេញផងដែរ ដើម្បីធ្វើយ៉ាងណាឱ្យបរិស្ថាននៅតាមសួនច្បារបានលក្ខណៈល្អប្រសើរ ស្របទៅនឹងក្រុងដែលមានភាពស៊ីវិល័យ។[44]

លោក សំ សាមុត ប្រធានអង្គភាពសួនច្បារនិងរុក្ខជាតិ នៃមន្ទីរសាធារណការនិងដឹកជញ្ជូនរាជធានីភ្នំពេញបានអោយដឹងនៅព្រឹកថ្ងៃទី០៨ ខែមករា ឆ្នាំ២០២០នេះថា នៅរាជធានីភ្នំពេញមកដល់ពេលនេះ សម្រាប់បង្គន់ អនាម័យដែលបានបំពាក់នៅតាមទីសាធារណៈនានា មានរហូតដល់១២កន្លែង ក្នុងនោះរួមមាន នៅមុខវត្តបទុមវត្តីមានចំនួនពីរកន្លែង គឺនៅសួនកុមារចំនួន១០បង្គន់ នៅសួនក្រមង៉ុយចំនួន១០បង្គន់ នៅតំបន់កំពង់ដរអរិយក្សត្រចំនួន១៨បង្គន់ នៅខាងលិចរង្វង់មូលសម្តេចជួនណាត ៦បង្គន់ នៅបញ្ជរទេសចរណ៍ចំនួន២០បង្គន់ នៅសួនច្បារ ក្រសួងការពារជាតិ ចំនួន៦បង្គន់ នៅសួនច្បារវត្តភ្នំចំនួន ១០បង្គន់ នៅបេនឡានក្រុងឬទីលានប្រជាធិបតេយ្យខណ្ឌឫស្សីកែវចំនួន ១៥បង្គន់ នៅសួនព្រះនាងប្រាជ្ញាបារមីចំនួន១៥បង្គន់ នៅទីលានប្រជាធិបតេយ្យចាស់ចំនួន៦បង្គន់ នៅក្រោយក្រសួងសាធារណៈការនិងដឹកជញ្ជូនជាប់នឹងស្ថានទូតអាមេរិកជាមួយនិងសួនច្បារយាយពេញចំនួន២ បង្គន់ ដែលបង្គន់ទាំងនេះមានលក្ខណៈទំនើបនិងមានអនាម័យ។

លោក សំ សាមុត បានបញ្ជាក់ទៀតថា ចំពោះការងារថែទាំសួនច្បារ និងបង្គន់អនាម័យនៅទីសាធារណៈទាំងអស់នេះ គឺស្ថិតនៅក្រោមការមើលថែទាំ ពីកម្មករនៃមន្ទីរសាធារណការនិងដឹកជញ្ជូនរាជធានីភ្នំពេញ ហើយអ្នកចូលបង្គន់ទាំងនេះ គឺមិនតម្រូវឱ្យមានការបង់ប្រាក់នោះទេ។

---

[44] ព័ត៌មានរបស់សាលារាជធានីភ្នំពេញ https://l.facebook.com/l.php?u=http%3A%2F%2Fwww.phnompenh.gov.kh%2F%3Ffbclid%3DIwAR13fAxsLExFXIU0OlpXcMO9q5pf-Z92CNFRQXCuAPxgS3jlNhDJZi0mw_k&h=AT15xL1lNmS1uBTYTy6a-k7ogh1Uzo4tXsUgCn_aq7eYMP8t7m4vJ5qIyQ_U9YSP_Ylp0vYr7ekeyNlLFRdnE-xPZi-MEpKuEzB2jmWrKpAj-nEjfxa4z0Z1R7z1Vg3Dau4OjQ

លោកក៏បានបញ្ជាក់ផងដែរថា បញ្ហាប្រឈមដែលជាការលំបាកដល់បងប្អូនកម្មករមើលថែបង្គន់សាធារណៈខ្លាំងជាងគេនោះ មានបង្គន់២កន្លែង នោះគឺនៅកំពង់ផអរិយក្សត្រ១កន្លែង និងនៅមុខវត្តបុទុមវតីមួយកន្លែង ដោយសារតែមានបងប្អូនប្រជាពលរដ្ឋមួយចំនួនដែលគាត់ផឹកស្រាស្រវឹង ពួកគាត់បានចូលទៅក្អួតពាសវាលពាសកាលពេញបង្គង់ តម្រូវឱ្យកម្មករធ្វើការបោះសំអាតឡើងវិញ។

លោក សំ សាមុត ក៏បានធ្វើការអំពាវនាវឱ្យបងប្អូនប្រជាពលរដ្ឋទាំងអស់ដែលប្រើប្រាស់បង្គន់អនាម័យសាធារណៈត្រូវចូលរួមថែទាំសំអាតបរិស្ថានទាំងអស់គ្នា ពិសេសបងប្អូនជាស្ត្រីកុំយកសំឡីអនាម័យដាក់ចូលក្នុងចានបង្គន់ និងបងប្អូនបុរសកុំជក់បារីក្នុងបន្ទប់បង្គង់ផងដែរ។

**៣.២.៥ ការសម្អាតមហាវិថីឈ្នះឈ្នះឱ្យបានស្អាតជាប្រចាំ**

អភិបាល នៃគណៈអភិបាលរាជធានីភ្នំពេញ **ឯកឧត្តម ឃួង ស្រេង** បានធ្វើការណែនាំដល់អាជ្ញាធរ និងមន្ទីរជំនាញពាក់ព័ន្ធធ្វើការសម្អាតមហាវិថីឈ្នះឈ្នះឱ្យបានស្អាតជាប្រចាំ អោយមានបរិស្ថានល្អប្រសើរ ជាមួយនឹងការទុកដាក់វេចខ្ចប់សំរាមអោយបានស្អាត ហើយដើមឈើនៅតាមមហាវិថីនេះក៏ត្រូវតែកាត់លះមែកអោយបានស្អាតផងដែរ។[45]

ការណែនាំបែបនេះរបស់ **ឯកឧត្តម ឃួង ស្រេង** បានធ្វើឡើងកាលពីព្រឹកថ្ងៃទី០៣ ខែសីហា ឆ្នាំ២០២០នេះ ខណៈដែលឯកឧត្តម បានដឹកនាំអាជ្ញាធរ និងមន្ទីរពាក់ព័ន្ធមួយចំនួនចុះត្រួតពិនិត្យមើលវិមានឈ្នះឈ្នះ និងតាមបណ្ដោយមហាវិថីឈ្នះឈ្នះនេះ ដើម្បីធ្វើយ៉ាងណាឱ្យតាមបណ្ដោយមហាវិថីនេះមានបរិស្ថានល្អ មិនមានធូលីដី និងមានសណ្ដាប់ធ្នាប់ល្អប្រសើរ។

**ឯកឧត្តម ឃួង ស្រេង** បានមានប្រសាសន៍លើកឡើងថា នៅតាមបណ្ដោយមហាវិថីឈ្នះឈ្នះ ស្ថិតក្នុងខណ្ឌជ្រោយចង្វារ ឃើញថាមានធូលីដី ដក់ទឹកនៅតាមចិញ្ចើមផ្លូវជាមួយនឹងភក់ច្រំផងដែរ។ ជាងនេះទៅទៀត បញ្ហាការទុកដាក់សំរាម ក៏ជាបញ្ហាប្រឈមមួយដែរ។ ដូច្នេះទេ ឯកឧត្តមស្នើដល់អាជ្ញាធរធ្វើយ៉ាងណាចុះណែនាំបងប្អូនប្រជាពលរដ្ឋដែលលក់ដូរនៅតាមចិញ្ចើមមហាវិថីនេះ ត្រូវសម្អាតទីតាំងលក់ដូររបស់ខ្លួនអោយបានល្អ ដោយត្រូវវេចខ្ចប់ទុកដាក់សំរាមឱ្យបានត្រឹមត្រូវ ធ្វើយ៉ាងណាឱ្យតំបន់នេះមានអនាម័យ បរិស្ថានល្អ ដើម្បីចូលរួម

---

[45] ព័ត៌មានរបស់សាលារាជធានីភ្នំពេញ
https://l.facebook.com/l.php?u=http%3A%2F%2Fwww.phnompenh.gov.kh%2F%3Ffbclid%3DIwAR13fAxsLExFXIU0OlpXcMO9q5pf-Z92CNFRQXCuAPxgS3jlNhDJZi0mw_k&h=AT15xL1lNmS1uBTYTy6a-k7ogh1Uzo4tXsUgCn_aq7eYMP8t7m4vJ5qIyQ_U9YSP_Ylp0vYr7ekeyNlLFRdnE-xPZi-MEpKuEzB2jmWrKpAj-nEjfxa4z0Z1R7z1Vg3Dau4OjQ

បង្ការទប់ស្កាត់នូវជំងឺកូវីដ-១៩ទាំងអស់គ្នា ខណៈដែលជំងឺនេះបាននឹងកំពុងរីករាលដាលនៅទូទាំងពិភពលោក ហើយកម្ពុជាក៏ជាប្រទេសកំពុងតែប្រឈមដែរនោះ។[46]

ក្រៅពីបញ្ហានេះ ឯកឧត្តមអភិបាលរាជធានីភ្នំពេញ ក៏បានណែនាំដល់មន្ទីរសាធារណការ និងដឹកជញ្ជូនរាជធានីភ្នំពេញ ធ្វើការសំអាតធូលីដី ភក់ នៅលើបណ្តោយផ្លូវនេះឱ្យបានស្អាត ជាមួយនឹងការប្រើគ្រឿងចក្រកៀទឹកដក់នៅតាមបណ្តោយផ្លូវនេះឱ្យបានស្អាត។

ឯកឧត្តមបន្តថា ចំពោះមន្ទីរបរិស្ថាន និងអង្គភាពសួនច្បារ និងរុក្ខជាតិនៃមន្ទីរសាធារណៈការ និងដឹកជញ្ជូនរាជធានីភ្នំពេញ ត្រូវទទួលខុសត្រូវមើលថែដើមឈើជាប្រចាំ ពោលគឺបើដើមឈើដែលត្រូវលះមែក គឺត្រូវលះមែកចេញអោយបានស្អាត តែបើដើមឈើដែលងាប់ ក៏ត្រូវគាស់ចេញ និងដាំបន្ថែមផងដែរ។

**៣.២.៦ ការដាំដើមឈើជិត ១០០០ដើម អមផ្លូវជាតិលេខ៦**A

ដើមឈើប្រភេទធ្នង់ប្រមាណជិត ១.០០០ដើម ត្រូវបានរដ្ឋបាលរាជធានីភ្នំពេញ ដាក់ដាំពង្រាយអមតាមចិញ្ចើមផ្លូវជាតិលេខ៦អា ចាប់ពីរង្វង់មូលព្រហ្មមុខ៤ រហូតដល់វត្តវារិន្ទ សង្កាត់ព្រែកលៀប ខណ្ឌជ្រោយចង្វារ ក្នុងគោលបំណងដើម្បីបង្កើនសម្រស់បៃតង និងលើកកម្ពស់សោភណ្ឌភាព បរិស្ថានស្អាតក្នុងរាជធានីភ្នំពេញ។

ពិធីដាំដើមឈើធ្វើឡើងនៅព្រឹកថ្ងៃទី២៧ ខែមេសា ឆ្នាំ២០២០នេះ នៅមុខវត្តមង្គលសិរីកៀនឃ្លាំងក្រោមអធិបតី **ឯកឧត្តម នួន ផារ័ត្ន** អភិបាលរងរាជធានីភ្នំពេញ តំណាង ឯកឧត្តម ឃួង ស្រេង អភិបាលរាជធានីភ្នំពេញ និង លោក ម៉ៃឃើល យូបៀល តំណាងឯកអគ្គរដ្ឋទូត នៃស្ថានទូតអាមេរិកប្រចាំនៅកម្ពុជា ព្រមទាំងមានការចូលរួមពី លោក ឃ្លាំង ហួត អភិបាលខណ្ឌជ្រោយចង្វារ និង លោក លោក គាំ សីហា នាយខណ្ឌរដ្ឋបាលព្រៃឈើភ្នំពេញផងដែរ។

**ឯកឧត្តម នួន ផារ័ត្ន** បានលើកឡើងថា «**ការដាំដើមឈើនៅពេលនេះ គឺដើម្បីពង្រីកនូវគម្របពណ៌បៃតងនៅក្នុងរាជធានីភ្នំពេញ ដែលជាផែនការមួយនៅក្នុងចំណោមផែនការជាច្រើន ក្នុងនោះមាន ទីក្រុងវ៉យឆ្លាតដែលរដ្ឋបាលរាជធានីភ្នំពេញ កំពុងរៀបចំប្លង់មេ Master Plan រួមមាន ការពង្រីកគម្របពណ៌បៃតងនៅក្នុងរាជធានីភ្នំពេញផងដែរ**»។

ឯកឧត្តម នួន ផារ័ត្ន បានបន្តថា ការដាំដើមឈើនៅពេលនេះជាជំហានតូចៗ នៅក្នុងជំហានដ៏វែងឆ្ងាយសម្រាប់អភិវឌ្ឍន៍រាជធានីភ្នំពេញ គម្របបៃតងដែលនឹងធ្វើការពង្រីក និងចូលរួមលើកនៅសោភណ្ឌភាពរាជធានីភ្នំពេញផងក៏ដូចជាកាត់បន្ថយនៅផលប៉ះពាល់ពីការផ្លាស់ប្តូរអាកាសធាតុផងដែរ។

[46] សេចក្តីណែនាំរបស់ក្រសួងសុខាភិបាល

ឯកឧត្តមបញ្ជាក់ថា **«ភ្នំពេញយើងបានរៀបចំជាទីក្រុងវៃឆ្លាតមានគម្របបៃតង។ យើងមានគម្រោងរួចហើយ សម្រាប់គម្រោងអភិវឌ្ឍន៍ក្រុងឆ្នាំ២០១៥~២០៣៥ ដែលមានដូចជាគម្រោងស្ថាបនាផ្លូវ ក៏ដូចជាប្រឡាយ លូជាដើម ហើយគម្រោងនេះបានបង្កើតរួចហើយ ពោលគឺនៅតែការអនុវត្តឱ្យបានជោគជ័យប៉ុណ្ណោះ»។**

ឯកឧត្តមបានបញ្ជាក់ទៀតថា មានមនុស្សមួយចំនួនតូច ស្អប់ឈើមឈើ ដោយសារតែដើមឈើនៅមុខផ្ទះគាត់ធ្វើឱ្យប៉ះពាល់ដល់អាជីវកម្ម និងការរកស៊ីជាប្រចាំថ្ងៃរបស់ពួកគាត់ ប៉ុន្តែមានប្រជាពលរដ្ឋភាគច្រើនពួកគាត់ស្រឡាញ់ដើមឈើ ដោយសារដើមឈើក្រៅផ្តល់ម្លប់ ពណ៌បៃតង ស្រស់ស្អាតហើយ វាបានកាត់បន្ថយជាតិពុលនៅក្នុងបរិស្ថានថែមទៀត មានន័យថា មានដើមឈើគឺមានក្តីសង្ឃឹម។

តំណាងឯកអគ្គរដ្ឋទូត នៃស្ថានទូតអាមេរិកប្រចាំនៅកម្ពុជា លោក ម៉ៃឃើល យូបៀល បានចាត់ទុកថាការដាំដើមឈើនៅពេលនេះ គឺដើម្បីអបអរខួបលើកទី៧០ នៃទំនាក់ទំនងរវាងកម្ពុជា និងអាមេរិក ដែលប្រធានបទនៅក្នុងខែនេះ ទាក់ទងទៅនឹងបញ្ហាបរិស្ថាន។

លោក ម៉ៃឃើល យូបៀល បានបញ្ជាក់ឱ្យដឹងថា ការដាំដើមឈើនៅពេលនេះ គឺដើម្បីបញ្ជាក់ពីទំនាក់ទំនងដ៏យូរអង្វែងរបស់ប្រទេសទាំងពីរ។ នាយខណ្ឌរដ្ឋបាលព្រៃឈើភ្នំពេញ បានបញ្ជាក់ឱ្យដឹងថា តាមបណ្តោយផ្លូវជាតិលេខ៦Aនេះ រដ្ឋបាលរាជធានីភ្នំពេញគ្រោងនឹងដាំដើមឈើចំនួន១០០០ដើម។ ប៉ុន្តែសម្រាប់ពេលនេះ យើងដាំបានចំនួន ៨៨៦ដើមហើយដែលជាប្រភេទឈើធ្នង់សុទ្ធ ដោយចាប់ផ្តើមដាំពីគល់ស្ពានជ្រោយចង្វារដល់ព្រំប្រទល់ខេត្តកណ្តាល។

លោកបញ្ជាក់ថា ដើមឈើប្រភេទធ្នង់ប្រមាណជិតមួយពាន់ដើម ដែលមានអាយុកាលចន្លោះចាប់ពី៤ឆ្នាំទៅ៦ឆ្នាំ ដែលរដ្ឋបាលរាជធានីភ្នំពេញទទួលបានពីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ តាមរយៈរដ្ឋបាលព្រៃឈើ ត្រូវបានដាក់ដាំពង្រាយតាមបណ្តោយផ្លូវជាតិលេខ៦អា ចាប់ពីរង្វង់មូលជ្រោយចង្វារ រហូតដល់ព្រំប្រទល់ខេត្តកណ្តាល។

## ៣.៣ ការស្ថាបនាស្ពានអាកាសថ្មើរជើង

### ៣.៣.១ ការស្ថាបនាស្ពានអាកាសថ្មើរជើងផ្សារដើមគរ និងសន្ធរម៉ុកជាផ្លូវការ

រដ្ឋបាលរាជធានីភ្នំពេញ នាព្រឹកថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០១៩នេះ បានរៀបចំពិធីក្រុងពាលីទៅតាមទំនៀមទំលាប់ តាមបែបសាសនា បញ្ចុះបឋមសិលាសាងសង់ស្ពានអាកាសថ្មើរជើងនៅមុខផ្សារដើមគរ និងនៅមុខសាសាបឋមសិក្សាសន្ធរម៉ុក។ ពិធីនេះបានធ្វើឡើងក្រោមអធិបតីភាព **ឯកឧត្តម ឃួង ស្រេង អភិបាល នៃគណៈអភិបាលរាជធានីភ្នំពេញ** និងលោកជំទាវ នៅចំណុចស្តុបសន្ធម៉ុក សង្កាត់ទឹកល្អក់ទី១ ខណ្ឌទួលគោក។

បើតាមផែនការ ស្ពានអាកាសថ្មើរជើងនៅតំបន់ផ្សារដើមគរ និងនៅមុខសាលាបឋមសិក្សាសន្ធរម៉ុកនេះនឹងប្រើប្រាស់រយៈពេល៦ខែ ស្ថាបនាអោយបានរួចរាល់ ដើម្បីជួយសម្រួលដល់ការធ្វើដំណើររបស់ប្រជាពលរដ្ឋ

និងសិស្សានុសិស្សបានឆ្លងកាត់ផ្លូវប្រកបដោយសុវត្ថិភាពមិនប្រឈមទៅនឹងបញ្ហាគ្រោះថ្នាក់ចរាចរណ៍ណាមួយកើតឡើងជាយថាហេតុ។[47]

គម្រោងស្ថាបនាស្ពានអាកាសថ្មើរជើងនៅតំបន់មុខផ្សារដើមគរ ត្រូវសាងសង់ឡើងកាត់ទទឹងផ្លូវម៉ៅសេទុងខាងលិចជាប់នឹងផ្សារដើមគរ។ ចំណែកគម្រោងស្ថាបនាស្ពានអាកាសថ្មើរជើងនៅត្រង់មុខសាលាបឋមសិក្សាសន្ធរម៉ុករិញ ត្រូវសាង់សង់នៅលើចំនុចផ្លូវប្រសព្វទាំង៤ទិសតែម្តង ពោលគឺត្រូវសាងសង់កាត់ទទឹងផ្លូវម៉ៅសេទុង២ខ្សែនិងកាត់ទទឹងផ្លូវកម្ពុជាក្រោម២ខ្សែ ដើម្បីបង្កលក្ខណៈងាយស្រួលដល់សិស្សានុសិស្សបានឆ្លងកាត់ផ្លូវនេះ ដោយសុវត្ថិភាព ទោះពួកគេមកពីទិសខាងណាក៏ដោយ។

ឯកឧត្តមអភិបាលរាជធានីភ្នំពេញធ្លាប់បានអះអាងហើយថា គម្រោងស្ថាបនាស្ពានអាកាសថ្មើរជើងទាំង២ទីតាំងនេះ នឹងស្ថាបនាឡើងអោយមានគុណភាពខ្ពស់ ដែលអាចប្រើប្រាស់បានរហូតដល់៥០ឆ្នាំឡើងទៅជាមួយនិងការរចនាជណ្តើរឡើងឱ្យមានភាពងាយស្រួលឡើងចុះទាំងកុមារនិងមនុស្សចាស់ ដែលអាចធ្វើដំណើរឆ្លងកាត់បានដោយភាពងាយស្រួល។

គួរបញ្ជាក់ថា មកដល់ពេលនេះរាជធានីភ្នំពេញមានស្ពានអាកាសថ្មើរជើងចំនួន៣កន្លែងហើយ ក្នុងនោះរួមមាននៅតំបន់ជម្ពូវ័ន្តខណ្ឌពោធិសែនជ័យមានចំនួន២កន្លែង និងនៅតំបន់ភ្លើងស្តុបនាងគង្ហីង មានចំនួន១កន្លែង ហើយបើតាមគម្រោងរដ្ឋបាលរាជធានីភ្នំពេញនិងពង្រីកគម្រោងស្ថាបនានេះឱ្យបានច្រើនកន្លែងបន្ថែមទៀត ដើម្បីឆ្លើយតបទៅនឹងប្រទេសជាតិមានការអភិវឌ្ឍនិងទីក្រុងមានភាពស៊ីវិល័យ និងបង្កលក្ខណៈងាយស្រួលដល់ប្រជាពលរដ្ឋឆ្លងកាត់ផ្លូវប្រកបដោយសុវត្ថិភាព។

### ៣.៣.២ គម្រោងកសាងស្ពានអាកាសថ្មើរជើងប្រមាណជា ២៥ស្ពានទៀត

រដ្ឋបាលរាជធានីភ្នំពេញ ស្របតាមកំណើនរបស់ប្រជាពលរដ្ឋចេះតែកើនឡើងជាលំដាប់ ដោយមកដល់ពេលនេះទាំងប្រជាពលរដ្ឋដែលរស់នៅអចិន្ត្រៃយ៍ និងប្រជាពលរដ្ឋដែលរស់នៅអាស្រ័យនឹងការរកស៊ី និងធ្វើការផ្សេងទៀត មានសរុបប្រមាណជាជាង៣លាន។ ទន្ទឹមនឹងកំណើននេះ រដ្ឋបាលរាជធានីភ្នំពេញ នឹងធ្វើការស្ថាបនាស្ពានអាកាសថ្មើរជើងចំនួន២៥ទីតាំងទៀត ដើម្បីសម្រួលការកកស្ទះចរាចរណ៍ និងកាត់បន្ថយគ្រោះថ្នាក់ចរាចរណ៍ជូនប្រជាពលរដ្ឋ។

[47] ព័ត៌មានរបស់សាលារាជធានីភ្នំពេញ https://l.facebook.com/l.php?u=http%3A%2F%2Fwww.phnompenh.gov.kh%2F%3Ffbclid%3DIwAR13fAxsLExFXIU0OlpXcMO9q5pf-Z92CNFRQXCuAPxgS3jlNhDJZi0mw_k&h=AT15xL1lNmS1uBTYTy6a-k7ogh1Uzo4tXsUgCn_aq7eYMP8t7m4vJ5qIyQ_U9YSP_Ylp0vYr7ekeyNlLFRdnE-xPZi-MEpKuEzB2jmWrKpAj-nEjfxa4z0Z1R7z1Vg3Dau4OjQ

នេះបើតាមការបញ្ជាក់របស់ **ឯកឧត្តម ឃួង ស្រេង** អភិបាលរាជធានីភ្នំពេញ ខណៈដែល ឯកឧត្តម ដឹកនាំ មន្ត្រីជំនាញ និងអាជ្ញាធរដែនដី ចុះពិនិត្យការរដ្ឋានស្ថាបនាស្ពានអាកាសថ្មើរជើងផ្សារដើមគរ កាលពីព្រឹកថ្ងៃទី ១៥ ខែមិថុនា ឆ្នាំ២០២០ ស្របពេលដែលស្ពាននេះស្ថាបនាបានរួចរាល់ប្រមាណជា៩៥ភាគរតយហើយនោះ។

**ឯកឧត្តម ឃួង ស្រេង** បានមានប្រសាសន៍បញ្ជាក់ថា សម្រាប់ភ្នំពេញរបស់យើងមកដល់ពេលនេះ ទាំងអ្នកស្នាក់អាស្រ័យ ទាំងអ្នកស្នាក់នៅអចិន្ត្រៃយ៍មានចំនួនប្រមាណជាងបីលាននាក់ ដែលតម្រូវឱ្យរដ្ឋបាលរាជធានីភ្នំពេញយើង ធ្វើការអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធផ្សេងៗ ទាំងការកសាងផ្លូវ លូ ជាមួយនឹងការកសាងស្ពានអាកាសក្រោមដី លើដី និងស្ពានអាកាសថ្មើជើងជាដើម ដើម្បីដោះចរាចរណ៍ក្នុងរាជធានីភ្នំពេញ។ ជាក់ស្តែងសម្រាប់ពេលនេះ រដ្ឋបាលរាជធានីភ្នំពេញ បាននឹងកំពុងស្ថាបនាស្ពានអាកាសថ្មើរពីរកន្លែងបន្ថែមទៀត នោះគឺស្ពានអាកាសថ្មើរ ជើងផ្សារដើមគរ និងស្ពានអាកាសថ្មើរជើងនៅស្តុបសន្ធរម៉ុក។

ឯកឧត្តមបញ្ជាក់ទៀតថា ដើម្បីតម្រូវការទៅតាមការអភិវឌ្ឍយ៉ាងឆាប់រហ័សរបស់រាជធានីភ្នំពេញ រដ្ឋបាលរាជធានីភ្នំពេញនឹងកសាងស្ពានអាកាសថ្មើជើងចំនួន២៥ទីតាំងទៀតនៅក្នុងរាជធានីភ្នំពេញ ដើម្បីដោះការកកស្ទះនិងកាត់បន្ថយនូវគ្រោះថ្នាក់ចរាចរណ៍ជូនប្រជាពលរដ្ឋ ។

**ឯកឧត្តម ឃួង ស្រេង** ក៏បានបញ្ជាក់ផងដែរថា ភ្នំពេញពិតជាមានការអភិវឌ្ឍយ៉ាងលឿន ជាក់ស្តែងបើតាមការសិក្សាអង្គការចៃកាបានបង្ហាញថា ស្ពានលីយ៉ុងផាត់ឬស្ពានព្រែកព្នៅ នឹងស្ថាបនាឡើងរួចរាល់នៅឆ្នាំ២០២០ ប៉ុន្តែវាមិនដូច្នោះទេ ក្រោមការដឹកនាំរបស់សម្តេចអគ្គមហាសេនាបតីតេជោហ៊ុនសែន ស្ពានលីយ៉ុងផាត់ហៅស្ពានព្រែកព្នៅ ស្ថាបនាបានរួចរាល់តាំងពីឆ្នាំ២០១០មកម្លេះ មានន័យថា យើងបានអភិវឌ្ឍលឿនមុន១០ឆ្នាំ។

បើតាមការបញ្ជាក់ពីក្រុមហ៊ុន Space media Co,Ltd ថាគិតមកដល់ពេលនេះ ការស្ថាបនាស្ពានអាកាសថ្មើរ ជើងនៅផ្សារដើមគរនេះបានសម្រេចលទ្ធផលប្រមាណជា៩៥ភាគរយហើយ ពោលគឺនៅសល់តែការក្រាលកំរាលថ្មើជើងការសំអាត ការតុបតែង ការតភ្លើង និងការលាបថ្នាំជាដើម ហើយការងារនេះនឹងបញ្ចប់នៅ៣សប្តាហ៍ទៀត។

ចំណែកស្ពានអាកាសថ្មើរជើងនៅត្រង់មុខសាលាបឋមសិក្សាសន្ធរម៉ុក ត្រូវសាងសង់នៅលើចំណុចផ្លូវប្រសព្វទាំង៤ទិស គឺសាងសង់កាត់ទទឹងផ្លូវម៉ៅសេទុង២ខ្សែ និងកាត់ទទឹងផ្លូវកម្ពុជាក្រោម២ខ្សែ ដើម្បីបង្កលក្ខណៈងាយស្រួលដល់សិស្សានុសិស្សបានឆ្លងកាត់ស្ពាននេះ ដោយសុវត្ថិភាព ទោះពួកគេមកពីទិសខាងណាក៏ដោយ។

គួរបញ្ជាក់ថា មកដល់ពេលនេះ រាជធានីភ្នំពេញមានស្ពានអាកាសថ្មើរជើងចំនួន៣កន្លែងហើយ ក្នុងនោះរួមមាននៅតំបន់ជម្ពូវ័ន្ត ខណ្ឌពោធិ៍សែនជ័យ មានចំនួន២កន្លែង និង នៅតំបន់ភ្លើងស្តុបនាងគង្ហីងមានចំនួន ១កន្លែង ហើយបើតាមគម្រោងរដ្ឋបាលរាជធានីភ្នំពេញ និងពង្រីកគម្រោងស្ថាបនានេះឱ្យបានច្រើនកន្លែងបន្ថែម

ទៀតដើម្បីឆ្លើយតបទៅនឹងប្រទេសជាតិ មានការអភិវឌ្ឍនិងទីក្រុងមានភាពស៊ីវិល័យ និងបង្កលក្ខណៈងាយស្រួលដល់ប្រជាពលរដ្ឋឆ្លងកាត់ផ្លូវប្រកបដោយសុវត្ថិភាព រាជធានីភ្នំពេញនឹងបន្តការអភិវឌ្ឍស្ពានអាកាស ស្ពានអាកាសថ្មើរជើងបន្ថែមទៀត ដើម្បីឆ្លើយតបទៅនឹងតម្រូវកាកំណើនរបស់ប្រជាពលរដ្ឋក្នុងទីក្រុង។ ព្រមទាំងបន្តអភិវឌ្ឍទាំងហេដ្ឋារចនាសម្ព័ន្ធ ផ្លូវគមនាគមន៍ ប្រពន្ធលូ រោងចក្រ សំណាងលំនៅដ្ឋាន បុរី សំណាងអាគារផ្សេងៗទៀតជាដើម...។

# សេចក្ដីសន្និដ្ឋាន

# សេចក្តីសន្និដ្ឋាន

តាមរយៈការស្រាវជ្រាវប្រធានបទខាងលើបានបង្ហាញថាឱ្យឃើញថា ការអភិវឌ្ឍរាជធានីភ្នំពេញ ដែលជារាជធានីរបស់ព្រះរាជាណាចក្រកម្ពុជា ពិតជាមានសារៈសំខាន់ណាស់សម្រាប់ប្រទេសជាតិទាំងមូល។ ការអភិវឌ្ឍគឺនាំមកនូវ ហេដ្ឋរចនាសម្ព័ន្ធ សំណង់លំនៅដ្ឋាន អគារពាណិជ្ជកម្ម ផ្សារទំនើប ខុនដូប្រណិតៗ និងមជ្ឈមណ្ឌលកំសាន្ត ជាច្រើនកន្លែង។ ស្របតាមគោលនយោបាយ **ឈ្នះ-ឈ្នះ** ក្រោមការដឹកនាំដ៏ឆ្លៀសវៃរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា។ ដែលមានទស្សនៈ វិស័យច្បាស់លាស់ និងមានការប្តេជ្ញាខ្ពស់បានធ្វើសមាហរណកម្មកម្ពុជាចូលក្នុងតំបន់និងពិភពលោក ដើម្បីរួមគ្នាលើកកម្ពស់កិច្ចសហប្រតិបត្តិការរក្សាសន្តិសុខ សណ្តាប់ធ្នាប់សង្គមក្នុងតំបន់ និងក្នុងប្រទេសខ្លួន។ ដូចនេះហើយទើបប្រជាពលរដ្ឋកម្ពុជាគ្រប់រូបលើពាក្យមួយឃ្លាថា **អរគុណសន្តិភាព** គឺអរគុណដល់សម្តេច ដែលជាបិតាស្ថាបនិកសន្តិភាពនៅកម្ពុជា។ ក្នុងការអភិវឌ្ឍកន្លងមក នៅតែមានការជួបប្រទះទៅនឹងបញ្ហាមួយចំនួន មានន័យថាទោះបីជារាជធានីភ្នំពេញមានការរៀបចំឱ្យមានហេដ្ឋារចនាសម្ព័ន្ធផ្លូវថ្នល់ ប្រព័ន្ធលូទឹកស្អុយ សួនច្បារ ការដាក់បង្គោលភ្លើងបំភ្លឺផ្លូវ បំពាក់ប្រព័ន្ធកាមេរ៉ា ការរៀបចំចិញ្ចើមផ្លូវ សំណង់អគារ ក៏ដូចជាមានការសម្អាត និងគ្រប់គ្រង សំរាមនៅតាមទីធ្លាសាធារណៈក៏ដោយ ប៉ុន្តែរាជធានីភ្នំពេញនៅតែមានការជួបប្រទះនូវបញ្ហាអសន្តិសុខ សណ្តាប់ធ្នាប់នៅតាមតំបន់មួយចំនួននៅឡើយ។ ម្យ៉ាងវិញទៀត ទោះបីជារាជធានីភ្នំពេញមានការរៀបចំ និងការអភិវឌ្ឍយ៉ាងច្រើន ស្ទើរគ្រប់វិស័យក៏ពិតមែន ក៏ប៉ុន្តែយើងសង្កេតឃើញថា ការអភិវឌ្ឍរបស់រាជធានីនៅតែមិនទាន់ទទួលបានលទ្ធផលដូចជាការរំពឹងទុកទៅតាមផែនការអភិវឌ្ឍរបស់រាជធានីភ្នំពេញនៅឡើយទេ។

ជាពិសេសក្រោមការដឹកនាំរាជធានីសព្វថ្ងៃដោយអភិបាលនៃគណៈអភិបាលរាជធានីភ្នំពេញ **ឯកឧត្តម ឃួង ស្រេង** បានធ្វើការរៀបចំនូវសន្តិសុខក្នុងរាជធានីភ្នំពេញបានយ៉ាងល្អ ដោយមានការសហការជាមួយអាជ្ញាធរមូលដ្ឋាន ក្នុងការចុះត្រួតពិនិត្យនៅតាមតំបន់ ដើម្បីការពារពីក្មេងទំនើង ការលួច ឆក់ ប្លន់ គ្រប់ប្រភេទ ការផលិត ការចែកចាយ និង ប្រើប្រាស់គ្រឿង-ញៀន ការលេងល្បែងស៊ីសងខុសច្បាប់ ដែលទាំងនេះជាបញ្ហាប្រឈម ដែលធ្វើឱ្យប៉ះពាល់យ៉ាងខ្លាំងទៅដល់ សន្តិសុខ និងការអភិវឌ្ឍ។

លើសពីនេះ យើងសង្កេតឃើញថា រាជធានីភ្នំពេញបានធ្វើការយកចិត្តទុកដាក់ លើបញ្ហាការរៀបចំស្តារនូវប្រព័ន្ធលូទឹកស្អុយ ដែលបង្កមកពីការកកស្ទះដោយសារសំរាម ការកសាង និង ជួសជុលផ្លូវ ដែលខូចខាត លិចលង់ ដោយប្រព័ន្ធលូតូចចង្អៀត ហើយការរៀបចំកសាងសួនច្បារ ការដាក់ភ្លើងបំភ្លឺតាមដងផ្លូវ ការដាក់កាមេរ៉ា ជាពិសេស ការគ្រប់គ្រងសំរាមនៅតាមដងផ្លូវ ដែលបង្កឱ្យមានក្លិនមិនល្អ ព្រមទាំងការហូរចូលប្រព័ន្ធលូមានការកក

ស្ទះហូរមិនទាន់ពេលមានភ្លៀងធ្លាក់ដែលទាំងនេះ ជាបញ្ហាប្រឈមដែលធ្វើឱ្យប៉ះពាល់ទៅដល់សោភ័ណភាពក្នុងខណ្ឌផងដែរ។

យ៉ាងណាមិញ ក្នុងការសិក្សាស្រាវជ្រាវទៅលើប្រធានបទ "**ការអភិវឌ្ឍរាជធានីភ្នំពេញបច្ចុប្បន្ន**" នេះទៀតសោតបានធ្វើឱ្យខ្ញុំបាទ បានយល់ដឹងកាន់តែច្បាស់ពីផលប៉ះពាល់នៃការអភិវឌ្ឍរាជធានីភ្នំពេញ ព្រមទាំងបានយល់ដឹងកាន់តែច្បាស់បន្ថែមទៀត ពីផលប្រយោជន៍នៃការអភិវឌ្ឍរាជធានីភ្នំពេញនេះកាន់តែច្បាស់ជាងមុនផងដែរ។ ផលប្រយោជន៍ដែលបានមកពីការអភិវឌ្ឍធ្វើឱ្យ រាជធានីភ្នំពេញ កាន់តែមានភាពទាក់ទាញ ដោយសារសោភ័ណភាពរបស់ទីក្រុងមានភាពស្រស់ស្អាតគួរឱ្យគយគន់។

សរុបមកយើងអាចសន្និដ្ឋានបានថា ការរៀបអភិវឌ្ឍ គឺពិតជាមានសារៈសំខាន់ណាស់ ទោះបីជាក្នុងពេលនេះមិនទាន់នឹងទទួលបានជោគជ័យល្អទៅតាមផែនការដែលបានគ្រោងទុកក៏ពិតមែន ប៉ុន្តែនៅពេលខាងមុខពិតជាអាចទទួលបាននូវភាពជោគជ័យយ៉ាងពេញលេញជាក់ជាមិនខាន ព្រោះថា បើកាលណាមានការចូលរួមសហការ រវាងរាជរដ្ឋាភិបាល ក៏ដូចជា អាជ្ញាធរពាក់ព័ន្ធ ក្រសួង ស្ថាប័នពាក់ព័ន្ធនានា ជាពិសេសនោះគឺ បងប្អូនប្រជាពលរដ្ឋមានការចូលរួមសហការ ក្នុងការជួយរៀបចំសន្តិសុខ សណ្តាប់ធ្នាប់ក្នុងខណ្ឌនោះពិតប្រាកដណាស់ថានឹងទទួលបាននូវភាពជោគជ័យលើផែនការ ក៏ដូចជាទទួលបានទីកន្លែងល្អៗ ស្រស់ស្អាត មានបរិយាកាសរស់នៅល្អ មានផាសុខភាព ប្រជាពលរដ្ឋមានការរស់នៅប្រកបទៅដោយសុខសុវត្ថិភាពទាំងផ្លូវកាយ និងផ្លូវចិត្តជាពិសេសនោះ ធ្វើការអភិវឌ្ឍទីក្រុងរបស់យើង កាន់តែមានភាពល្អប្រសើរតទៅមុខជាក់ជាមិនខាន។

# អនុសាសន៍

# អនុសាសន៍

ក្នុងនាមខ្ញុំជានិស្សិតដែលបានធ្វើការតាក់តែងសារណានេះ ខ្ញុំបាទមាននូវអនុសាសន៍ជាចុងក្រោយ ក្នុងការស្នើសុំឱ្យមានកែសម្រួលមួយចំនួន ដើម្បីឈានទៅរកការអភិវឌ្ឍដ៏មានប្រសិទ្ធភាព សម្រាប់ការអភិវឌ្ឍទៅលើរាជធានីភ្នំពេញ។ ដោយយោងតាមការបកស្រាយខាងលើឃើញថា រាជធានីភ្នំពេញមានបញ្ហាប្រឈមមួយចំនួន ដែលបញ្ហាទាំងនោះភាគច្រើនបានកើតឡើងដដែលៗ ទោះបីជាមានការអភិវឌ្ឍខ្លះក៏ពិតមែន ប៉ុន្តែវានៅតែចោទជាបញ្ហា ដែលប្រជាពលរដ្ឋចង់ឱ្យអាជ្ញាធរធ្វើការកែសម្រួលនូវបញ្ហាទាំងនេះ ដែលមានដូចជា ផ្លូវថ្នល់ ប្រព័ន្ធលូ ការលក់ដូរគ្មានសណ្តាប់ធ្នាប់នៅតាមចិញ្ចើមផ្លូវ និងបញ្ហាអសន្តិសុខផ្សេងៗទៀត។ ម្យ៉ាងវិញទៀត បញ្ហាកាកសំណល់ ឬសំរាម វាជាបញ្ហាដែលកើតមានឡើង ព្រោះសំរាមតាមដងផ្លូវ និងការទុកដាក់គ្មានសណ្តាប់ធ្នាប់ ដែលធ្វើឱ្យប៉ះពាល់ដល់សោភ័ណភាព និងបរិស្ថានរបស់ខណ្ឌ ព្រមទាំងធ្វើឱ្យមានការកកស្ទះដល់ប្រព័ន្ធលូបង្ហូរទឹកផ្សេងៗ។

ជាចុងបញ្ចប់ ខ្ញុំបាទសូមមានមតិយោបល់ជាសំណើ សូមអំពាវនាវដល់រាជរដ្ឋាភិបាល សូមឱ្យមានការអភិវឌ្ឍទៅលើបណ្តាហេដ្ឋារចនាសម្ព័ន្ធឱ្យបានច្រើនជាងមុន ជាពិសេស ធ្វើការកែលម្អ និងជួសជុលនូវផ្លូវដែលមានការខូចខាតឱ្យមានភាពល្អវិញ ក៏ដូចជាកែប្រែពីផ្លូវដី មកជាផ្លូវចាក់បេតុង ឬផ្លូវកៅស៊ូ ជាដើម ហើយក៏សូមសំណូមពរផងដែរទៅលើបញ្ហាប្រព័ន្ធ លូបង្ហូរទឹក សូមធ្វើការអភិវឌ្ឍឱ្យបានទាន់ពេលវេលា ជាពិសេសធ្វើការកែលម្អប្រព័ន្ធលូពីតូចទៅធំនៅ តាមតំបន់មួយចំនួន ដែលរងនូវការជន់លិចនៅពេលមានភ្លៀងធ្លាក់ និងធ្វើការស្តារនូវប្រព័ន្ធលូចាស់ៗ ឡើងវិញ ដែលនេះជាបញ្ហាមួយដែលគួរយកចិត្តទុកដាក់ឱ្យបានល្អជាទីបំផុត។ ដូចនេះ សូមធ្វើការរៀបចំឱ្យមានភាពល្អប្រសើរ និងតាមស្តង់ដារនៅគ្រប់ទីកន្លែងទាំងអស់ ដើម្បីជៀសវាងមានការខូចខាតផ្លូវបន្តទៀត និងជៀសវាងនូវការកកស្ទះនូវប្រព័ន្ធលូ ដែលនាំឱ្យពិបាកក្នុងការធ្វើដំណើរ រាជធានីភ្នំពេញទាំងមូល។

# ឯកសារយោង


១. កម្មវិធីវិនិយោគបីឆ្នាំរំកិលរាជធានីភ្នំពេញ២០២០-២០២២

២. ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលធានី ខេត្ត ក្រុង ស្រុក ខណ្ឌ

៣. អនុក្រឹត្យលេខ ០៣ អនក្រ.បក ស្តីពី ការបង្កើតខណ្ឌបឹងកេងកង នៃរាជធានីភ្នំពេញ ចុះថ្ងៃទី ៨ ខែមករា ឆ្នាំ ២០១៩

៤. អនុក្រឹត្យលេខ ០៤ អនក្រ បក ស្តីពី.ការបង្កើតខណ្ឌកំបូល នៃរាជធានីភ្នំពេញ ចុះថ្ងៃទី ៨ ខែមករា ឆ្នាំ២០១៩

៥. ជំរឿនឆ្នាំ២០១៨

៦.យុទ្ធសាស្ត្រចតុកោណដំណាក់ការទី៤

៧.សារាចរណ៍លេខ ០៣១០ រថ អ ធរ សរច របស់ ក្រសួងរ៉ែ និងថាមពល

៨.គោលនយោបាយអភិវឌ្ឍន៍ឧស្សាហកម្មកម្ពុជាឆ្នាំ២០១៥-២០២៥

៩. គោលដៅជាយុទ្ធសាស្ត្រសុខភិបាលសម្រាប់ឆ្នាំ២០២០-២០២២

១០. វចនានុក្រមខ្មែរ សម្តេចសង្ឃរាជ ជួន ណាត


**គេហទំព័រ**


១.គេហទំព័ររដ្ឋបាលធានីភ្នំពេញ

https://l.facebook.com/l.php?u=http%3A%2F%2Fwww.phnompenh.gov.kh%2F%3Ffbclid%3DIwAR13fAxsLExFXIU0OlpXcMO9q5pf-Z92CNFRQXCuAPxgS3jlNhDJZi0mw_k&h=AT15xL1lNmS1uBTYTy6a-k7ogh1Uzo4tXsUgCn_aq7eYMP8t7m4vJ5qIyQ_U9YSP_Ylp0vYr7ekeyNlLFRdnE-xPZi-MEpKuEzB2jmWrKpAj-nEjfxa4z0Z1R7z1Vg3Dau4OjQ

២.គេហទំព័រស្តីពីភ្នំពេញ

https://km.wikipedia.org/wiki/%E1%9E%97%E1%9F%92%E1%9E%93%E1%9F%86%E1%9E%96%E1%9F%81%E1%9E%89

# ឧបសម្ព័ន្ធ